# ប្រព័ន្ធអេកូឡូស៊ី វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

# កម្ពុជា



UNITED NATIONS ESCAP
Economic and Social Commission for Asia and the Pacific



តំបន់ពណ៌ប្រផេះនៃផែនទីនេះបង្ហាញពីសមាជិក និងសមាជិករងរបស់គណៈកម្មការសេដ្ឋកិច្ចនិងសង្គមប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក (ESCAP) *

គណៈកម្មការសេដ្ឋកិច្ចនិងសង្គមប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក (ESCAP) គឺជាវេទិកាអន្តររដ្ឋាភិបាលដែលប្រកបដោយបរិយាប័ន្នបំផុតនៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក។ គណៈកម្មការនេះមានតួនាទីលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងចំណោមសមាជិកចំនួន ៥៣ ប្រទេស និងសមាជិករងចំនួន ៩ ប្រទេស សំដៅជួយស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈមនានានៅក្នុងការអភិវឌ្ឍប្រកបដោយចីរភាព។ ESCAP គឺជាគណៈកម្មការមួយក្នុងចំណោមគណៈកម្មការទាំង ៥ ប្រចាំតំបន់របស់អង្គការសហប្រជាជាតិ។

លេខាធិការដ្ឋាន ESCAP គាំទ្រដល់ការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន មានភាពធន់ និងមានចីរភាពនៅក្នុងតំបន់ តាមរយៈការបង្កើតចំណេះដឹងដែលផ្តោតលើសកម្មភាព និងតាមរយៈការផ្តល់ជាជំនួយបច្ចេកទេស និងសេវាកម្មកសាងសមត្ថភាព សំដៅជួយទ្រទ្រង់ដល់គោលដៅអភិវឌ្ឍន៍ជាតិ កិច្ចព្រមព្រៀងក្នុងតំបន់ និងការអនុវត្តរបៀបវារៈការអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០។

** ការរចនាប្លង់ដែលប្រើ និងការបង្ហាញនានានៅក្នុងផែនទីនេះ មិនមែនជាការបញ្ចេញទស្សនៈអ្វីមួយដោយលេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិ ទាក់ទងនឹងស្ថានភាពផ្នែកច្បាប់ប្រទេស ដែនដី ទីក្រុងឬតំបន់ណាមួយ ឬអាជ្ញាធររបស់ប្រទេស ឬសមត្ថកិច្ចទាក់ទងនឹងការកំណត់ព្រំដែននៃទីកន្លែងនោះទេ។*

# ប្រព័ន្ធអេកូឡូស៊ីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍កម្ពុជា

UNITED NATIONS
ESCAP
Economic and Social Commission for Asia and the Pacific

ការបោះពុម្ពផ្សាយរបស់អង្គការសហប្រជាជាតិ
រក្សាសិទ្ធិ © អង្គការសហប្រជាជាតិឆ្នាំ២០២១
រក្សាសិទ្ធិគ្រប់យ៉ាង
បោះពុម្ពនៅបាងកក
ST/ESCAP/2948

សញ្ញាសម្គាល់ប្រាក់ដុល្លារ ($) សំដៅលើប្រាក់ដុល្លាររបស់សហរដ្ឋអាមេរិក លើកលែងតែមានការបញ្ជាក់ផ្សេងទៀត។

ការរចនាប្លង់ដែលប្រើ និងការបង្ហាញនានានៅក្នុងឯកសារនេះ មិនមែនជាការបញ្ចេញទស្សនៈអ្វីមួយដោយលេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិ ទាក់ទងនឹងស្ថានភាពផ្នែកច្បាប់ប្រទេស ដែនដី ទីក្រុងឬតំបន់ណាមួយ ឬអាជ្ញាធររបស់ប្រទេស ឬសមត្ថកិច្ចទាក់ទងនឹងការកំណត់ព្រំដែននៃទីកន្លែងនោះទេ។

នៅពេលដែលមានការរចនាឈ្មោះ "ប្រទេស ឬតំបន់" នោះគឺគ្របដណ្តប់លើប្រទេស ដែនដី ទីក្រុងឬតំបន់ទាំងនោះ។

ឯកសារគន្ថនិទ្ទេស និងឯកសារយោងផ្សេងទៀតត្រូវបានធ្វើការផ្ទៀងផ្ទាត់។ អង្គការសហប្រជាជាតិមិនទទួលខុសត្រូវចំពោះសុពលភាព ឬដំណើរការនៃ URLs ទេ។

ទស្សនៈដែលបានលើកឡើងនៅក្នុងការបោះពុម្ពផ្សាយនេះគឺជាទស្សនៈរបស់អ្នករៀបរៀង ឬអ្នកចូលរួមចំណែក និងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់អង្គការសហប្រជាជាតិទេ។

ទស្សនៈ តួលេខ និងការប៉ាន់ស្មាននានាដែលបានលើកឡើងនៅក្នុងការបោះពុម្ពផ្សាយនេះគឺជាទំនួលខុសត្រូវរបស់អ្នករៀបរៀងនិងអ្នកចូលរួមចំណែក និងមិនត្រូវចាត់ទុកថាជាការឆ្លុះបញ្ចាំងពីទស្សនៈ ឬមានការឯកភាពពីអង្គការសហប្រជាជាតិឡើយ។ រាល់កំហុសឆ្គងណាមួយដែលមាន គឺជាទំនួលខុសត្រូវរបស់អ្នករៀបរៀង។

សេចក្តីយោងអំពីឈ្មោះក្រុមហ៊ុន និងផលិតផលពាណិជ្ជកម្ម ពុំបញ្ជាក់ថា អង្គការសហប្រជាជាតិឯកភាពតាមសេចក្តីយោងទាំងនោះទេ ហើយការដែលមិនបានបញ្ចេញឈ្មោះសហគ្រាស ផលិតផលពាណិជ្ជកម្ម ឬដំណើរការណាមួយ ក៏ពុំមែនជាសញ្ញានៃការមិនយល់ព្រមដែរ។

ការប្រើប្រាស់ការបោះពុម្ពផ្សាយសម្រាប់គោលបំណងពាណិជ្ជកម្មណាមួយត្រូវបានហាមឃាត់ លើកលែងតែមានការអនុញ្ញាតជាមុនពីលេខាធិការក្រុមប្រឹក្សាបោះពុម្ពផ្សាយ នៃអង្គការសហប្រជាជាតិ ប្រចាំនៅទីក្រុងញូវយ៉ក។ ការស្នើសុំការអនុញ្ញាតបោះពុម្ពផ្សាយត្រូវបញ្ជាក់ពីគោលបំណង និងទំហំនៃការបោះពុម្ពផ្សាយនោះ។

# អារម្ភកថា

វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (វ.ប.ន.) នឹងដើរតួនាទីដ៏សំខាន់ដែលមិនអាចខ្វះបានសម្រាប់ប្រទេសកម្ពុជាក្នុងការឈានទៅសម្រេចបាននូវមហិច្ឆតាគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ប្រែក្លាយខ្លួនទៅជាប្រទេសដែលមានសេដ្ឋកិច្ចផ្អែកលើនវានុវត្តន៍ជាមូលដ្ឋាន និងស្តារសេដ្ឋកិច្ចឡើងវិញបន្ទាប់ពីមានវិបត្តិជំងឺរាតត្បាតកូវីដ-១៩។ ក៏ប៉ុន្តែ ដើម្បីទាញយកសក្តានុពលឱ្យបានពេញលេញពី វ.ប.ន. និងកសាងសេដ្ឋកិច្ចឡើងវិញជាលក្ខណៈយុទ្ធសាស្ត្រ រាជរដ្ឋាភិបាលកម្ពុជាចាំបាច់ត្រូវមានគោលនយោបាយផ្អែកលើទឡ្ហីករណ៍ ដែលមើលឱ្យហួសពីលក្ខន្តិកៈចាំបាច់ផ្នែកសេដ្ឋកិច្ច និងដែលជួយជំរុញឱ្យមានការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន ភាពធន់ និងចីរភាព។ ទន្ទឹមគ្នានេះដែរ គោលនយោបាយ ដែលជួយបង្កបរិយាកាសអំណោយផលដល់អាជីវកម្ម អ្នកស្រាវជ្រាវ និងនវានុវត្តជន ក៏ជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់ធានាថា គ្មានបុគ្គលណាម្នាក់ត្រូវបានគេទុកចោលនោះឡើយ។

របាយការណ៍ស្តីពី ប្រព័ន្ធអេកូឡូស៊ី វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជា ត្រូវបានកសាងឡើងក្រោមការគាំទ្រពីគណៈកម្មការសេដ្ឋកិច្ច និងសង្គមប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិកនៃអង្គការសហប្រជាជាតិ (ESCAP) ក្រោមកិច្ចសហការជាមួយអគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងផ្តល់ការគាំទ្រដល់ការកសាងគោលនយោបាយជាតិស្តីពី វ.ប.ន.។ របាយការណ៍នេះបានពិនិត្យពិច័យលើក្របខ័ណ្ឌគោលនយោបាយបច្ចុប្បន្ន តួអង្គពាក់ព័ន្ធ ព្រមទាំងចំណុចខ្លាំង និងចំណុចខ្សោយនៃប្រព័ន្ធនវានុវត្តន៍ជាតិ។ ដោយបានផ្អែកលើលទ្ធផលនៃការវាយតម្លៃ របាយការណ៍នេះបានផ្តល់ជាអនុសាសន៍ចំនួន ៥ ចំណុចពាក់ព័ន្ធនឹងយុទ្ធសាស្ត្រគោលនយោបាយ រួមមានជាអាទិ៍៖ ១) កែលម្អអភិបាលកិច្ចនៃប្រព័ន្ធ វ.ប.ន. ២) កសាងធនធានមូលធនក្នុងវិស័យ វ.ប.ន. ៣) ពង្រឹងសមត្ថភាពស្រាវជ្រាវ និងគុណភាព ៤) បង្កើនកិច្ចសហការ និងបណ្តាញរវាងតួអង្គពាក់ព័ន្ធ និង ៥) ជំរុញប្រព័ន្ធអេកូឡូស៊ីដែលបង្កបរិយាកាសដល់នវានុវត្តន៍។

បន្ថែមទៀតនោះ លទ្ធផលនៃការវាយតម្លៃក៏បានផ្តល់ជាមូលដ្ឋានវិភាគសម្រាប់ «ផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជា ២០៣០» ដែលត្រូវបានតាក់តែងឡើងដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដោយមានការគាំទ្រពី ESCAP។ ផែនទីបង្ហាញផ្លូវនឹងជួយតម្រង់ទិសមន្ត្រីរាជរដ្ឋាភិបាល និងតួអង្គពាក់ព័ន្ធសំខាន់ៗ នៅក្នុងការអនុវត្តសកម្មភាពដែលចាំបាច់ សំដៅពង្រឹងសមត្ថភាពជាតិក្នុងវិស័យ វ.ប.ន. និងបណ្តុះប្រព័ន្ធនវានុវត្តន៍ប្រកបដោយថាមវន្ត។ តួអង្គពាក់ព័ន្ធជាច្រើនបានចូលរួមផ្តល់ធាតុចូលសំខាន់ៗទៅក្នុងរបាយការណ៍នេះ ក្នុងនោះរួមមានថ្នាក់អគ្គនាយកមកពីក្រសួង/ស្ថាប័នចំនួន ១៨ សាកលវិទ្យាធិការ និងនាយកស្ថាប័នស្រាវជ្រាវមកពីគ្រឹះស្ថានអប់រំ និងស្រាវជ្រាវឈានមុខចំនួន ៨ នាយកប្រតិបត្តិក្រុមហ៊ុនក្នុងវិស័យផ្សេងៗគ្នា ថ្នាក់ដឹកនាំមកពីមជ្ឈមណ្ឌលពន្លឿនការបណ្តុះធុរកិច្ចចំនួន ៣ ព្រមទាំងដៃគូអភិវឌ្ឍន៍អន្តរជាតិចំនួន ៣ ផងដែរ។

របាយការណ៍នេះគឺជាសមិទ្ធផលដែលបានប្រសូតចេញពីភាពជាដៃគូជិតស្និទ្ធរវាង ESCAP និង ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ កិច្ចខិតខំប្រឹងប្រែងក្នុងការស្រាវជ្រាវ និងការរៀបចំកសាងផែនទីបង្ហាញផ្លូវ វ.ប.ន. កម្ពុជា ២០៣០ ក៏ជាលទ្ធផលដែលបានមកពីកិច្ចសហការយ៉ាងស្អិតល្មួតរវាងស្ថាប័នទាំងពីរដែរ។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា របាយការណ៍ស្តីពីប្រព័ន្ធអេកូឡូស៊ី វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជា នឹងក្លាយជាធនធានដ៏មានសារសំខាន់ដើម្បីជួយប្រទេសកម្ពុជាក្នុងការឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយវិបុលភាព បរិយាប័ន្ន ភាពធន់ និងចីរភាព នាពេលអនាគត។

**អគ្គលេខាធិការរងនៃអង្គការសហប្រជាជាតិ**
**លេខាធិការប្រតិបត្តិនៃគណៈកម្មការសេដ្ឋកិច្ច និងសង្គម**
**ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក**

Armida Salsiah Alisjahbana

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា**
**និងនវានុវត្តន៍**

***កិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ***

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍វិភាគអំពីប្រព័ន្ធអេកូឡូស៊ីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (វ.ប.ន.) នេះត្រូវបានរៀបចំឡើងក្រោមការគាំទ្ររបស់ផ្នែកពាណិជ្ជកម្ម វិនិយោគ និងនវានុវត្តន៍ នៃគណៈកម្មការសេដ្ឋកិច្ចនិងសង្គមប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក (The Trade, Investment and Innovation Division of the Economic and Social Commission for Asia and the Pacific - ESCAP)។ របាយការណ៍នេះត្រូវបានរៀបរៀងដោយលោកស្រី Francie Sadeski និងលោក Matthieu Lacave ជាទីប្រឹក្សានាំមុខរបស់ Technopolis Group នៅទីក្រុងប៉ារីស ដោយមានការត្រួតពិនិត្យរបស់លោកស្រី Marta Pérez Cusó ជាមន្ត្រីផ្នែកកិច្ចការសេដ្ឋកិច្ចរបស់គណៈកម្មការសេដ្ឋកិច្ច និងសង្គមប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក និងការគាំទ្របច្ចេកទេសរបស់លោក Rafael Torquato Cruz ជាមន្ត្រីគម្រោងបច្ចេកវិទ្យា និងនវានុវត្តន៍របស់គណៈកម្មការសេដ្ឋកិច្ច និងសង្គមប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក។ ឯកឧត្តមបណ្ឌិត ហ៊ុល សៀងហេង អគ្គនាយកនៃអគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (អ.វ.ប.ន.) និងលោកបណ្ឌិត ស្រ៊ុន បញ្ញារិទ្ធិ ប្រធាននាយកដ្ឋានគោលនយោបាយវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានរួមចំណែកផ្តល់ជាទិសដៅរួមក្នុងការរៀបរៀងរបាយការណ៍។

របាយការណ៍វិភាគនេះត្រូវបានតាក់តែងឡើងនៅឆ្នាំ២០២០ ដើម្បីផ្តល់ជាធាតុចូលសម្រាប់ដំណើរការរៀបចំបង្កើតផែនទីបង្ហាញផ្លូវ វ.ប.ន. ឆ្នាំ២០៣០ និងបានបញ្ចូលនូវទិន្នន័យ ក៏ដូចជាការយល់ដឹងយ៉ាងទូលំទូលាយដែលប្រមូលបាន នៅក្នុងដំណើរការបង្កើតផែនទីបង្ហាញ វ.ប.ន. ឆ្នាំ២០៣០។ របាយការណ៍នេះក៏ទទួលបានធាតុចូលសំខាន់ៗពីក្រុមជំនាញដែលបានចូលរួមនៅគ្រប់ដំណាក់កាលនៃការកសាងឯកសារ ក្នុងនោះរួមមាន៖

- លោកបណ្ឌិត ទ្រី សុផល អគ្គនាយករងនៃ អ.វ.ប.ន.
- លោកស្រីបណ្ឌិត គ្រី ណាល់លីស អគ្គនាយិការងនៃ អ.វ.ប.ន.
- លោក អ៊ិន សំបូរ អគ្គនាយករងនៃ អ.វ.ប.ន.
- លោក កែ ប៊ុនធឿន ប្រធាននាយកដ្ឋានផ្ទេរបច្ចេកវិទ្យា
- លោកស្រី សេង ម៉ូលិកា ប្រធាននាយកដ្ឋានគ្រប់គ្រងព័ត៌មាន អ.វ.ប.ន.
- លោកស្រីបណ្ឌិត លី សុខនី ប្រធាននាយកដ្ឋានសហប្រតិបត្តិការវិស័យ អ.វ.ប.ន. និង
- លោកបណ្ឌិត ជាតិ សុផល ប្រធាននាយកដ្ឋានត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយ

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមយ៉ាងយកចិត្តទុកដាក់ ពីសំណាក់តំណាងភាគីពាក់ព័ន្ធជាតិជាច្រើន ដែលបានរួមចំណែកក្នុងការផ្តល់ធាតុចូលសំខាន់ៗ និងសូមថ្លែងអំណរគុណសម្រាប់ការសម្របសម្រួលរបស់លោក Kal Joffres ជានាយកប្រតិបត្តិនៃក្រុមហ៊ុន Tandemic នៅក្នុងដំណើរការរៀបចំជារួមសម្រាប់ដំណើរការសិក្ខាទាំងមូល។ សូមថ្លែងអំណរគុណចំពោះលោកស្រី Mary Ann Perkins ដែលបានចូលរួមកែសម្រួលរបាយការណ៍ និងសូមថ្លែងអំណរគុណលោកស្រី Phadnalin Ngernlim និងលោកស្រី Su-Arjar Lewchalermvongs ដែលបានផ្តល់ការគាំទ្រផ្នែករដ្ឋបាលក្នុងការចងក្រងរបាយការណ៍នេះ។

# ខ្លឹមសារសង្ខេបប្រតិបត្តិ

ក្នុងរយៈពេលពីរទសវត្សរ៍កន្លងទៅនេះ នៅមុនពេលមានវិបត្តិសេដ្ឋកិច្ចដែលបង្កឡើងដោយជំងឺកូវីដ-១៩ ប្រទេសកម្ពុជា បានរំលេចឡើងនូវសមិទ្ធកម្មសេដ្ឋកិច្ចដ៏ខ្លាំងក្លា និងវឌ្ឍនភាពគួរឱ្យកត់សម្គាល់នៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព និងមានវិសាលភាពកាន់តែទូលំទូលាយ ក៏ដូចជាការកាត់បន្ថយភាពក្រីក្រ។ សមិទ្ធកម្មដ៏រឹងមាំនេះអាចសម្រេចទៅបាន ដោយសារតែមានការជំរុញគោលនយោបាយសាធារណៈសមប្រកប ដែលអាចធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងសេដ្ឋកិច្ចបើកចំហ។

ខណៈដែលរាជរដ្ឋាភិបាលសម្រេចបានវឌ្ឍនភាពនៅក្នុងពហុវិស័យ សេដ្ឋកិច្ចរបស់ប្រទេសក៏កំពុងតែស្ថិតនៅក្នុងដំណាក់កាលនៃការធ្វើឧស្សាហូបនីយកម្ម និងទំនើបកម្មឥតឈប់ឈរ។ កម្ពុជាស្ថិតនៅក្នុងចំណោមប្រទេសនាំចេញអង្ករច្រើនជាងគេទាំង ១០ នៅលើពិភពលោក ដោយក្នុងនោះកម្ពុជាបានបង្កើនការនាំចេញអង្ករទ្វេដងក្នុងអំឡុងឆ្នាំ២០១៣ ដល់ ២០១៧។ ការរួមចំណែកនៃវិស័យឧស្សាហកម្មនៅក្នុងផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) បានកើនឡើងដល់ទៅចំនួន ៣២,៨% គិតត្រឹមឆ្នាំ២០១៨។ វិស័យសេវាកម្មក៏ឃើញមានកំណើនប្រចាំឆ្នាំខ្លាំងក្លាផងដែរ ជាពិសេសតាមរយៈសមិទ្ធកម្មដែលប្រសើរនៃពាណិជ្ជកម្មក្នុងស្រុក និងការដឹកជញ្ជូន។

ចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ មានមហិច្ឆតាកសាងកម្ពុជាឱ្យក្លាយទៅជាប្រទេសដែលមិនត្រឹមតែមានវិបុលភាពប៉ុណ្ណោះទេ ថែមទាំងមានបរិយាប័ន្នក្នុងសង្គម និងមានចីរភាពបរិស្ថានផងដែរ តាមរយៈការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាត្រឹមឆ្នាំ២០៥០។

វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (វ.ប.ន.) នឹងដើរតួនាទីយ៉ាងចាំបាច់បំផុត សម្រាប់ប្រទេសកម្ពុជាដើម្បីឈានទៅសម្រេចបាននូវចក្ខុវិស័យរបស់ខ្លួន ព្រមទាំងប្រែក្លាយទៅជាប្រទេសដែលមានចំណូលខ្ពស់ដែលដឹកនាំតម្រង់ទិសដោយនវានុវត្តន៍នៅឆ្នាំ២០៥០។ ហេតុដូច្នេះហើយ ទើបរាជរដ្ឋាភិបាលកម្ពុជាបានរៀបចំសេចក្តីព្រាងគោលនយោបាយសំខាន់ៗដើម្បីជួយជំរុញការងារស្រាវជ្រាវ នវានុវត្តន៍ និងសហគ្រិនភាព។ រាជរដ្ឋាភិបាលក៏បានលើកកម្ពស់វិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដូចមានរំលេចនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣ និងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥។

នៅក្នុងឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តគោលនយោបាយជាតិស្តីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ២០២០-២០៣០ ក្នុងគោលបំណងកសាងសមត្ថភាពជាតិនៅក្នុងវិស័យ វ.ប.ន. និងពង្រឹងសមិទ្ធនវានុវត្តន៍ សំដៅឆ្លើយតបទៅនឹងតម្រូវការជាមូលដ្ឋានរបស់ជាតិ។

នៅក្នុងឆ្នាំ២០២០ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ឧ.វ.ប.ន.) ត្រូវបានបង្កើតឡើង ដោយមានភារកិច្ចដឹកនាំ និងសម្របសម្រួលគំនិតផ្តួចផ្តើមនានានៅក្នុងវិស័យ វ.ប.ន. សំដៅអភិវឌ្ឍសមត្ថភាពជាតិបន្ថែមទៀតក្នុងវិស័យនេះ ព្រមទាំងផ្តល់ការគាំទ្រដល់តួអង្គពាក់ព័ន្ធសំខាន់ៗ និងបង្កើតលក្ខខណ្ឌក្របខ័ណ្ឌអំណោយផលផ្សេងៗ។

នៅកម្ពុជា ប្រព័ន្ធអេកូឡូស៊ីសម្រាប់បណ្តុះធុរកិច្ចថ្មីក្នុងវិស័យបច្ចេកវិទ្យាមានការរីកចម្រើនយ៉ាងឆាប់រហ័ស ក្នុងនោះធុរកិច្ចថ្មីផ្នែកបច្ចេកវិទ្យាដែលសកម្មចំនួនជាង ៣០០ គឺកំពុងដំណើរការនៅក្នុងកម្រិតផ្សេងៗគ្នា។ ការគាំទ្រពីវិស័យឯកជនចំពោះនវានុវត្តន៍ក៏កំពុងរីកដុះដាលផងដែរ តួយ៉ាង គេសង្កេតឃើញមានវត្តមានសេវាកម្មមួយចំនួនកើនឡើងនៅក្នុងទីផ្សារដូចជា កន្លែងធ្វើការងាររួមគ្នា (Co-Working Spaces) មជ្ឈមណ្ឌលភ្ញាស់ (Incubation Centers) វិនិយោគិនក្នុងស្រុកលើធុរកិច្ចថ្មី (Local Angel Investors) មូលនិធិមូលធនឯកជន (Private Equity Funds) និងមូលនិធិវិនិយោគផ្សងព្រេង (Venture Capital Funds)។ ស្ថាប័នឧត្តមសិក្សាបានចាប់ផ្តើមផ្តោតការយកចិត្តទុកដាក់លើការលើកកម្ពស់វិស័យសហគ្រិនភាព និងនវានុវត្តន៍ ដោយមានសាកលវិទ្យាល័យខ្លះបានបង្កើតមជ្ឈមណ្ឌលភ្ញាស់ និងមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មីផ្ទាល់ខ្លួន ក៏ដូចជាបានបង្កើតការិយាល័យភ្ជាប់ទំនាក់ទំនងជាមួយសហគ្រាស។ ការអនុម័តច្បាប់មួយចំនួន ដូចជា ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងច្បាប់ស្តីពីការប្រកួតប្រជែង បានរួមចំណែកជួយបង្កើតលក្ខខណ្ឌអំណោយផលដល់សហគ្រិនភាព និងហ៊ានប្រឈមនឹងហានិភ័យ។

ទោះយ៉ាងណា ប្រព័ន្ធនវានុវត្តន៍ជាតិរបស់ប្រទេសកម្ពុជា នៅតែមិនទាន់មានការរៀបចំនៅឡើយ។ ជាក់ស្តែង នៅក្នុង**សន្ទស្សន៍នវានុវត្តន៍សកល** ឆ្នាំ២០១៨ កម្ពុជាជាប់ចំណាត់ថ្នាក់លេខ ១០១ ក្នុងចំណោម ១២៧ ប្រទេស ក្នុងនោះកម្ពុជាទទួលបានពិន្ទុទាប ទាក់ទិននឹង ការចំណាយលើវិស័យអប់រំ ការចុះឈ្មោះចូលរៀននៅថ្នាក់ឧត្តមសិក្សា និងការងារដែលពឹងផ្អែកខ្លាំងលើចំណេះដឹង។ ខណៈដែលរចនាសម្ព័ន្ធថ្មីរបស់រាជរដ្ឋាភិបាល សម្រាប់លើកកម្ពស់វិស័យ វ.ប.ន. អាចផ្តល់ជាមូលដ្ឋានដ៏រឹងមាំក្នុងការអភិវឌ្ឍប្រព័ន្ធនវានុវត្តន៍ជាតិក្តី ក៏កិច្ចសហការគ្នាក្នុងចំណោមតួអង្គពាក់ព័ន្ធ ជាអាទិ៍៖ នៅក្នុងជួររាជរដ្ឋាភិបាល និងរវាងរដ្ឋាភិបាល វិស័យឯកជន និងគ្រឹះស្ថានអប់រំ នៅតែមានភាពទន់ខ្សោយនៅឡើយ។ ការបែងចែកទំនួលខុសត្រូវសម្រាប់វិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ក្នុងចំណោមក្រសួង-ស្ថាប័នសំខាន់ៗទាំង ១១ គឺជាបញ្ហាប្រឈមនៅក្នុងអភិបាលកិច្ច និងការអភិវឌ្ឍគោលនយោបាយឱ្យមានប្រសិទ្ធភាព ក្នុងនោះដែរ សមត្ថកិច្ចរបស់ក្រសួង ឧ.វ.ប.ន. ក្នុងនាមជាស្ថាប័នចម្បងក្នុងការសម្របសម្រួលក៏នៅតែត្រូវការបង្រួបបង្រួមបន្ថែមទៀតដែរ។

ការយល់ដឹងអំពីនវានុវត្តន៍ និងវិទ្យាសាស្ត្រនៅកម្ពុជានៅមានកម្រិតនៅឡើយ។ បទដ្ឋានសង្គមពាក់ព័ន្ធនឹងទំនាក់ទំនងយេនឌ័រនៅតែបន្តជាឧបសគ្គរាំងដល់ការអភិវឌ្ឍសក្តានុពលរបស់ស្ត្រី ក៏ដូចជារារាំងការផ្តល់សិទ្ធិអំណាចជូនពួកគាត់ដើម្បីមានលទ្ធភាពប្រឡូកនៅក្នុងវិស័យសេដ្ឋកិច្ច សង្គម សាធារណៈ និងនយោបាយ។ លើសពីនេះទៀត ការបញ្ចៀសមិនចង់ជួបហានិភ័យក៏ជាឧបសគ្គរាំងដល់វិស័យនវានុវត្តន៍ដែរ។ ខណៈដែលវប្បធម៌វិទ្យាសាស្ត្រនៅតែមានកម្រិត គេក៏សង្កេតឃើញពីភាពមិនស៊ីចង្វាក់គ្នារវាងការអប់រំផ្នែកវិទ្យាសាស្ត្របច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (ស្ទែម) និងរវាងទីផ្សារការងារ។ មាននិស្សិតមួយចំនួនតូចតែប៉ុណ្ណោះដែលកំពុងសិក្សាលើមុខវិជ្ជាវិទ្យាសាស្ត្រ វិស្វកម្ម និងកសិកម្ម ពោលគឺជាមុខវិជ្ជាសិក្សា និងជាជំនាញដែលត្រូវបានចាត់ទុកថាជាគន្លឹះដ៏សំខាន់ដើម្បីជំរុញកំណើនសេដ្ឋកិច្ចជាតិ។ ជាងនេះទៅទៀត សហគ្រាសធុនតូច និងមធ្យមជាច្រើននៅតែមានការស្ទាក់ស្ទើរក្នុងការចុះបញ្ជីជាផ្លូវការ ដោយបន្តស្ថិតនៅក្រៅផ្លូវការដដែល។ នៅពេលដែលលក្ខខណ្ឌក្របខ័ណ្ឌកំពុងមានភាពប្រសើរឡើង ប៉ុន្តែបទដ្ឋាននិងប្រព័ន្ធវិញ្ញាបនបត្រកម្មពុំបានដំណើរការពេញលេញនៅឡើយ ដែលបានកាត់បន្ថយឱកាសសម្រាប់សហគ្រាសក្នុងការហក់ចូលទៅក្នុងខ្សែច្រវ៉ាក់តម្លៃអន្តរជាតិ។

ដើម្បីពង្រឹងប្រព័ន្ធនវានុវត្តន៍ជាតិបន្ថែមទៀត យុទ្ធសាស្ត្រគោលនយោបាយត្រូវបានផ្តល់ជាអនុសាសន៍ ដូចមានរៀបរាប់ខាងក្រោម។

- **កែលម្អអភិបាលកិច្ចនៃប្រព័ន្ធ វ.ប.ន.៖** ពង្រឹងសមត្ថកិច្ចរបស់ក្រសួង ឧ.វ.ប.ន. ដោយការកំណត់ឱ្យបានច្បាស់លាស់ពីតួនាទីរបស់ក្រសួង និងតួអង្គពាក់ព័ន្ធដទៃទៀត ទាក់ទងនឹងការលើកកម្ពស់វិស័យ វ.ប.ន. លើកកម្ពស់ការយល់ដឹង និងពង្រឹងសមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តគោលនយោបាយជាតិ វ.ប.ន. និងត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពនៅក្នុងការលើកកម្ពស់វិស័យ វ.ប.ន.។
- **កសាងមូលធនមនុស្សផ្នែក វ.ប.ន.៖** ការបង្រៀនមុខវិជ្ជា វ.ប.ន. តាំងពីកុមារភាពនឹងជួយបង្កើតក្រុមអ្នកវិទ្យាសាស្ត្រ និងអ្នកនវានុវត្តជំនាន់ថ្មី។ ជំនាញផ្នែកស្វែមក៏ត្រូវការការលើកកម្ពស់នៅក្នុងថ្នាក់ឧត្តមសិក្សាផងដែរ។ លើសពីនេះទៀត ការពង្រឹងកិច្ចការបង្រៀន និងកិច្ចសហការជាមួយវិស័យឯកជននៅតាមស្ថាប័នអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (ធីវេត) គួរត្រូវបានគិតគូរពង្រឹងបន្ថែមទៀត។
- **ពង្រឹងសមត្ថភាពស្រាវជ្រាវ និងគុណភាព ៖** ដើម្បីគាំទ្រដល់ការស្រាវជ្រាវដែលមានគុណភាពខ្ពស់ និងសកម្មភាពអភិវឌ្ឍន៍ដែលយកផលប្រយោជន៍ជាតិជាចម្បង ចាំបាច់ត្រូវអនុវត្តសកម្មភាពមួយចំនួនជាអាទិ៍៖ បង្កើតរបៀបវារៈស្រាវជ្រាវជាតិជាមួយសហគមន៍អ្នកសិក្សាស្រាវជ្រាវ និងសហការយ៉ាងជិតស្និទ្ធជាមួយវិស័យឯកជន ផ្តល់ជាមូលនិធិដើម្បីគាំទ្រស្នាដៃលេចធ្លោពាក់ព័ន្ធនឹងវិទ្យាសាស្ត្រ ការធ្វើអន្តរជាតូបនីយកម្មកិច្ចការស្រាវជ្រាវ ព្រមទាំងលើកទឹកចិត្តឱ្យមានកិច្ចសហការជាមួយវិស័យឯកជន។
- **បង្កើនកិច្ចសហការនិងបណ្តាញរវាងតួអង្គពាក់ព័ន្ធ៖** ដើម្បីគាំទ្រដល់នវានុវត្តន៍នៅក្នុងសហគ្រាសធុនតូច និងមធ្យម និងដើម្បីបង្កើនសមត្ថភាពស្រូបយក ចាំបាច់ត្រូវលើកកម្ពស់ និងទ្រទ្រង់បរិក្ខារឧបទ្ទេសភ្ញាស់ និងពន្លឿនធុរកិច្ច វេទិកាបច្ចេកវិទ្យាដែលបើកចំហដល់វិស័យឯកជន និងបណ្តុំស្ថាប័នដែលមានលក្ខណៈនវានុវត្តន៍សំដៅជំរុញកិច្ចសហការ។
- **ជំរុញប្រព័ន្ធអេកូឡូស៊ីដែលបង្កបរិយាកាសអំណោយផលដល់នវានុវត្តន៍៖** ដើម្បីគាំទ្រសមត្ថភាពនវានុវត្តន៍ និងបង្កើនសមត្ថភាពស្រូបយករបស់ក្រុមហ៊ុន ទាមទារឱ្យមានហិរញ្ញប្បទាន និងការលើកកម្ពស់រចនាសម្ព័ន្ធអន្តរការីដែលជួយបណ្តុះធុរកិច្ចថ្មី (Start-ups) ក៏ដូចជាគាំទ្រការផ្ទេរបច្ចេកវិទ្យា និងលើកកម្ពស់បច្ចេកវិទ្យាក្នុងស្រុក។ លើសពីនេះទៅទៀត គេក៏ចាំបាច់ត្រូវជួយជំរុញស្ថាប័នណាដែលមានសមត្ថកិច្ចក្នុងការផ្តល់សេវាកម្មបច្ចេកវិទ្យា និងគុណភាព (ដូចជា បទដ្ឋាននិងវិញ្ញាបនបត្រកម្ម) ទៅដល់បណ្តាក្រុមហ៊ុន។ ម្យ៉ាងទៀត វាក៏ទាមទារនូវការបង្កើនលទ្ធភាពទទួលបានហិរញ្ញប្បទាន សម្រាប់សកម្មភាពនវានុវត្តន៍ តាមរយៈការលើកកម្ពស់ការវិនិយោគពីវិស័យឯកជន និងការទាក់ទាញប្រភពថវិកាពីម្ចាស់ជំនួយ។ ការលើកទឹកចិត្តឱ្យមានការវិនិយោគផ្ទាល់ពីបរទេស ដែលគាំទ្រដល់ការកសាង សមត្ថភាពបច្ចេកវិទ្យាក្នុងស្រុក។

# មាតិកា

**អារម្ភកថា** ..... i
**សេចក្តីថ្លែងអំណរគុណ** ..... iii
**ខ្លឹមសារសង្ខេបប្រតិបត្តិ** ..... iv
**មាតិកា** ..... vi
**បញ្ជីអក្សរកាត់** ..... ix
**ជំពូកទី ១ បរិបទសង្គមសេដ្ឋកិច្ចកម្ពុជា** ..... ១
១.១ ទិដ្ឋភាពទូទៅ ..... ១
១.២ រចនាសម្ព័ន្ធតាមវិស័យនៃសេដ្ឋកិច្ចកម្ពុជា ..... ៤
**ជំពូកទី ២ មហិច្ឆតាកម្ពុជាឆ្នាំ២០៣០ និង២០៥០** ..... ៩
២.១ យុទ្ធសាស្ត្រជាតិ ..... ៩
២.២ យុទ្ធសាស្ត្រតាមវិស័យ ..... ១០
២.៣ តួនាទីរបស់នវានុវត្តន៍ដើម្បីសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ..... ១៤
. ២.៤ បច្ចេកវិទ្យាដែលជាអាទិភាព ..... ១៥
**ជំពូកទី ៣ ប្រព័ន្ធនវានុវត្តន៍ជាតិកម្ពុជា** ..... ១៧
៣.១ ក្របខ័ណ្ឌទស្សនទាន ..... ១៧
៣.២ ការចាប់បដិសន្ធិនៃប្រព័ន្ធនវានុវត្តន៍ជាតិ ..... ២០
**ជំពូកទី ៤ ភាពខ្លាំងនៃប្រព័ន្ធនវានុវត្តន៍ជាតិ** ..... ២២
៤.១ ទិដ្ឋភាពទូទៅនៃរដ្ឋាភិបាល និងអភិបាលកិច្ចដែលបង្កបរិយាកាសដល់ការអភិវឌ្ឍ វិស័យ វ.ប.ន. ..... ២២
៤.២ ពន្លកនៃប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធនវានុវត្តន៍ ..... ២៦
៤.៣ វឌ្ឍនភាពឈានឡើងនៃប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មីផ្នែកបច្ចេកវិទ្យាទំនើប ..... ៣០
៤.៤ ការបោះជំហានទៅមុខនៃប្រព័ន្ធអប់រំ និងស្រាវជ្រាវ ..... ៣៣
៤.៥ លក្ខខណ្ឌនៃក្របខ័ណ្ឌអនុគ្រោះ ..... ៣៩
**ជំពូកទី ៥ ចំណុចខ្សោយនៃប្រព័ន្ធនវានុវត្តន៍ជាតិ** ..... ៤១
៥.១ បញ្ហាប្រឈមនៅក្នុងអភិបាលកិច្ចផ្នែក វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ..... ៤១
៥.២ ប្រព័ន្ធអេកូឡូស៊ីឧស្សាហកម្មមួយដែលគ្មានតុល្យភាព ..... ៤៣
៥.៣ កង្វះវប្បធម៌វិទ្យាសាស្ត្រ និងសហគ្រិនភាព ជំនាញវិជ្ជាជីវៈ និងការស្រាវជ្រាវមានគុណភាព ..... ៤៤
៥.៤ ហេដ្ឋារចនាសម្ព័ន្ធ និងលក្ខខណ្ឌនៃក្របខ័ណ្ឌថ្មីដែលត្រូវការការពង្រឹងបន្ថែម ..... ៤៨
**ជំពូកទី ៦ សេចក្តីសន្និដ្ឋាន និងអនុសាសន៍** ..... ៥១
**ឯកសារយោង** ..... ៥៣
**ឧបសម្ព័ន្ធ** ..... ៥៥

## ប្រអប់


ប្រអប់ ១.១. សូចនាករសង្គមសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ..... ២
ប្រអប់ ៤.១. វិធានការដើម្បីបង្កើនការទទួលបានហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា ..... ២៨
ប្រអប់ ៤.២. កាលានុវត្តភាពដែលមិនទាន់ប្រើប្រាស់សម្រាប់ការបណ្ដុះធុរកិច្ចថ្មីឌីជីថលនៅប្រទេសកម្ពុជា ..... ៣១
ប្រអប់ ៤.៣. ការគាំទ្រដល់សកម្មភាពសហគ្រិនភាពនៅក្នុងសាកលវិទ្យាល័យ ..... ៣៥
ប្រអប់ ៤.៤. និន្នាការនៃការបោះពុម្ពផ្សាយសំខាន់ៗនៅកម្ពុជា ពីឆ្នាំ២០០០-២០១៩ ..... ៣៨


## រូបភាព


រូបភាព ៣.១ ក្របខ័ណ្ឌនៃប្រព័ន្ធនវានុវត្តន៍ជាតិ ..... ១៨
រូបភាព ៣.២ ព័ត៌មានស្ដីអំពីកម្ពុជា សន្ទស្សន៍នវានុវត្តន៍សកល ឆ្នាំ២០២០ ..... ២១
រូបភាព ៤.១ ភាពខ្លាំងនៃប្រពន្ធ័នវានុវត្តន៍ជាតិកម្ពុជា ..... ២២
រូបភាព ៥.១. ចំណុចខ្សោយរបស់ប្រព័ន្ធនវានុវត្តន៍ជាតិកម្ពុជា ..... ៤១


## តារាង


តារាង ៣.១ ក្របខ័ណ្ឌប្រព័ន្ធនវានុវត្តន៍ជាតិ ..... ១៩
តារាង ៤.១. រចនាសម្ព័ន្ធក្រសួង ឧ.វ.ប.ន. ..... ២៣
តារាង ៤.២ សមាជិកនៃក្រុមប្រឹក្សាជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ..... ២៣

# បញ្ជីអក្សរកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| ASEAN | សមាគមនៃប្រជាជាតិអាស៊ីអាគ្នេយ៍ |
| AVI | វិទ្យាស្ថានចក្ខុវិស័យអាស៊ី |
| CDRI | វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា |
| CSDG | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (គ.អ.ច.ក.) |
| ESCAP | គណៈកម្មការសេដ្ឋកិច្ចនិងសង្គមប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក |
| FDI | ការវិនិយោគដោយផ្ទាល់ពីបរទេស |
| GDP | ផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) |
| ITC | វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា |
| JICA | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MISTI | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ និងនវានុវត្តន៍ |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MPTC | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| MSME | មីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យម |
| NIPTCT | វិទ្យាស្ថានជាតិប្រៃសណីយ៍ទូរគមនាគមន៍និងបច្ចេកវិទ្យាព័ត៌មានវិទ្យា |
| OECD | អង្គការសម្រាប់កិច្ចសហប្រតិបត្តិការនិងអភិវឌ្ឍន៍សេដ្ឋកិច្ច |
| R&D | ការស្រាវជ្រាវ និងអភិវឌ្ឍន៍ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| RS-IV | យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ |
| RUPP | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| SME Bank | ធនាគារសហគ្រាសធុនតូច និងមធ្យម |
| SMEs | សហគ្រាសធុនតូច និងមធ្យម |
| STEM | វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (ស្ទែម) |
| STI | វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (វ.ប.ន.) |
| TVET | បណ្តុះបណ្តាល និងអប់រំ វិជ្ជាជីវៈ (ធីវេត) |
| UICC | មជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការរវាងសាកលវិទ្យាល័យនិងវិស័យឧស្សាហកម្ម |
| UNESCO | អង្គការសហប្រជាជាតិសម្រាប់ការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ |

# ជំពូកទី ១

# បរិបទសេដ្ឋកិច្ចសង្គមកម្ពុជា

## ១.១ ទិដ្ឋភាពទូទៅ

ប្រទេសកម្ពុជាមានរាជធានី ខេត្តចំនួន ២៥ ដែលរាប់បញ្ចូលទាំងរាជធានីភ្នំពេញ និងមានចំនួនប្រជាជននិងស្ថានភាពសង្គមសេដ្ឋកិច្ចខុសគ្នាទៅតាមតំបន់។ ខេត្តនៅភូមិភាគខាងឦសាន ដូចជា រតនគីរី មណ្ឌលគីរី ព្រះវិហារ និងស្ទឹងត្រែង និងនៅភូមិភាគនិរតី ដូចជាកោះកុង គឺជាខេត្តដាច់ស្រយាលសម្បូរទៅដោយព្រៃឈើ ឬភ្នំ។ ប្រជាជនភាគច្រើនរស់នៅតាមដងទន្លេធំពីរ គឺទន្លេមេគង្គនិងទន្លេសាប។ ច្រករបៀងសេដ្ឋកិច្ចសំខាន់របស់ប្រទេសកម្ពុជារត់កាត់ពីតំបន់ចុងភាគអាគ្នេយ៍ទៅកាន់ព្រំដែនភាគខាងលិចជាប់នឹងប្រទេសថៃ។[1]

បន្ទាប់ពីទទួលបានឯករាជ្យនៅឆ្នាំ១៩៥៣ និងក្រោយមកត្រូវប្រឈមនឹងវិបត្តិនយោបាយ និងសេដ្ឋកិច្ចចាប់ពីទសវត្សរ៍ឆ្នាំ១៩៦០ រហូតដល់ទសវត្សរ៍ឆ្នាំ១៩៩០ កម្ពុជាបានចាប់ផ្ដើមកសាងឡើងវិញនូវសេដ្ឋកិច្ចរបស់ខ្លួនដោយផ្អែកជាចម្បងលើវិស័យកសិកម្ម រួមមាន នេសាទ រុក្ខាប្រមាញ់ និងធនធានធម្មជាតិផ្សេងទៀត (សូមមើលក្នុងប្រអប់១.១)។[2]

ប្រទេសកម្ពុជាបានក្លាយជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ក្នុងឆ្នាំ១៩៩៩។ កម្ពុជាជាប្រទេសតូច និងមានភាពជឿនលឿនខាងបច្ចេកវិទ្យាតិចតួច ធៀបនឹងបណ្ដាប្រទេសជាសមាជិកមួយចំនួនទៀត និងបានកំពុងប្រឹងប្រែងដេញតាមប្រទេសទាំងនោះ តាមរយៈកំណែទម្រង់ស្ថាប័ន និងបណ្ដុះបណ្ដាលធនធានមនុស្ស។ ទោះបីជាយ៉ាងណា កម្ពុជាទាញបានអត្ថប្រយោជន៍យ៉ាងច្រើនពីសមាជិកភាពនេះតាមរយៈប្លុកពាណិជ្ជកម្មរួមមួយដែលបានពង្រីកទិដ្ឋភាពសេដ្ឋកិច្ច និងបានផ្ដល់ជាខែលសន្តិសុខក្នុងតំបន់ពេលដែលមានការកើនឡើងនូវភាពតានតឹង និងជាឱកាសលើកស្ទួយវប្បធម៌កម្ពុជា។

ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះដែរ ប្រទេសកម្ពុជាបានបង្ហាញនូវសមិទ្ធកម្មសេដ្ឋកិច្ចដ៏ខ្លាំងក្លា និងវឌ្ឍនភាពគួរឱ្យកត់សម្គាល់នៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព និងមានវិសាលភាពកាន់តែទូលំទូលាយ។ ឧស្សាហកម្មថ្មីៗ ដូចជា វាយនភណ្ឌ និងទេសចរណ៍ កំពុងរីកចម្រើនជាមួយនឹងតំបន់វប្បធម៌ប្រវត្តិសាស្ត្រ ដែលត្រូវបានគេស្គាល់ទូទាំងពិភពលោក ដូចជាប្រាសាទអង្គរវត្តនិងខេត្តសៀមរាប។ ទន្ទឹមគ្នានេះ ប្រេង

---

[1] UNDP 2019

[2] នៅឆ្នាំ១៩៩១ មុខរបរនៅក្នុងវិស័យកសិកម្ម មានចំនួនដល់ទៅ ៧៨% ខណៈបានធ្លាក់ចុះមកត្រឹម ៣៤,៥%នៅឆ្នាំ២០១៩។ ប្រភព៖ World Bank Data. https://data.worldbank.org/country/cambodia.

កាតត្រូវបានរុករកឃើញកាលពីឆ្នាំ២០០៥ នៅក្នុងដែនសមុទ្រកម្ពុជា ហើយចាប់ផ្តើមទទួលដំណក់ប្រេងដំបូង នៅដើមឆ្នាំ២០២១។ វិស័យសេវាកម្មក៏ឃើញមានកំណើនប្រចាំឆ្នាំខ្លាំងក្លាផងដែរនាប៉ុន្មានឆ្នាំថ្មីៗនេះ។

កម្ពុជាបានរក្សាកំណើន ផ.ស.ស. ជាមធ្យមជាង ៧% ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ ដោយសារតែមានការគាំទ្រដោយគោលនយោបាយដែលអាចជានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងសេដ្ឋកិច្ចបើកចំហ។ ការណ៍នេះធ្វើឱ្យប្រាក់ចំណូលជាមធ្យមកើនឡើង អត្រានៃភាពក្រីក្រធ្លាក់ចុះយ៉ាងគំហុក ជាមួយនឹងអត្រាមានការងារធ្វើកើនឡើងខ្ពស់ និងបញ្ហាវិសមភាពបានធ្លាក់ចុះ។[3] ប្រាក់ចំណូលក្នុងស្រុកបានប៉ាន់ប្រមាណថានឹងកើនឡើងខ្ពស់ដល់ ២២,៣% នៃ ផ.ស.ស. នៅឆ្នាំ២០១៨ ដោយសារការគ្រប់គ្រងពន្ធបានប្រសើរជាងមុន។

### ប្រអប់ ១.១. សូចនាករសេដ្ឋកិច្ច-សង្គមកិច្ច របស់ប្រទេសកម្ពុជា

- ផ្ទៃដី៖ ១៨១ ០៣៥ គីឡូម៉ែត្រក្រឡា
- ចំនួនប្រជាជន៖ ១៥ ២៨៨ លាននាក់
- រាជធានី៖ ភ្នំពេញ
- ភាសាផ្លូវការ៖ ភាសាខ្មែរ
- ជនជាតិ៖ ខ្មែរ (៩០%) វៀតណាម ចាម និងឡាវ
- សាសនា៖ ព្រះពុទ្ធ (៩៧%), អ៊ីស្លាម (១,១%), គ្រិស្ត (០,៥%) សាសនាផ្សេងទៀត (០,៦%)
- ផ.ស.ស. ៖ ២៤,៥៤ ប៊ីលានដុល្លារអាមេរិក (២០១៨)
- ផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់៖ ១៥១០,៣២ ដុល្លារអាមេរិក (២០១៨)
- កំណើនសេដ្ឋកិច្ច៖ ៧,៥% (២០១៨/១៩) ។ យោងការព្យាករ៖ -២% នៅឆ្នាំ២០២០ ដោយសារផលប៉ះពាល់នៃវីរុសកូវីដ-១៩ និង មានកំណើន ៤% វិញ នៅឆ្នាំ២០២១*
- វិស័យឧស្សាហកម្មសំខាន់ៗ៖ កសិកម្ម កម្មន្តសាល (សម្លៀកបំពាក់ សម្ភារក្រៅពីសម្លៀកបំពាក់ និងស្បែកជើង) សំណង់ និងទេសចរណ៍
- ថវិការដ្ឋាភិបាលកម្ពុជា៖ -៥,១០% នៃផលិតផលក្នុងស្រុកសរុប (២០១៨)
- អត្រានិកម្មភាព (ភាគរយនៃកម្លាំងពលកម្មសរុប)៖ ១,០៥% (ឆ្នាំ ២០១៨)
- កម្លាំងពលកម្មក្នុងមុខរបរក្រៅផ្លូវការ/ងាយរងគ្រោះ៖ ៧០% (២០១៨)៨**

*កំណត់សម្គាល់*

***World Bank 2020, Cambodia Economic Update, November 2020: Restrained Recovery.**

****Government of Cambodia 2019, Decent Work Country Programme 2019–2023. Available at www.ilo.org/wcmsp5/groups/public/---ed_mas/---program/documents/genericdocument/wcms_711728.pdf.**

ជាមួយនឹងការវិនិយោគឥតឈប់ឈរពីវិស័យសាធារណៈនិងឯកជន សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករនៅមុនឆ្នាំ២០២០ ថា នឹងបន្តរីកលូតលាស់យ៉ាងខ្លាំងពីចំនួន ២៧,៧% នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៥ ទៅដល់ចំនួន

[3] Government of Cambodia 2019, p.3.

៣២,៨% ក្នុងឆ្នាំ២០១៨ និង ៣៨,២% ក្នុងឆ្នាំ២០២២ ខណៈបន្តមានការប្រែប្រួលរចនាសម្ព័ន្ធដែលបង្ក បរិយាកាសដល់ការអភិវឌ្ឍវិស័យឧស្សាហកម្ម។ យ៉ាងណាមិញ ការរាតត្បាតនៃជំងឺកូវីដ-១៩ បានធ្វើឱ្យប៉ះទង្គិចដល់សេដ្ឋកិច្ចពិភពលោក ដែលបង្កឱ្យសេដ្ឋកិច្ចកម្ពុជាជួបវិបត្តិយ៉ាងខ្លាំង ហើយមានការព្យាករថា កំណើនសេដ្ឋកិច្ចកម្ពុជាថយចុះដក ២% នៃ ផ.ស.ស. នៅឆ្នាំ២០២០។ ក៏ប៉ុន្តែ ធនាគារពិភពលោកបានព្យាករថា សេដ្ឋកិច្ចកម្ពុជានឹងទទួលបានកំណើន ៤% វិញនៅក្នុងឆ្នាំ២០២១ នេះ។ វិស័យកម្មន្តសាលដែលកំពុងឈានមុខគេ ដូចជា កាត់ដេរនិងស្បែកជើង នៅតែបន្តរីកចម្រើន និងជួយគាំទ្រដល់ការផ្លាស់ប្តូររចនាសម្ព័ន្ធជាវិជ្ជមាន ក៏ដូចជាការបង្កើនតម្លៃបន្ថែម។ គេក៏សង្កេតឃើញមានការធ្វើពិពិធកម្មមួយចំនួនលើមូលដ្ឋានឧស្សាហកម្មផងដែរ ជាពិសេសផ្នែកគ្រឿងបន្លាស់គ្រឿងយន្ត និងអេឡិចត្រូនិច។[4]

អត្រាប្រជាជនកម្ពុជាដែលរស់នៅក្រោមខ្សែបន្ទាត់នៃភាពក្រីក្រ[5]បានធ្លាក់ចុះជាមធ្យម ១% ក្នុងមួយឆ្នាំ ពោលគឺធ្លាក់មកត្រឹម ១៣% នៅឆ្នាំ២០១៨ បើធៀបនឹង ៤៨% នៅឆ្នាំ២០០៧។[6] ថ្វីបើកំណើនគួរឱ្យចាប់អារម្មណ៍នេះនៅតែបន្តមានក្តី ក៏អត្រានៃការកាត់បន្ថយភាពក្រីក្រក្នុងចន្លោះឆ្នាំ២០១៣ ដល់ឆ្នាំ២០១៧ គឺមានកម្រិតទាបជាងក្នុងចន្លោះឆ្នាំ២០០៩ ដល់ឆ្នាំ២០១៣។ នេះគឺអាចដោយសារតែផ្លែផ្កានៃសេដ្ឋកិច្ចផ្តល់ផលប្រយោជន៍ដល់អ្នកដែលនៅលើបន្ទាត់ក្រីក្រជាង ក្នុងខណៈដែលភាពក្រីក្រក្នុងទីប្រជុំជននៅទ្រឹង បើប្រៀបធៀបទៅក្នុងដំណាក់កាលដំបូង។ ភាពក្រីក្រគឺប្រមូលផ្តុំលើសលប់នៅតាមតំបន់ជនបទ ហើយគម្លាតហាក់កាន់តែរីកធំឡើង នេះអាចដោយសារតែឱកាសសេដ្ឋកិច្ចប្រមូលផ្តុំតែនៅក្នុងទីប្រជុំជន ដែលជាហេតុធ្វើឱ្យមានការធ្វើចំណាកស្រុកពីជនបទមកទីក្រុង ដែលអាចបណ្តាលឱ្យការរួមចំណែកនៃវិស័យកសិកម្មក្នុង ផ.ស.ស. មានការធ្លាក់ចុះ ។

បើទោះបីជាប្រទេសកម្ពុជានៅតែជួបប្រទះនឹងតម្រូវការមួយចំនួនក្តី ការទទួលបានហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានាត្រូវបានជានា និងអាចជាកត្តាដឹកនាំតម្រង់ទិសឱ្យមាននវានុវត្តន៍។ បច្ចុប្បន្ន ហេដ្ឋារចនាសម្ព័ន្ធផ្នែកអគ្គិសនីបានផ្គត់ផ្គង់តម្រូវការអគ្គិសនីទៅដល់ប្រមាណ ១២ ៣០៥ ភូមិ ដែលស្មើនឹង ៨៦,៨៥% នៃភូមិទាំងអស់ក្នុងប្រទេស។ នៅឆ្នាំ២០១៦ ១៨% នៃប្រជាជនកម្ពុជាពឹងផ្អែកជាចម្បងលើបច្ចេកវិទ្យា និងថាមពលស្អាតដែលមិនបានបង្កការបំពុលនៅតាមលំនៅដ្ឋាន។ ចំណែកថាមពលកកើតឡើងវិញ បើធៀបនឹងការប្រើប្រាស់ថាមពលសរុប នៅមិនទាន់មានសមាមាត្រនៅឡើយ។ ជាក់ស្តែង នៅឆ្នាំ២០០០ មានចំនួន ៨១,៤% ប៉ុន្តែបានធ្លាក់ចុះមក ៦៨,៥២% ក្នុងឆ្នាំ២០១០ ហើយធ្លាក់នៅត្រឹម ៦៤,៩២% ក្នុងឆ្នាំ២០១៥ ។ ទោះបីយ៉ាងណាក៏ដោយ បរិមាណអគ្គិសនីបានមកពីថាមពលកកើតឡើងវិញបានកើនឡើងក្នុងរយៈពេល ១៦ ឆ្នាំកន្លងមក ដោយមានថាមពលវារីអគ្គិសនីដែលជាប្រភពថាមពលកកើតឡើងវិញដ៏សំខាន់នៅក្នុងឆ្នាំ២០១៦។ ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍បានពង្រីកខ្លួនយ៉ាងរហ័សក្នុងពីរទសវត្សរ៍ចុងក្រោយ។ ការប្រើប្រាស់បច្ចេកវិទ្យាទំនាក់ទំនង និងព័ត៌មាន (ICT) បានកើនឡើងគួរឱ្យកត់សម្គាល់ ដូចដែលបានឆ្លុះបញ្ចាំងតាមរយៈចំនួនលេខទូរស័ព្ទចល័តបាន

---

[4] Government of Cambodia 2019.

[5] យោងតាមការកំណត់របស់ក្រសួងផែនការ (ឆ្នាំ២០១៣) ចំនួន ០,៩៥ ដុល្លារ ស្មើនឹង ៣,៨៧១ រៀល។

[6] See https://www.worldbank.org/en/country/cambodia/overview; See also Asian Development Bank data on poverty in Cambodia.

កើនពីចំនួន ២,៧ លាននាក់ក្នុងឆ្នាំ២០១២ ដល់ចំនួន ១០ លាននាក់ក្នុងឆ្នាំ២០១៧ នេះបើយោងតាមឯកសារយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤។

ការប្រើប្រាស់អ៊ីនធឺណិតនៅក្នុងប្រទេសមានការរីកលូតលាស់យ៉ាងឆាប់រហ័ស ដែលបច្ចុប្បន្ននេះគ្របដណ្តប់បានប្រមាណ ៩៨% នៃចំនួនប្រជាជនសរុប។ ស្រដៀងនេះដែរ គិតត្រឹមដើមឆ្នាំ២០២០ ចំនួនអ្នកប្រើប្រាស់សកម្មនៃបណ្តាញទំនាក់ទំនងសង្គម ហ្វេសប៊ុក (Facebook) មានប្រមាណ ៩,៧ លាននាក់ ដែលស្មើនឹង ៥៧% នៃប្រជាជនសរុប ពោលគឺកើន ៤០% ពីឆ្នាំ២០១៨។ មួយភាគធំនៃអាជីវកម្មតាមអនឡាញគឺប្រើប្រាស់ហ្វេសប៊ុក ។ ប្រទេសកម្ពុជាអាចនឹងពឹងផ្អែកលើអគ្គិសនីនិងឧបករណ៍ឌីជីថលមូលដ្ឋាន ដែលមានដ៏ទូលំទូលាយរបស់ខ្លួនដើម្បីគាំទ្រ និងទ្រទ្រង់នវានុវត្តន៍។

ជារួម ស្តែងចេញពីការរីកចម្រើនខាងសេដ្ឋកិច្ច រាជរដ្ឋាភិបាលកម្ពុជាបានកែសម្រួលនូវរដ្ឋបាលសារពើពន្ធឱ្យប្រសើរឡើង និងទទួលបានផលប្រយោជន៍ចេញពីការកើនឡើងនៃធនធានសាធារណៈ។ ការប្រមូលពន្ធផ្ទាល់និងពន្ធប្រយោល បានកើនឡើងគួរឱ្យកត់សម្គាល់នៅប៉ុន្មានឆ្នាំកន្លងមក ដែលមួយផ្នែកគឺកើតឡើងដោយសារការបង្កើនប្រសិទ្ធភាពរដ្ឋបាលចំណូល។ សេវាកម្មពន្ធអេឡិចត្រូនិក រួមមានការបង់ប្រាក់ពន្ធ ចុះឈ្មោះបញ្ជីពន្ធដារ និងអាករលើតម្លៃបន្ថែមតាមអេឡិចត្រូនិក ក៏ដូចជាការប្រើប្រាស់ប្រព័ន្ធធនាគារសម្រាប់ការបង់ពន្ធ ត្រូវបានដាក់ឱ្យដំណើរការ។[7] លើសពីនេះទៀត ដោយសារមានកំណើននៃការនាំចូល ការប្រមូលពន្ធពាណិជ្ជកម្មបានកើនឡើងក្នុងឆ្នាំ ២០១៩ ដែលរួមចំណែកដល់ ២,៤% នៃ ផ.ស.ស. ឬកើនឡើង ២០% ពីមួយឆ្នាំទៅមួយឆ្នាំ ពោលគឺកើនឡើងពី ២,២% ក្នុងឆ្នាំ២០១៧។ ពន្ធពាណិជ្ជកម្មកើនឡើង បើទោះបីជាមានការប្តេជ្ញាចិត្តនានានៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ានក៏ដោយចុះ។[8]

## ១.២. រចនាសម្ព័ន្ធតាមវិស័យនៃសេដ្ឋកិច្ចកម្ពុជា

### វិស័យកសិកម្មនៅតែជាប្រភពចម្បងនៃផលិតកម្ម និងការងារ

គោលនយោបាយដែលផ្តល់អាទិភាពលើឧស្សាហូនីយកម្ម និងទំនើបកម្មវិស័យសេដ្ឋកិច្ចបានធ្វើឱ្យចំណែកនៃវិស័យកសិកម្មក្នុង ផ.ស.ស. កាន់តែរួមតូច។ ការធ្វើចំណាកស្រុកជាច្រើនរបស់ពលករចូលទៅក្នុងវិស័យឧស្សាហកម្មនៅក្នុងទីប្រជុំជន និងក្រៅប្រទេស បានបន្តធ្វើឱ្យតុល្យភាពសេដ្ឋកិច្ចងាកចេញពីទីជនបទកាន់តែធំ។ ក៏ប៉ុន្តែវិស័យកសិកម្មនៅតែជាប្រភពដ៏សំខាន់នៃផលិតកម្មនិងការងារ។ ជាក់ស្តែង កម្ពុជាស្ថិតក្នុងចំណោមប្រទេសនាំចេញអង្ករច្រើនជាងគេទាំង ១០ នៅលើពិភពលោក ដោយបានបង្កើនការនាំចេញអង្ករទ្វេដងក្នុងអំឡុងឆ្នាំ ២០១៣-២០១៧។[9]

ក្នុងរយៈពេលមួយទសវត្សរ៍កន្លងទៅ មានការរីកចម្រើនលើគុណភាព និងយីហោ។ ដោយសារមានទីតាំងស្ថិតនៅជិតក្រុមប្រទេសនាំមុខក្នុងការផលិតទំនិញប្រើប្រាស់ ដូចជាម៉ាឡេស៊ី ថៃ និងវៀតណាម ប្រទេសកម្ពុជាបាននិងកំពុងខិតខំប្រឹងប្រែងជាយុទ្ធសាស្ត្រក្នុងការកែលម្អគុណភាព (ស្រូវ ម្រេច) បុព្វលាភចីរភាព

[7] World Bank 2019, p. 18.
[8] Ibid.
[9] Government of Cambodia.

«បៃតង» (sustainability premiums "green") និងបង្កើនសុវត្ថិភាពចំណីអាហារ "អនាម័យ" ហើយទន្ទឹមគ្នានេះធ្វើទំនើបកម្មការកែច្នៃកសិផល (គ្រាប់ស្វាយចន្ទី ម្សៅអាមីដុង)។ ក្នុងន័យនេះ អាជ្ញាធរបានណែនាំម៉ាកអង្ករ «ម្លិះអង្គរ» ក៏ដូចជា ផលិតផលសម្គាល់ភូមិសាស្ត្រ (GI) លើម្រេចកំពត និងកាហ្វេមណ្ឌលគីរី ជាដើម។ រោងចក្រកែច្នៃជំឡូងមីមួយចំនួនក៏កំពុងត្រូវបានសាងសង់។ ទោះយ៉ាងណា ការធ្វើពិពិធកម្មឆ្ពោះទៅរកការផលិតផលិតផលធ្វើពីសត្វ និងជលផលទទួលបានជោគជ័យតិចតួចនៅឡើយ ថ្វីបើមានតម្រូវការនិងតម្លៃកើនឡើងក៏ដោយ។ ការកើនឡើងចំណូល និងកំណើននៃនគរូបនីយកម្ម អមជាមួយនឹងការរីកលូតលាស់យ៉ាងឆាប់រហ័សនៃវិស័យទេសចរណ៍ដែលបច្ចុប្បន្នត្រូវបានអាក់ខានជាបណ្ដោះអាសន្នដោយសារកូវីដ-១៩ កំពុងផ្លាស់ប្តូររបបទទួលទានអាហារក្នុងគ្រួសារ ជាពិសេសទាក់ទងនឹងការប្រើប្រាស់ផលិតផលធ្វើពីសត្វ។ នេះក៏ជាការពិតទៅលើការនាំចេញផងដែរ ខណៈដែលចំនួនប្រជាជនវណ្ណៈកណ្ដាលនៅតំបន់អាស៊ី ជាពិសេសនៅក្នុងប្រទេសចិនកំពុងកើនឡើង។[10]

កាលពីខែកុម្ភៈឆ្នាំ២០១៩ នៅពេលដែលសហភាពអឺរ៉ុបបានអនុវត្តយ៉ាងពេញលេញនូវវិធានការការពារពាណិជ្ជកម្ម ការនាំចេញអង្ករទៅកាន់សហភាពអឺរ៉ុបបានធ្លាក់ចុះចំនួន ៥៧,៨% សម្រាប់រយៈពេលដូចគ្នាប្រៀបទៅខែមុនៗ។ ផ្ទុយទៅវិញ ការនាំអង្ករចេញរបស់កម្ពុជាទៅកាន់ទីផ្សារចិនបានកើនឡើងដល់ទៅចំនួន ៤៥,៦%។ ជាលទ្ធផល ការនាំចេញអង្កររបស់កម្ពុជាគ្រប់គ្រងបាននូវកំណើន ២% ក្នុងរយៈពេល ២ ខែដំបូងនៃឆ្នាំ ២០១៩។ ទិន្នន័យផ្លូវការបង្ហាញថា កម្ពុជាទទួលបានប្រាក់ចំណូលពីការនាំចេញអង្ករចំនួន ៤១៣,៥ លានដុល្លារក្នុងឆ្នាំ២០១៨។[11]

## សារសំខាន់កាន់ខ្លាំងឡើងនៃវិស័យឧស្សាហកម្ម និងកម្មន្តសាល

ការរួមចំណែកនៃវិស័យឧស្សាហកម្មនៅក្នុង ផ.ស.ស. បានកើនឡើងពីចំនួន ២៧,៧% ក្នុងឆ្នាំ២០១៥ ដល់ចំនួន ៣២,៨% ហើយបានប្រើប្រាស់កម្លាំងពលកម្មចំនួន ២៣,៩% គិតត្រឹមឆ្នាំ ២០១៨ និង ២៣,៨% នៅឆ្នាំ ២០១៧ នៃកម្លាំងពលកម្មសរុប ពោលគឺលើសពីគោលដៅកំណត់របស់រាជរដ្ឋាភិបាល។ ទោះយ៉ាងណា វិស័យកម្មន្តសាលបានកើនឡើងពី ១៦,០% នៃ ផ.ស.ស. ក្នុងឆ្នាំ ២០១៥ ដល់ត្រឹមតែ ១៦,៨% ក្នុងឆ្នាំ ២០១៨ នេះបង្ហាញពីការរីកចម្រើនយឺតយ៉ាវនៃមូលដ្ឋានឧស្សាហកម្មស្ដួលមួយនេះ។[12] វិស័យសំណង់គឺជាវិស័យដែលមានថាមវន្តជាងគេបំផុត ដែលបានកើនឡើងប្រមាណពី ៩,៨% ក្នុងឆ្នាំ២០១៥ ដល់ប្រមាណ ១៣,៧% ក្នុងឆ្នាំ២០១៨[13]។

ការវិនិយោគរបស់រាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន បានបន្តផ្តោតលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ជាពិសេស ផ្លូវថ្នល់ ផ្លូវដែក ស្ពាន កំពង់ផែ វារីអគ្គិសនី កសិដ្ឋានថាមពលពន្លឺព្រះអាទិត្យ ខ្សែបណ្ដាញបញ្ជូនថាមពល និងប្រព័ន្ធធារាសាស្ត្រ។ ការណ៍នេះអាចបណ្ដាលឱ្យក្នុងកម្រិតណាមួយដល់រោងចក្រកាត់ដេរមួយចំនួនក្នុងការផ្លាស់ប្តូរទីតាំងពីរាជធានីទៅជនបទ ដែលកាន់តែកៀកជិតប្រភពកម្លាំងពលកម្ម និងសម្រាលបន្ទុកមួយចំនួនលើហេដ្ឋារចនាសម្ព័ន្ធនៅទីប្រជុំជន។ រាជរដ្ឋាភិបាលកម្ពុជា បានកសាង

---

10 World Bank 2019, p. 13-14.
11 Ibid.
12 Government of Cambodia 2019, P.51
13 Government of Cambodia 2019, P.50

គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម (២០១៥-២០២៥) ដោយបានដាក់ចេញវិធានការលម្អិតប្រមាណជា ១០០ ចំណុច ដើម្បីឆ្លើយតបលើបញ្ហាអាទិភាពជាច្រើន រួមបញ្ចូលពីបញ្ហាការអភិវឌ្ឍជំនាញ បច្ចេកវិទ្យា ហិរញ្ញប្បទាន កិច្ចសម្រួលពាណិជ្ជកម្ម និងការវិនិយោគ។ ប្រទេសកម្ពុជានៅតែបន្តទទួលបាននូវការវិនិយោគផ្ទាល់ពីបរទេសយ៉ាងច្រើនសន្ធឹកសន្ធាប់ ដែលមួយរយៈចុងក្រោយនេះផ្តោតខ្លាំងការអភិវឌ្ឍវិស័យអចលនទ្រព្យ និងទេសចរណ៍។ ឧស្សាហកម្មសំណង់និងហេដ្ឋារចនាសម្ព័ន្ធគឺជាវិស័យដែលទទួលផលមុនគេពីការវិនិយោគផ្ទាល់ពីបរទេស បន្ទាប់មកគឺវិស័យវាយនភណ្ឌ កសិកម្ម និងទេសចរណ៍។[14]

ទោះបីយ៉ាងណាក៏ដោយ ប្រទេសកម្ពុជានៅតែប្រឈមនឹងបញ្ហាជាមួយតម្លៃកស្តុភាកម្មខ្ពស់ ការសម្របសម្រួលស្ថាប័ននៅមានភាពទន់ខ្សោយ កង្វះខាតហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាព និងមានភាពស៊ីចង្វាក់គ្នាដែលធ្វើឱ្យផលិតករមិនអាចចូលទៅកាន់ទីផ្សារ ហើយសហគ្រាសពិបាកក្នុងការជ្រើសរើសទីតាំង។ ភាពទន់ខ្សោយនៃផ្នែកថាមពល ការអភិវឌ្ឍជំនាញ និងបច្ចេកវិទ្យា រួមទាំងបច្ចេកវិទ្យាឌីជីថល បានរាំងស្ទះដល់ការលូតលាស់នៃអនុវិស័យកម្មន្តសាល ព្រមទាំងកង្វះសមត្ថភាពក្នុងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម។[15]

មូលដ្ឋានឧស្សាហកម្មរបស់ប្រទេសកម្ពុជានៅតែតូចចង្អៀត និងល្បាយមិនស្មើគ្នា ដោយសកម្មភាពភាគច្រើនប្រមូលផ្តុំតែនៅលើផលិតកម្មសម្លៀកបំពាក់ និងការកែច្នៃម្ហូបអាហារ។ ជាក់ស្តែង មូលដ្ឋានឧស្សាហកម្មមានលក្ខណៈប្រហោងកណ្តាល (Missing Middle)។ នៅកម្ពុជា ភាគរយសហគ្រាសធុនធំមានតិចតួច តែ ០,៦% ប៉ុណ្ណោះ ប៉ុន្តែតំណាងឱ្យផលរបរ (Turnover) របស់កម្ពុជារហូតដល់ ៧៦% និងស្រូបយកអាត្រាពលកម្ម ៦៣% ខណៈមីក្រូសហគ្រាសដែលមានចំនួនច្រើនបំផុតរហូតដល់ ៩៧% តំណាងឱ្យតែ ១២% នៃផលរបរ និងស្រូបកម្លាំងពលកម្មបានតែ ៣០%។[16] សហគ្រាសឧស្សាហកម្មធុនធំប្រមាណ ៨០% ផលិតសម្លៀកបំពាក់ វាយនភណ្ឌ និងស្បែកជើង ដែលក្នុងនោះច្រើនជាង ៦៣% គឺការវិនិយោគផ្ទាល់ពីបរទេស និងផ្តោតលើការនាំចេញ។[17] ប្រាក់ចំណូលពីការនាំចេញរបស់កម្ពុជា ភាគច្រើនបានមកពីវិស័យវាយនភណ្ឌ ពោលគឺជិត ៦៨% នៃការនាំចេញសរុប។[18] ផ្ទុយទៅវិញ មីក្រូសហគ្រាសនិងសហគ្រាសធុនតូចស្ទើរតែទាំងអស់គឺមានប្រជាជនក្នុងស្រុកជាម្ចាស់កម្មសិទ្ធិ។[19]

អាជីវកម្មក្រៅផ្លូវការនៅក្នុងប្រទេសកម្ពុជាគឺមានចំនួនយ៉ាងច្រើន។ តាមការប៉ាន់ប្រមាណ វិស័យក្រៅផ្លូវការមានចំនួនយ៉ាងច្រើនរហូតដល់ចំនួន ៩៨,៦% នៃមីក្រូសហគ្រាស ចំនួន ៦២,៨% នៃសហគ្រាសធុនតូច ចំនួន ២៨,៦% នៃសហគ្រាសធុនមធ្យម និងចំនួន ៧,០ % នៃសហគ្រាសធុនធំ។[20] ក្នុងនោះដែរ ចំនួនសហគ្រាសធុនមធ្យម និងក្រុមហ៊ុនធំៗ ដែលបានចុះបញ្ជីជាផ្លូវការ នៅមានកម្រិតនៅឡើយ ហើយបានរួមចំណែកមួយភាគធំដល់ប្រាក់ចំណូលជាតិតាមរយៈការបង់ពន្ធ។ បញ្ហានេះគឺបណ្តាលមកពីមីក្រូសហគ្រាស

14 https://santandertrade.com/en/portal/establish-overseas/cambodia/investing-3?
15 Government of Cambodia 2019, P.66.
16 Ministry of Industry and Handicraft 2016.
17 Ibid
18 World Bank 2016a.
19 OECD 2018, p. 58.
20 Mininistry of Industry and Handicraft 2016.

មានចំនួនច្រើនលើសលុបនៅក្នុងផ្នែកអាជីវកម្មក្នុងប្រទេស។ គួរឱ្យកត់សម្គាល់ផងដែរ ស្ត្រីកម្ពុជាប្រមាណជា ៤៥% គឺប្រកបអាជីវកម្មផ្ទាល់ខ្លួន នៅក្នុងវិស័យក្រៅផ្លូវការ។[21]

## វិស័យសេវាកម្មដែលកំពុងលេចចេញជារូបរាង និងរីកចម្រើន

វិស័យសេវាកម្មក៏មានកំណើនប្រចាំឆ្នាំខ្លាំងក្លាផងដែរ ជាពិសេសតាមរយៈសមិទ្ធកម្មកាន់តែប្រសើរឡើងក្នុងវិស័យពាណិជ្ជកម្មក្នុងស្រុក និងការដឹកជញ្ជូន។ វិស័យទេសចរណ៍ ការលក់រាយ/លក់ដុំ និងវិស័យអចលនទ្រព្យដែលជាប្រភពសំខាន់នៃការបង្កើតការងារ ក៏ដូចជាប្រភពនៃទិន្នផលនៅក្នុងសេដ្ឋកិច្ច កំពុងតែមានសន្ទុះនៃការលូតលាស់ខ្លាំងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ។[22]

សេវាកម្មហិរញ្ញវត្ថុ និងវិស័យធនាគារបាននិងកំពុងរីកលូតលាស់យ៉ាងខ្លាំងនៅប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ និងកាន់តែរឹងមាំឡើងចាប់តាំងពីឆ្នាំ២០១៦ ខណៈដែលកំណើននៃការផ្តល់ប្រាក់កម្ចីត្រូវបានស្ថិតក្នុងការគ្រប់គ្រង។ ថ្មីៗនេះ ក៏មានការរីកចម្រើនក្រៃលែងផងដែរនៅក្នុងវិស័យសំណង់និងអចលនទ្រព្យ។ ជាឧទាហរណ៍ នៅឆ្នាំ ២០១៨ គម្រោងអភិវឌ្ឍន៍លំនៅដ្ឋាន និងពាណិជ្ជកម្មដែលត្រូវបានអនុម័ត ដោយមិនរាប់បញ្ចូលគម្រោងធំៗចាប់ពីមួយប៊ីលានដុល្លារឡើងទៅ មានចំនួន ៤,៦ ប៊ីលានដុល្លារ ពោលគឺបានកើនឡើងចំនួន ១៤% ពីឆ្នាំ ២០១៧។ ទោះបីជាយ៉ាងណា កំណើននៅក្នុងវិស័យទាំងនេះទំនងជាមិនស្ថិតស្ថិរទេ ដោយសារតែលក្ខណៈប្រថុយប្រថានរបស់អាជីវកម្មក្នុងវិស័យទាំងនោះ។[23]

ថ្មីៗនេះដែរ ឥណទានក្នុងស្រុកលើវិស័យសេវាកម្មហាក់បីជាមានការកើនឡើង ក្នុងនោះរួមមាន ការលក់ដុំ ដឹកជញ្ជូន ទូរគមនាគមន៍ និងការប្រើប្រាស់ផ្ទាល់ខ្លួនជាដើម។ និន្នាការនេះបង្ហាញពីការកើនឡើងនៅក្នុងតម្រូវការនៃការប្រើប្រាស់ និងការសាងសង់ ដែលបានជំរុញឱ្យអាជីវកម្មលក់ដុំធំៗបង្កើនការផ្តល់សេវាកម្មឱ្យសមស្របទៅតាមតម្រូវការ។ នេះគូសបញ្ជាក់តាមរយៈការនាំចូលទំនិញប្រើប្រាស់បានយូរដូចជា យានយន្ត និងសម្ភារសំណង់។

ផ្ទុយទៅវិញ ឥណទានក្នុងស្រុកសម្រាប់វិស័យកសិកម្ម កម្មន្តសាល ឬសេវាកម្មលក់រាយ រួមទាំងវិស័យម្ហូបអាហារ មានការរួមតូច។[24]

ប្រាក់កម្ចីសរុបដែលជាហិរញ្ញប្បទានផ្តល់ដោយវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ បានកើនឡើងជាង ១០០% នៃ ផ.ស.ស. ឬស្មើនឹង ១០៤,២ ទ្រីលានរៀលក្នុងឆ្នាំ២០១៨ ក្នុងនោះ ៨០% ត្រូវបានផ្តល់ដោយវិស័យធនាគារ និង ២០% ទៀតដោយវិស័យមីក្រូហិរញ្ញវត្ថុ។ នេះមិនទាន់រាប់បញ្ចូលឥណទានដែលត្រូវបានផ្តល់ដោយប្រព័ន្ធ "ធនាគារស្រមោល" (shadow banking) ដែលត្រូវបានប្រើប្រាស់ដោយក្រុមហ៊ុនអភិវឌ្ឍន៍អចលនទ្រព្យ ក្រុមហ៊ុនជួល និងហាងបញ្ចាំ និងអ្នកផ្តល់ប្រាក់កម្ចីក្រៅផ្លូវការជាដើម។ ដូច្នេះហើយ ចំនួនឥណទានសរុបជាក់ស្តែងមានទំហំច្រើនជាងនេះទៀត។[25]

បើទោះបីជាមានការរីកចម្រើនក្នុងវិស័យនេះក៏ដោយ ពិតណាស់ក៏តម្រូវការសេវាកម្មហិរញ្ញវត្ថុនៅតែមានដដែល។ តួយ៉ាង ប្រជាជនចំនួន ៧៨% ពុំបានប្រើប្រាស់គណនីធនាគារ ខណៈប្រជាជនចំនួន ៣%

[21] Mininistry of Industry and Handicraft 2016; OECD 2018, p. 58.
[22] Ibid.
23 World Bank 2019.
[24] (WB, 2019) Cambodia economic update, p17
[25] Ibid

ប៉ុណ្ណោះមានប័ណ្ណឥណទាន និង ១៣% ទៀតប្រើប្រាស់ទម្រង់ទូទាត់តាមទូរស័ព្ទ។ កំណើននៃការប្រើប្រាស់ថ្នាលនិងផលិតផលបច្ចេកវិទ្យាហិរញ្ញវត្ថុ (Fintech) ដែលបង្វែរការប្រើប្រាស់ប្រព័ន្ធធនាគារតាមបែបប្រពៃណីអាចជាដំណោះស្រាយលោតផ្លោះ «Leapfrog» នៅក្នុងទីផ្សារប្រទេសកម្ពុជា។[26]

កំណើននៃភ្ញៀវទេសចរអន្តរជាតិរក្សាអត្រាប្រមាណ ១០,៧% ក្នុងឆ្នាំ២០១៨ ដែលទាបជាង ១១,៨% ក្នុងឆ្នាំ២០១៧ ដោយសារកំណើននៃចំនួនភ្ញៀវទេសចរចិន។ ក៏ប៉ុន្តែ កំណើននេះត្រូវបានធ្លាក់ចុះយ៉ាងគំហុកទៅវិញ ក្រោយពីមានការផ្ទុះឡើងនៃកូវីដ-១៩ ដែលធ្វើឱ្យកម្ពុជាទទួលបានភ្ញៀវទេសចរបរទេសតែ ១,២៦ លាននាក់ក្នុងរយៈពេល ១០ ខែដំបូង នៃឆ្នាំ២០២០ ពោលគឺបានធ្លាក់ចុះចំនួន ៧៦% បើប្រៀបទៅឆ្នាំ២០១៩ នេះបើយោងទៅតាមក្រសួងទេសចរណ៍។[27]

គំនិតផ្តួចផ្តើមមួយចំនួនត្រូវបានដាក់ចេញក្នុងគោលដៅបង្កើន និងលើកកម្ពស់វិស័យសេវាកម្មទេសចរណ៍ ដូចជា «**រមណីយដ្ឋានស្អាត ទីក្រុងស្អាត សេវាកម្មល្អ» ស្តង់ដារអាហារតាមដងផ្លូវ ទីសាធារណៈដែលមានសេវាអ៊ីនធឺណិតឥតគិតថ្លៃ គំនិតផ្តួចផ្តើមខ្សែក្រវាត់បៃតងនិងទីក្រុងឆ្លាតវៃ** ជាដើម។ ក៏ប៉ុន្តែ ការវិនិយោគបន្ថែមទៀតក្នុងគោលដៅកសាងហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍សាធារណៈឱ្យបានគ្រប់គ្រាន់និងមានដំណើរការល្អ ក៏ដូចជាការកែលម្អកិច្ចសហប្រតិបត្តិការរវាងស្ថាប័នសាធារណៈ និងវិស័យពាណិជ្ជកម្មគឺជាកិច្ចការចាំបាច់ដែលត្រូវធ្វើ។[28]

---

[26] Kem et al. 2019, p.8.
[27] See www.phnompenhpost.com/national/foreign-tourist-arrivals-down-761-ministry.
[28] World Bank 2019, p. 12.

# ជំពូកទី ២

# មហិច្ឆតាកម្ពុជាឆ្នាំ ២០៣០ និង ២០៥០

## ២.១ យុទ្ធសាស្ត្រជាតិ

### យុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

ប្រកបដោយចីរភាព។ រាជរដ្ឋាភិបាលកម្ពុជាបានបញ្ជ្រាបសសរស្តម្ភទាំងបីនេះចូលទៅក្នុងផែនការយុទ្ធសាស្ត្រទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ។ នៅថ្នាក់ជាតិ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ ដែលបានដាក់ចេញនៅឆ្នាំ២០១៨ កំណត់យ៉ាងជាក់លាក់នូវចតុកោណគោលនយោបាយចំនួន៤ រួមមាន (១) ការអភិវឌ្ឍ ធនធានមនុស្ស (២) ការធ្វើពិពិធកម្មសេដ្ឋកិច្ច (៣) ការអភិវឌ្ឍវិស័យឯកជន និងការងារ (៤) ការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន។ យុទ្ធសាស្ត្រចតុកោណត្រូវបានបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ជាតិឆ្នាំ២០១៩-២០២៣ ដើម្បីធ្វើផែនការតាមវិស័យ ក៏ដូចជាការរៀបចំគម្រោងថវិកា។

ផែនការអភិវឌ្ឍន៍ ៥ ឆ្នាំ និងកម្មវិធីវិនិយោគ ៣ ឆ្នាំរំកិលថ្នាក់រាជធានីខេត្ត ត្រូវបានកសាងឡើងដើម្បីគាំទ្រយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ និងត្រូវបានអនុម័តដាក់ឱ្យប្រើប្រាស់ដោយក្រុមប្រឹក្សារាជធានីខេត្ត។

### ចក្ខុវិស័យឆ្នាំ២០៥០៖ ឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា

រាជរដ្ឋាភិបាលបានបោះជំហានសំខាន់ៗមួយចំនួនដើម្បីជំរុញការអភិវឌ្ឍប្រកបដោយចីរភាព។ ចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ មានមហិច្ឆតាកសាងកម្ពុជាឱ្យក្លាយទៅជាប្រទេសដែលមិនត្រឹមតែមានវិបុលភាពប៉ុណ្ណោះទេ ប៉ុន្តែត្រូវមានបរិយាប័ន្នសង្គម និងចីរភាពបរិស្ថាន តាមរយៈការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (គ.អ.ច.ក.) ត្រឹមឆ្នាំ២០៥០។ គ.អ.ច.ក. គឺឯកសារគោលនយោបាយដែលត្រូវបានបង្កើតឡើងដោយផ្អែកលើ «គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០» (គ.អ.ច.) និងការដាក់បញ្ចូលគោលដៅមួយទៀតរបស់កម្ពុជាពាក់ព័ន្ធនឹងការបោសសម្អាតមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ។ គ.អ.ច.ក. ត្រូវបានគាំទ្រដោយគោលដៅចំនួន ៨៨ និងសូចនាករចំនួន ១៤៨ ហើយឯកសារនេះប្រើប្រាស់សំណុំទិន្នន័យក្នុងស្រុក និងអភិក្រមគោលនយោបាយជាតិជាគោល។

គ.អ.ច.ក. ត្រូវបានធ្វើសមាហរកម្មចូលទៅក្នុងផែនការ និងគោលនយោបាយជាតិ តាមរយៈការបញ្ចូលទៅក្នុងក្របខ័ណ្ឌត្រួតពិនិត្យ និងវាយតម្លៃនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដែលសូចនាករប្រមាណ ៤០% ត្រូវបានអនុម័ត។ លើសពីនេះទៀត រាជរដ្ឋាភិបាលកម្ពុជាមានគោលបំណងប្រើប្រាស់សូចនាករប្រកបដោយ

នវានុវត្តន៍នៅក្នុង គ.អ.ច.ក. ដើម្បីវាស់វែងសមិទ្ធកម្មនៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួងនិងស្ថាប័ននានា ដែលការណ៍នេះបានទាក់ទាញចំណាប់អារម្មណ៍ពីមជ្ឈដ្ឋានអន្តរជាតិ។[29]

បើទោះជាយ៉ាងណា មានបញ្ហាប្រឈមជាច្រើនដែលត្រូវដោះស្រាយ។ ដើម្បីទទួលជោគជ័យនៅក្នុងកិច្ចការនេះ គេត្រូវការជាចាំបាច់នូវអភិក្រមដែលផ្អែកលើទឡ្ហីករណ៍សម្រាប់ជួយគាំទ្រការអភិវឌ្ឍប្រកបដោយចីរភាព។ មានអាទិភាពធំៗចំនួន ៣ ដែលត្រូវដោះស្រាយ៖ (១) បង្កបរិយាកាសការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពតាមរយៈការពង្រឹងប្រភពទិន្នន័យដែលគួរជឿទុកចិត្ត និងផ្អែកលើទឡ្ហីករណ៍ (២) កសាងសមត្ថភាពគ្រប់គ្រងដ៏ម៉ត់ចត់និងអនុវត្តកំណែទម្រង់អភិបាលកិច្ចដើម្បីគាំទ្រដល់ការសម្រេចឱ្យបានលទ្ធផល ៣)និងការផ្តល់ហិរញ្ញប្បទានដល់ គ.អ.ច.ក.។ ទាក់ទិននឹងអាទិភាពទី ៣ នេះដែរ ចាំបាច់រួមមាន ការស្វែងរកធនធានថ្មីៗដើម្បីគាំទ្រ គ.អ.ច.ក. ព្រមទាំងតភ្ជាប់បណ្តាញតួអង្គមិនមែនរដ្ឋឱ្យចូលរួមគាំទ្រ ដោយសារតែជំនួយអភិវឌ្ឍន៍ផ្លូវការនិងប្រភពធនធានប្រពៃណីផ្សេងៗទៀតកំពុងធ្លាក់ចុះ។

## ២.២. យុទ្ធសាស្ត្រតាមវិស័យ

នៅឆ្នាំ២០១៥ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម (ឆ្នាំ ២០១៥-២០២៥) ដោយបានដាក់ចេញវិធានការលម្អិតប្រមាណជា ១០០ ចំណុចសម្រាប់ដោះស្រាយវិស័យអាទិភាពជាច្រើន ដូចជា ការអភិវឌ្ឍជំនាញ បច្ចេកវិទ្យា ហិរញ្ញវត្ថុ និងការសម្រួលពាណិជ្ជកម្ម និងការវិនិយោគ ជាដើម។ រាជរដ្ឋាភិបាលកម្ពុជាមានចក្ខុវិស័យជំរុញកែប្រែ និងធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មនៅកម្ពុជា ពីឧស្សាហកម្មអតិពលកម្ម ឈានទៅឧស្សាហកម្មផ្អែកលើជំនាញត្រឹមឆ្នាំ២០២៥ តាមរយៈការតភ្ជាប់ទៅនឹងខ្សែច្រវ៉ាក់តម្លៃសកល សមាហរណកម្មទៅក្នុងបណ្តាញផលិតកម្មតំបន់ និងការអភិវឌ្ឍកន្សោមផលិតកម្មប្រទាក់ប្រឡា ទន្ទឹមនឹងការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាពឧស្សាហកម្មក្នុងស្រុក ហើយបន្តឈានទៅអភិវឌ្ឍឧស្សាហកម្មទំនើបដែលផ្អែកជាសំខាន់លើមូលដ្ឋានបច្ចេកវិទ្យា និងចំណេះដឹង។ ការសម្រេចជោគជ័យនូវចក្ខុវិស័យមួយនេះនឹងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ កំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាពនិងបរិយាប័ន្ន ការបង្កើតការងារ ការបង្កើនតម្លៃបន្ថែមនៅក្នុងវិស័យសេដ្ឋកិច្ច និងការកើនប្រាក់ចំណូលដល់ប្រជាជនកម្ពុជា។

ថ្មីៗនេះ នៅក្នុងខែមីនា ឆ្នាំ២០១៩ នៅក្នុង «វេទិការាជរដ្ឋាភិបាល និងវិស័យឯកជន» **សម្តេចតេជោនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញវិធានការកំណែទម្រង់ជាកញ្ចប់ដែលមាន ១៧ ចំណុចក្នុងគោលដៅកែលម្អភាពប្រកួតប្រជែងរបស់កម្ពុជា លើកកម្ពស់សហគ្រាសធុនតូចនិងមធ្យម និងទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស។ វិធានការទាំងនេះរាប់ចាប់តាំងពីការកាត់បន្ថយថ្លៃភស្តុភាកម្ម រហូតដល់ការបញ្ចុះតម្លៃអគ្គិសនី ការកែលម្អច្បាប់ការងារ ការបង្កើនលទ្ធភាពទទួលបានហិរញ្ញប្បទានដល់សហគ្រាសធុនតូចនិងមធ្យម ការបញ្ចប់វិសោធនកម្មច្បាប់ស្តីពីការវិនិយោគ និងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស ជាដើម។ កម្ពុជាមានតំបន់សេដ្ឋកិច្ចពិសេសប្រហែល ៣០ កន្លែង ដែលអាជីវកម្មទាំងឡាយទទួលបានលក្ខខណ្ឌអំណោយ

---

[29] Government of Cambodia 2019.

ផលសម្រាប់ប្រតិបត្តិការ។ តំបន់សេដ្ឋកិច្ចពិសេសមានគោលបំណងជួយជំរុញដល់ការអភិវឌ្ឍបណ្ដុំឧស្សាហកម្ម និងជាលទ្ធផល បង្កើតឱកាសការងារថ្មីនិងមានគុណភាពជាងមុនសម្រាប់ប្រជាជនក្នុងស្រុក។

ដើម្បីជួយគាំទ្រសហគ្រាសធុនតូចនិងមធ្យម នៅដើមឆ្នាំ២០២០ ក្រសួង ឧ.វ.ប.ន. បានប្រកាសឱ្យប្រើផែនការអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យមរយៈពេល ៥ ឆ្នាំ ដោយបានផ្សារភ្ជាប់ការងារនាពេលបច្ចុប្បន្នជាមួយផែនការអភិវឌ្ឍន៍វិស័យឧស្សាហកម្ម និងផែនការសកម្មភាពយុទ្ធសាស្ត្រអាស៊ានស្ដីពីការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម (SAP-SMED) ឆ្នាំ២០១៦-២០២៥ ដែលជួយលើកកម្ពស់មីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យមនៅក្នុងតំបន់ជាលក្ខណៈតាមប្រទេសនីមួយៗ និងជាសមូហភាព។

មូលនិធិអភិវឌ្ឍន៍ជំនាញ (SDF) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៨ ដើម្បីកាត់បន្ថយគម្លាតពាក់ព័ន្ធនឹងជំនាញនៅក្នុងសេដ្ឋកិច្ចកម្ពុជា និងផ្ដោតលើវិស័យអាទិភាពចំនួន ៥ រួមមាន កម្មន្តសាល សំណង់ បច្ចេកវិទ្យាទំនាក់ទំនងនិងព័ត៌មាន អេឡិចត្រូនិក និងទេសចរណ៍។ ក្នុងឆ្នាំដដែលនោះដែរ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញអនុក្រឹត្យផ្ដល់ការលើកលែងពន្ធរយៈពេល ៥ ឆ្នាំ ដល់សហគ្រាសធុនតូច និងមធ្យម។ លើសពីនេះទៅទៀត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបង្កើតធនាគារសហគ្រាសធុនតូចនិងមធ្យម និងមូលនិធិអភិវឌ្ឍន៍សហគ្រិនភាព ក៏ដូចជាមជ្ឈមណ្ឌលលើកកម្ពស់សហគ្រិនភាព និងដាក់ឱ្យដំណើរការចាប់តាំងពីដើមឆ្នាំ២០២០។

រាជរដ្ឋាភិបាលក៏កំពុងពិនិត្យឡើងវិញនូវច្បាប់ស្ដីពីការវិនិយោគ ដែលអាចនឹងត្រូវអនុម័តនៅឆ្នាំ២០២១ ក្នុងគោលបំណងបង្កើនភាពប្រកួតប្រជែង ធ្វើទំនើបកម្ម និងបង្កើនផលិតភាពឧស្សាហកម្មក្នុងស្រុក តាមរយៈការធ្វើសមាហរណកម្មឱ្យកាន់តែទូលំទូលាយចូលទៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងតំបន់ និងពិភពលោក។ ច្បាប់នេះក៏មានគោលបំណងបង្កើតរបបលើកទឹកចិត្តការវិនិយោគដែលមានតម្លាភាព អាចព្យាករបាន មិនរើសអើង និងមានការប្រកួតប្រជែង សំដៅគាំទ្រដល់គោលនយោបាយសេដ្ឋកិច្ចសង្គម ព្រមទាំងការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់វិនិយោគិននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ដោយមានផែនការអភិវឌ្ឍន៍វិស័យឧស្សាហកម្ម និងយុទ្ធសាស្ត្រផ្សេងៗទៀតស្រាប់ រាជរដ្ឋាភិបាលបានសហប្រតិបត្តិការគ្នាជាមួយដៃគូអន្តរជាតិជាច្រើនដើម្បីរួមគ្នាអនុវត្តកម្មវិធី និងគម្រោងផ្សេងៗ ជាពិសេស កម្មវិធីភាពជាដៃគូប្រចាំប្រទេស (PCP) ឆ្នាំ២០១៨-២០២៣ ជាមួយអង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍន៍ឧស្សាហកម្ម (UNIDO) កិច្ចសហប្រតិបត្តិការជាមួយទីភ្នាក់ងារកម្មសិទ្ធិបញ្ញាផ្សេងៗ គណៈកម្មាធិការពិគ្រោះយោបល់អាស៊ានស្ដីពីស្តង់ដារ និងគុណភាព (ACCSQ) និងជាមួយ គណៈកម្មាធិការជាតិសម្រាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍(ASEAN-COSTI)។

នៅចុងឆ្នាំ២០១៧ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបង្កើតអង្គភាព «ភាពជាដៃគូរវាងរដ្ឋនិងឯកជន» (PPP Unit) ដែលមានគោលបំណងជំរុញអនុវត្តគម្រោងដែលទទួលបានហិរញ្ញប្បទានភាគច្រើនពីក្រុមហ៊ុនឯកជន។ គេរំពឹងថា កិច្ចសន្យាអាចត្រូវបានរៀបចំឡើងរវាងស្ថាប័នរដ្ឋាភិបាល (ក្រសួង/ស្ថាប័នពាក់ព័ន្ធ) និងដៃគូឯកជនក្នុងការរចនា សាងសង់ និងប្រតិបត្តិការ ព្រមទាំងការរក្សាគម្រោងវិនិយោគ រួមទាំងគម្រោងសាងសង់-ប្រតិបត្តិការ-ផ្ទេរ (B-O-T) និងគម្រោងសម្បទាននានា។

ចំពោះផ្នែកឌីជីថលដែលស្ថិតនៅក្រោមការដឹកនាំរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រាជរដ្ឋាភិបាលបានអនុម័ត ច្បាប់ស្ដីពីទូរគមនាគមន៍ គោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ឆ្នាំ២០២០ និងផែនការមេបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ឆ្នាំ២០២០។ ច្បាប់ស្ដីពី

ទូរគមនាគមន៍ មានគោលបំណងធានាឱ្យមានប្រសិទ្ធភាពលើការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធនិងបណ្ដាញ ព្រមទាំងការផ្ដល់សេវាកម្មទូរគមនាគមន៍ប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព គុណភាព អាចជឿទុកចិត្តបាន និងមានតម្លៃសមរម្យ។ ច្បាប់នេះក៏លើកទឹកចិត្តឱ្យមានការចូលរួមរបស់វិស័យឯកជននៅក្នុងការអភិវឌ្ឍវិស័យនេះ ធានាឱ្យមាននូវការប្រកួតប្រជែងដោយយុត្តិធម៌ និងការពារអ្នកប្រើប្រាស់។ គោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ឆ្នាំ២០២០ បានដាក់ចេញជាវិធានការ និងកិច្ចអន្តរាគមន៍ជាក់លាក់នានា ដើម្បីឈានទៅអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ សមត្ថភាពធនធានមនុស្ស សន្តិសុខអ៊ីនធឺណិត សេវាកម្មអេឡិចត្រូនិក និងឧស្សាហកម្ម ICT។

ផែនការមេ ICT ឆ្នាំ២០២០ មានយុទ្ធសាស្ត្រផ្អែកលើមូលដ្ឋានចម្បងចំនួនបួន រួមមាន៖

១. «ការបង្កើនសក្ដានុពលធនធានមនុស្ស» រួមមាន ការអភិវឌ្ឍធនធានមនុស្សផ្នែក ICT និងការលើកកម្ពស់ការយល់ដឹងតាមអេឡិចត្រូនិក។

២. «ការធានាការតភ្ជាប់» រួមមាន ៣ វិស័យ ដូចជា ហេដ្ឋារចនាសម្ព័ន្ធ ICT ថ្នាក់ជាតិ ក្របខ័ណ្ឌគតិយុត្ត និងសន្តិសុខអ៊ីនធឺណិត។

៣. «ការពង្រឹងសមត្ថភាព» រួមមាន ៣ វិស័យ ដូចជា ឧស្សាហកម្ម ICT ស្តង់ដារ ICT និងការស្រាវជ្រាវនិងអភិវឌ្ឍន៍។

៤. «ការបង្កើនសេវាកម្មអេឡិចត្រូនិក» រួមមាន សេវាកម្មរដ្ឋាភិបាលអេឡិចត្រូនិក សេវាកម្មសាធារណៈអេឡិចត្រូនិក និងសេវាកម្មអប់រំអេឡិចត្រូនិក។

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានធ្វើកំណែទម្រង់របបអាជ្ញាប័ណ្ណទូរគមនាគមន៍ ពីការផ្ដល់អាជ្ញាប័ណ្ណតែមួយ ទៅជាការផ្ដល់អាជ្ញាប័ណ្ណរួម (ពហុសេវាកម្ម) ព្រមទាំងបានបង្កើត «មូលនិធិកាតព្វកិច្ចសេវាសកលទូរគមនាគមន៍» ដែលមានទំហំ ២% នៃចំណូលសរុបរបស់ទូរគមនាគមន៍ និង «មូលនិធិកសាងសមត្ថភាព និងការស្រាវជ្រាវនិងអភិវឌ្ឍន៍» ដែលមានទំហំ ១% នៃចំណូលសរុបរបស់ទូរគមនាគមន៍។ មជ្ឈមណ្ឌលនវានុវត្តន៍ ICT និងមជ្ឈមណ្ឌលបណ្ដុះធុរកិច្ចថ្មីឌីជីថល កំពុងត្រូវបានសាងសង់ឡើងដើម្បីពន្លឿនការអភិវឌ្ឍមូលធនមនុស្សរបស់ប្រទេស ជំរុញការស្រាវជ្រាវនិងនវានុវត្តន៍ និងបង្កើនបរិមាណធុរកិច្ចនៅក្នុងវិស័យឌីជីថល។ មជ្ឈមណ្ឌលនេះត្រូវបានផ្ដល់ហិរញ្ញប្បទានដោយ «មូលនិធិកសាងសមត្ថភាព និងការស្រាវជ្រាវនិងអភិវឌ្ឍន៍» ។

បច្ចុប្បន្ន ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍កំពុងតាក់តែង និងរៀបចំឯកសារមួយចំនួនដូចខាងក្រោម៖

- ផែនការមេ និងក្របខ័ណ្ឌគោលនយោបាយឌីជីថល ក្នុងគោលបំណងកសាងរដ្ឋាភិបាលមួយដែលរឹងមាំ ឆ្លាតវៃ និងស្អាតស្អំ ដោយផ្អែកលើការអភិវឌ្ឍនិងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។ សេចក្ដីព្រាងក្របខ័ណ្ឌគោលនយោបាយរដ្ឋាភិបាលឌីជីថល ដាក់ចេញ៖

- គោលការណ៍ ៣ ចំណុច៖ គោលការណ៍ឆ្លងម្តងប៉ុណ្ណោះ[30] (Once-Only Principle) គោលការណ៍អន្តរប្រតិបត្តិការជាប្រព័ន្ធអេកូឡូស៊ី[31] (Interoperationality as an Ecoystem) និងគោលការណ៍យុទ្ធសាស្ត្រចាប់ និងពង្រីក[32] (Land and Expand Strategy) ដើម្បីទទួលបានប្រសិទ្ធភាព។
- វិធានការគោលនយោបាយ ៤ ចំណុច៖ (១)ការធ្វើឌីជីថលូបនីយកម្មសេវាសាធារណៈ (២) កត្តាបង្កជាគន្លឹះផ្សេងៗ ជាអាទិ៍៖ ហេដ្ឋារចនាសម្ព័ន្ធឌីជីថល ច្បាប់ ឧស្សាហកម្ម និងការស្រាវជ្រាវនិងអភិវឌ្ឍន៍ (៣) អភិបាលកិច្ចផ្តោតលើទិន្នន័យ និង (៤) ក្របខ័ណ្ឌនិងយន្តការសន្តិសុខ។
- ក្របខ័ណ្ឌអភិបាលកិច្ច៖ ការរៀបចំស្ថាប័ន ភាពជាអ្នកដឹកនាំ និងការកសាងសមត្ថភាព និងយន្តការសម្រាប់ការផ្តល់មូលនិធិនិងលទ្ធកម្ម។

• អនុក្រឹត្យស្តីពីការប្រែក្លាយ វិទ្យាស្ថានជាតិប្រៃសណីយ៍ទូរគមនាគមន៍និងបច្ចេកវិទ្យាព័ត៌មានវិទ្យាឱ្យទៅជា បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា ដែលមានវិទ្យាស្ថានចំនួន ៣ រួមមាន៖ (១) វិទ្យាស្ថានជាតិបច្ចេកវិទ្យាឌីជីថល ដែលមានជំនាញវិស្វកម្មឌីជីថល ធុរកិច្ចឌីជីថល និងនិងមជ្ឈមណ្ឌលអប់រំ (២) វិទ្យាស្ថានជាតិអភិបាលកិច្ចឌីជីថល ដែលមានជំនាញអភិបាលកិច្ចឌីជីថល និងការបណ្តុះបណ្តាលមន្ត្រីរាជរដ្ឋាភិបាល និង (៣) វិទ្យាស្ថានជាតិស្រាវជ្រាវនិងនវានុវត្តន៍ឌីជីថល ដែលមានជំនាញបញ្ញាសិប្បនិម្មិត អ៊ីនធឺណិតនៃវត្ថុ ក្លោដកុំព្យូធីង បច្ចេកវិទ្យាប្លុកឆេន វិទ្យាសាស្ត្រទិន្នន័យ និងគោលនយោបាយឌីជីថល និងនវានុវត្តន៍។

ដើម្បីឈានទៅសម្រេចបានគោលដៅទី ៤ នៃ គ.អ.ច.ក. ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតនិងអនុម័ត «ផែនទីបង្ហាញផ្លូវឧត្តមសិក្សាកម្ពុជាឆ្នាំ២០៣០» ដែលឯកសារនេះផ្តល់ជាក្របខ័ណ្ឌរួមសម្រាប់អភិក្រមគ្របដណ្តប់លើវិស័យរួមក្នុងរយៈពេលវែង សំដៅការអភិវឌ្ឍនិងផ្តល់សេវាកម្មអប់រំ ហើយផែនទីនេះក៏បានដាក់ចេញជាអាទិភាព និងយុទ្ធសាស្ត្រដើម្បីឈានទៅសម្រេចបានគោលដៅទាំងនេះ។ ការលើកកម្ពស់ចំណេះដឹង ជំនាញវិជ្ជាជីវៈ សហគ្រិនភាព ការច្នៃប្រឌិត នវានុវត្តន៍ និងសុខុមាលភាព គឺជាសមាសធាតុស្នូលនៅក្នុងចតុកោណទី ១ នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤។ គោលដៅទី ៤ នៃ គ.អ.ច.ក. គឺសម្របទៅនឹងអាទិភាពនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤។ មុំទី ១ នៃចតុកោណទី ១ គឺការពង្រឹងគុណភាពនៃវិស័យអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាក្នុងគោលបំណងទទួលបាន «ប្រព័ន្ធអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាប័ន្ន»។ មុំទី ២ គឺ ការបណ្តុះបណ្តាលជំនាញបច្ចេកទេស ក្នុងគោលបំណងធានាថា «យុវជនម្នាក់មាន

---

[30] ពលរដ្ឋ ស្ថាប័ន និងក្រុមហ៊ុន គ្រាន់តែផ្តល់ព័ត៌មានតាមស្តង់ដាច្បាស់លាស់ទៅកាន់អាជ្ញាធរ និងរដ្ឋបាលក្នុងពេលតែម្តងជាការស្រេច។
[31] បង្កើនសមត្ថភាពក្នុងការផ្ទេរ និងប្តូរទិន្នន័យសំខាន់ៗ ក៏ដូចជាព័ត៌មានផ្សេងនៅក្នុងប្រព័ន្ធ និងកម្មវិធី (applications)ជាដើម។
[32] អ្នកប្រើប្រាស់ "Land" ជាមួយនឹងកម្មវិធីតូច (applications) រួចហើយ "ពង្រីក" ទៅដល់ផលិតផល និងសេវាកម្មបន្ថែមទៀត។

ជំនាញមួយយ៉ាងតិចប្រចាំជីវិត»។ មុំទី ៤ ផ្ដោតលើការពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គម ដើម្បីលើកស្ទួយស្ថានភាពសង្គម-សេដ្ឋកិច្ច និងពង្រឹងតួនាទីរបស់ស្ត្រី។

ក្រសួងអប់រំ យុវជន និងកីឡា បានបញ្ចូលមុខវិជ្ជា វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (ស្ទែម) ទៅក្នុងផែនទីបង្ហាញផ្លូវនេះ ព្រមទាំងបានកំណត់សូចនាករជាក់លាក់មួយចំនួនដើម្បីត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការអប់រំស្ទែម។

ដោយផ្អែកលើយុទ្ធសាស្ត្រ និងគោលនយោបាយស្ដីពី ICT ក្រសួងអប់រំ យុវជន និងកីឡាបានបោះពុម្ពផ្សាយ ផែនការមេ ICT ក្នុងវិស័យអប់រំឆ្នាំ២០០៩-២០១៣។ បច្ចុប្បន្ន គេកំពុងពិនិត្យមើលសមិទ្ធផលរបស់ផែនការមេនេះ ខណៈដែលផែនការមេបន្ទាប់កំពុងត្រូវបានរៀបចំបង្កើត។[33] នៅឆ្នាំ២០១៥ ក្រសួងអប់រំ យុវជន និងកីឡា បានបោះពុម្ពផ្សាយក្របខ័ណ្ឌកម្មវិធីសិក្សាចំណេះដឹងទូទៅនិងការអប់រំបច្ចេកទេស ដើម្បីណែនាំអ្នកពាក់ព័ន្ធឱ្យរៀបចំបង្កើតឯកសារពាក់ព័ន្ធ និងសំខាន់ៗ ដូចជា សៀវភៅសិក្សាសម្រាប់សិស្ស សៀវភៅកិច្ចតែងការបង្រៀននិងរៀន គោលការណ៍ណែនាំវិធីសាស្ត្របង្រៀននិងរៀន ព្រមទាំងសូចនាករនៃលទ្ធផលសិក្សារបស់សិស្ស។ ក្រៅពីនេះ ក្របខ័ណ្ឌកម្មវិធីសិក្សាក៏បានបញ្ចូលមុខវិជ្ជាថ្មីៗពាក់ព័ន្ធនឹង ICT ទៅក្នុងកម្មវិធីសិក្សាចាប់ពីថ្នាក់ទី ៤ ដល់ទី ១២ និងណែនាំអំពីការធ្វើទំនើបកម្មវិធីសាស្ត្របង្រៀននៅគ្រប់កម្រិតអប់រំ។[34]

ដើម្បីដោះស្រាយបញ្ហាហេដ្ឋារចនាសម្ព័ន្ធ ICT ក្នុងវិស័យអប់រំ នៅឆ្នាំ២០១៦ ក្រសួងអប់រំ យុវជន និងកីឡាបានបោះពុម្ពផ្សាយ គោលនយោបាយសាលាជំនាន់ថ្មី ដើម្បីណែនាំដល់អ្នកអប់រំនិងសិស្សានុសិស្សឱ្យយល់កាន់តែច្បាស់អំពីវិធីសាស្ត្រថ្មីៗនៃការសិក្សា ពង្រឹងនវានុវត្តន៍អប់រំនៅក្នុងប្រព័ន្ធសាលារៀន ព្រមទាំងផ្ដល់សិទ្ធិអំណាចដល់ប្រព័ន្ធអប់រំសំដៅបង្កើតសមត្ថភាពប្រកួតប្រជែងនៅក្នុងតំបន់អាស៊ាន ដែលកំពុងតែត្រូវការបន្ទាន់នូវកម្លាំងពលកម្មដែលមានជំនាញសតវត្សរ៍ទី២១។ យោងតាមគោលនយោបាយអភិវឌ្ឍន៍ ICT ឆ្នាំ២០២០ រាជរដ្ឋាភិបាលក៏មានគោលដៅអភិវឌ្ឍធនធានមនុស្សផ្នែក ICT តាមរយៈការបង្កើនភាគរយនៃសិស្សបញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិដែលមានជំនាញ ICT ជាមូលដ្ឋាន និងភាគរយនៃធនធានមនុស្សដែលមានជំនាញវិជ្ជាជីវៈ ICT ។[35]

ចំពោះវិស័យអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ (ជីវេត) ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ កំពុងតែអនុវត្ត ក្របខ័ណ្ឌគោលនយោបាយជាតិស្ដីពីការបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥ ក្របខ័ណ្ឌគុណវុឌ្ឍិកម្ពុជា ស្តង់ដារគុណសម្បទាជាតិ និងកម្មវិធីសិក្សាផ្អែកលើគុណសម្បទា។ ដោយមានគោលដៅស្របគ្នានៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ ក្រសួងកំពុងផ្ដោតការងារលើ (១) ការកែលម្អគុណភាពគ្រឹះស្ថានជីវេត ដូចជាបណ្ដុះបណ្ដាលគ្រូបង្រៀន ការទទួលស្គាល់គុណភាព ការបង្កើតកម្មវិធីសិក្សា និងឧបករណ៍សម្ភារ (២)លើកកម្ពស់ភាពទាក់ទាញនៃកម្មវិធីបណ្ដុះបណ្ដាលជីវេត ដល់សិស្សានុសិស្ស និងក្រុមគ្រួសារ (៣) ពង្រឹងកិច្ចសហការរវាងវិស័យសាធារណៈនិងឯកជននៅក្នុងជីវេត (៤) ធ្វើឱ្យប្រសើរឡើងនូវអភិបាលកិច្ចគ្រឹះស្ថានជីវេត និង (៥) ការអភិវឌ្ឍសហគ្រិនភាពនិងវប្បធម៌នវានុវត្តន៍នៅតាមគ្រឹះស្ថានជីវេត។

---

[33] Konrad-Adenauer-Stiftung Cambodia 2019, p. 31.
[34] Ibid.
[35] Ibid.

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្មឆ្នាំ២០២០-២០២៥ ដើម្បីពន្លឿនការអភិវឌ្ឍវិស័យកសិកម្ម ក្នុងនោះរួមមាន ការបង្កើនផលិតភាពកសិកម្ម ការធ្វើពិពិធកម្ម និងពាណិជ្ជូបនីយកម្ម ការលើកកម្ពស់ការចិញ្ចឹមសត្វ និងវារីវប្បកម្ម កំណែទម្រង់ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព។[36] ការណ៍នេះបង្ហាញពីកិច្ចខិតខំប្រឹងប្រែងដែលត្រូវធ្វើ នៅក្នុងវិស័យបច្ចេកវិទ្យា ការអប់រំ និងផ្នែកស្រាវជ្រាវ។

## ២.៣ តួនាទីរបស់នវានុវត្តន៍ដើម្បីសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០

វ.ប.ន. ត្រូវបានគេទទួលស្គាល់ជាទូទៅថាជាក្បាលម៉ាស៊ីនដឹកនាំទៅការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ប្រទេសកម្ពុជាក៏បានទទួលស្គាល់តួនាទីដ៏សំខាន់នៃនវានុវត្តន៍ដើម្បីឈានទៅសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ ក៏ដូចជាចក្ខុវិស័យឆ្នាំ២០៥០ ផងដែរ។

ចក្ខុវិស័យវែងឆ្ងាយកម្ពុជាឆ្នាំ២០៥០ មានគោលដៅលើកកម្ពស់ការអភិវឌ្ឍវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ព្រមទាំងនវានុវត្តន៍ ដោយផ្តោតលើ៖

- ពង្រឹងមូលដ្ឋានគ្រឹះ រួមមាន៖
  - ការធ្វើស្ថាប័នីយកម្មវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាថ្នាក់ជាតិ និងក្របខ័ណ្ឌច្បាប់
  - បណ្តុះធនធានមនុស្សលើវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និង
  - ការធ្វើប្រព័ន្ធនីយកម្មការគាំទ្រហិរញ្ញវត្ថុលើវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។
- ការបង្កើតបរិយាកាសអំណោយផលដល់វិស័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាដែលចាំបាច់ដើម្បីធានាដល់ការស្រាវជ្រាវនិងការអភិវឌ្ឍ ប្រកបដោយប្រសិទ្ធភាព
  - ការលើកកម្ពស់ការយល់ដឹង និងគាំទ្រជាសាធារណៈ
  - ការលើកកម្ពស់ប្រព័ន្ធព័ត៌មានក្នុងវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និង
  - ការបង្កើតប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ។

ចក្ខុវិស័យឆ្នាំ២០៥០ នឹងទទួលបានការគាំទ្រ តាមរយៈការអនុវត្តគោលនយោបាយជាតិស្តីពី វ.ប.ន. ឆ្នាំ២០២០-២០៣០ ដែលត្រូវបានអនុម័តនៅឆ្នាំ២០១៩។ គោលនយោបាយ វ.ប.ន. នឹងជួយពង្រឹងមូលដ្ឋានគ្រឹះ វ.ប.ន. កសាងសមត្ថភាពជាតិលើវិស័យ វ.ប.ន. សំដៅបង្កើតបាននូវបច្ចេកវិទ្យាដែលមានសក្តានុពលសម្រាប់ការអភិវឌ្ឍ ពង្រឹងសមត្ថភាពនវានុវត្តន៍ក្នុងការឆ្លើយតបទៅនឹងតម្រូវការមូលដ្ឋានរបស់ប្រទេស លើកកម្ពស់គុណភាពនៃជីវិតជូនប្រជាជន បង្កើនទ្រព្យសម្បត្តិជាតិ អភិវឌ្ឍមូលដ្ឋានគ្រឹះឧស្សាហកម្មថ្នាក់ជាតិដែលមានភាពប្រកួតប្រជែង ក៏ដូចជាកែលម្អអភិបាលកិច្ចក្នុងវិស័យ វ.ប.ន.។

---

[36] Government of Cambodia 2019, P. 51.

ឯកសារគោលនយោបាយណែនាំដ៏ចម្បងក្នុងរយៈពេលវែងទាំងពីរនេះ បង្ហាញពីរបៀបវារៈកំណែទម្រង់ជុំវិញវិស័យ វ.ប.ន.នៅក្នុងប្រទេសកម្ពុជា និងជាឧបករណ៍មូលដ្ឋានសម្រាប់ជំរុញទៅមុខនូវការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ទៅកាន់ដំណាក់ថ្មីមួយដែលប្រកបដោយចីរភាព។ ឯកសារគោលនយោបាយទាំងនេះមានគោលបំណងសម្រេចឱ្យបាននូវរបៀបវារៈអភិវឌ្ឍន៍ជាតិ។

លើសពីនេះទៀត រាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមបញ្ជ្រាបវិស័យបច្ចេកវិទ្យា បន្ថែមពីលើបញ្ហាយេនឌ័រ និងការសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ ចូលទៅក្នុងគម្រោងអភិវឌ្ឍន៍ដែលផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍។

## ២.៤ បច្ចេកវិទ្យាដែលជាអាទិភាព

គោលនយោបាយជាតិស្តីពី វ.ប.ន. ឆ្នាំ២០២០-២០៣០ ដែលបានអនុម័តដោយ **សម្តេចតេជោនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** កាលពីខែធ្នូ ឆ្នាំ២០១៩ ផ្តោតសំខាន់លើដែនវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាចំនួន ៥៖

- ការបង្កើនទិន្នផលកសិកម្ម ពិពិធកម្មផលិតផល និងការកែច្នៃកសិផល
- ផលិតកម្ម និងវិស្វកម្មទំនើប
- សុខាភិបាល និងជីវវេជ្ជសាស្ត្រ
- វិទ្យាសាស្ត្រ និងវិស្វកម្មរូបធាតុ
- សេវាកម្ម និងសេដ្ឋកិច្ចឌីជីថល រួមមាន បញ្ញាសិប្បនិម្មិត បច្ចេកវិទ្យាលំហនិងអវកាស។

ដែនទាំង ៥ នេះគឺដើរស្របទិសគ្នានឹងគោលដៅគន្លឹះនៃវិស័យសេដ្ឋកិច្ចដែលផ្តល់អាទិភាពនៅក្នុងផែនការអភិវឌ្ឍន៍វិស័យឧស្សាហកម្ម។

ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍជាតិ និងដើម្បីជំរុញកំណើនសេដ្ឋកិច្ចជាតិស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាបានធ្វើការសិក្សាអង្កេតមួយដើម្បីកំណត់ពីបច្ចេកវិទ្យាដែលជាអាទិភាពរបស់ជាតិ។ ជាលទ្ធផល បច្ចេកវិទ្យាដែលជាអាទិភាពចំនួន ១០ ត្រូវបានផ្តល់ជាអានុសាសន៍ ដើម្បីជួយបង្កើនភាពប្រកួតប្រជែងនៅក្នុងវិស័យសេដ្ឋកិច្ចរបស់កម្ពុជា។[37]

បច្ចេកវិទ្យាដែលមានកម្រិតអាទិភាពបំផុតចំនួន ៣៖

- ការកែច្នៃផលិតផលកសិកម្មជាអាទិភាពចម្បងបំផុត
- បច្ចេកវិទ្យាកម្មវិធីសូហ្វែរនិងមាតិកាឌីជីថល
- ជីវបច្ចេកវិទ្យា។

បច្ចេកវិទ្យាដែលមានកម្រិតអាទិភាពបន្ថែមចំនួន ២៖

- បច្ចេកវិទ្យាវិស្វកម្មកសិកម្ម
- បច្ចេកវិទ្យាអេឡិចត្រូនិកនិងអគ្គិសនី

---

[37] General Secretariat of the National Science and Technology Council 2019.

បច្ចេកវិទ្យាចំនួន ៥ ផ្សេងទៀតគួរតែត្រូវកំណត់យកសម្រាប់រយៈពេលវែងដូចជា

- បរិក្ខារលំនៅដ្ឋាន
- ថាមពលកកើតឡើងវិញ
- បច្ចេកវិទ្យាវេជ្ជសាស្ត្រនិងសុខាភិបាល
- បច្ចេកវិទ្យាទេសចរណ៍ និង
- បច្ចេកវិទ្យានៃការរចនាសម្ភារ។

# ជំពូកទី ៣ ប្រព័ន្ធនវានុវត្តន៍ជាតិ

## ៣.១ ក្របខ័ណ្ឌទស្សនទាន

ក្របខ័ណ្ឌទស្សនទាននៃប្រព័ន្ធនវានុវត្តន៍ជាតិ (NIS) អាចជួយដល់អ្នកតាក់តែងគោលនយោបាយក្នុង

ការកំណត់កិច្ចអន្តរាគមន៍ដែលមានលក្ខណៈជាប្រព័ន្ធ ដើម្បីលើកកម្ពស់នវានុវត្តន៍។ បច្ចុប្បន្ន ទស្សនទាននៃ "ប្រព័ន្ធនវានុវត្តន៍ជាតិ"[38] ត្រូវបានគេយកទៅប្រើប្រាស់ជាទូទៅ ជាពិសេសបណ្ដារដ្ឋាភិបាល ស្ថាប័នហិរញ្ញវត្ថុ និងអង្គការអភិវឌ្ឍន៍អន្តរជាតិនានា រួមមាន អង្គការសម្រាប់កិច្ចសហប្រតិបត្តិការនិងអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD) អង្គការសហប្រជាជាតិ និងធនាគារពិភពលោកជាដើម ដើម្បីពិនិត្យវិនិច្ឆ័យពីការកើតឡើង ឬការលើកកម្ពស់វិស័យ វ.ប.ន. នៅក្នុងស្ថាប័ន។ ខុសពី ទស្សនទានមុននៃ "គំរូលីនេអ៊ែរនៃនវានុវត្តន៍" ដែលយល់ថាការស្រាវជ្រាវអាចនាំទៅរកនវានុវត្តន៍ ទស្សនទាននៃ "ប្រព័ន្ធនវានុវត្តន៍ជាតិ" វិញ ចាត់ទុកនវានុវត្តន៍ថាជាផលិតផលរួមដែលកើតចេញពីបណ្ដាញនៃតួអង្គផ្សេងៗ ហើយអាចកើតមានពីគ្រប់ទីកន្លែងនៅក្នុងប្រព័ន្ធនវានុវត្តន៍ តាមរយៈសកម្មភាពរបស់មជ្ឈមណ្ឌលស្រាវជ្រាវ ធុរកិច្ច រដ្ឋាភិបាល ជាដើម។ ការស្រាវជ្រាវអាចជួយបំពេញនូវសេចក្ដីត្រូវការ ហើយការស្រាវជ្រាវនេះទៀតសោតក៏អាចត្រូវបានផ្ដួចផ្ដើមបន្ទាប់ពីការកំណត់បាននូវតម្រូវការផងដែរ។ ការស្រាវជ្រាវប្រភេទនេះកើតឡើងជាពិសេសនៅក្នុងអង្គភាពដែល មាន "សមត្ថភាពស្រូបយក"[39]ពោលគឺជាសមត្ថភាពក្នុងការកំណត់ពីបញ្ហាវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ស្វែងរក និងប្រើប្រាស់ដំណោះស្រាយទាំងនោះទៅក្នុងឱកាសធុរកិច្ច។

រូបភាពទី ៣.១ បង្ហាញអំពីសមាសធាតុសំខាន់ៗនៃប្រព័ន្ធនវានុវត្តន៍ជាតិ ដែលរួមមាន ប្រព័ន្ធស្រាវជ្រាវនិងឧត្តមសិក្សា ប្រព័ន្ធផលិតកម្ម តំណភ្ជាប់រវាងប្រព័ន្ធទាំងពីរ លក្ខខណ្ឌបរិបទផ្សេងទៀតរួមមាន តម្រូវការហេដ្ឋារចនាសម្ព័ន្ធនវានុវត្តន៍ និងលក្ខខណ្ឌនៃក្របខ័ណ្ឌ ព្រមទាំងរដ្ឋាភិបាល និងអភិបាលកិច្ចជារួម។

---

[38] Freeman 1987; Lundvall 1992; Nelson 1993.
[39] Cohen and Levinthal 1990.

ការអាស្រ័យគ្នានៃសមាសធាតុផ្សេងៗគ្នាបញ្ជាក់ថា ប្រព័ន្ធនវានុវត្តន៍មួយដែលដំណើរការបានល្អគឺតម្រូវឱ្យរាល់ប្រព័ន្ធរងមានដំណើរការប្រកបដោយប្រសិទ្ធផល និងប្រសិទ្ធភាពក្នុងកម្រិតដែលសមរម្យ ហើយតំណភ្ជាប់រវាងសមាសធាតុផ្សេងៗក៏ចាំបាច់ត្រូវមានដំណើរការល្អដែរ ព្រោះថានវានុវត្តន៍ភាគច្រើនកើតចេញពីការបង្កើតរួមគ្នា។ ដូច្នេះ គេត្រូវរៀបចំកសាងគោលនយោបាយចម្រុះមួយដែលអាចឈានទៅសម្រេចគោលដៅនេះ ហើយក៏មានការរក្សាតុល្យភាពរវាងសមាសធាតុផ្សេងៗគ្នាផងដែរ។ ជាឧទាហរណ៍ គេគួរតែធានាឱ្យមានភាពបន្សីគ្នារវាងការផ្គត់ផ្គង់និងតម្រូវការសម្រាប់និស្សិតបញ្ចប់ការសិក្សា បណ្ឌិត និងអ្នកស្រាវជ្រាវ។ ទន្ទឹមគ្នានេះ អាទិភាពនៃការស្រាវជ្រាវតាមវិស័យនៅថ្នាក់ជាតិ គួរតែមានសង្គតិភាពគ្នាជាមួយតម្រូវការរបស់រាជរដ្ឋាភិបាល និងឧស្សាហកម្ម។ ដើម្បីសម្រេចគោលដៅនេះ គេគួរតែមាន «រង្គភូមិ» គោលនយោបាយជាតិ តួយ៉ាង ក្រុមប្រឹក្សាស្រាវជ្រាវ និងនវានុវត្តគោលនយោបាយ ដើម្បីពិនិត្យតាមដានប្រព័ន្ធនវានុវត្តន៍ជាតិ និងផ្តល់ជាអនុសាសន៍ ក៏ដូចជាការសម្របសម្រួលជូនរដ្ឋាភិបាល។[40]

## រូបភាព ៣.១ ក្របខ័ណ្ឌនៃប្រព័ន្ធនវានុវត្តន៍ជាតិ




ប្រភព៖ S. Kuhlmann and E. Arnold, 2001, RCN in the Norwegian Research and Innovation System, Background Report No. 12 in the Evaluation of the Research Council of Norway. Oslo: Royal Norwegian Ministry of Education, Research and Church Affairs.

[40] Schwaag-Serger et al. 2015.

ដោយសារតែផ្នែកផ្សេងៗគ្នានៃប្រព័ន្ធនវានុវត្តន៍ជាតិធ្វើការជាមួយគ្នា ពួកគេមានទំនោរសហវិវឌ្ឍន៍ទៅជាលំនាំជាក់លាក់មួយ។ ដូច្នេះ គោលនយោបាយចាំបាច់ត្រូវរៀបចំតាក់តែងឡើងសម្រាប់បរិបទជាតិជាក់ស្តែង ពោលគឺមិនអាចចម្លងដោយផ្ទាល់ពីបរទេសបានឡើយ។

យោងតាមការស្រាវជ្រាវរបស់ធនាគារពិភពលោក[41] កម្រិតដ៏ទាបនៃការទទួលយកបច្ចេកវិទ្យានៅតាមប្រទេសកំពុងអភិវឌ្ឍន៍ គឺជាការឆ្លើយតបសមហេតុផលរបស់បណ្តាក្រុមហ៊ុនចំពោះស្ថានភាពដែលប្រឈម រួមមាន ឧបសគ្គក្នុងការកៀរគរមូលធនរូបវន្តនិងមូលធនមនុស្ស សមត្ថភាពក្រុមហ៊ុននៅមានកម្រិតទាប និងសមត្ថភាពរដ្ឋាភិបាលនៅទន់ខ្សោយ។ លទ្ធផលស្រាវជ្រាវរបស់របស់ធនាគារពិភពលោកបានបង្ហាញពីតម្រូវការចាំបាច់ដែលរដ្ឋត្រូវអនុវត្តកម្មវិធីប្រកបដោយមហិច្ឆតា ដើម្បីកសាងប្រព័ន្ធនវានុវត្តន៍ជាតិ និងដើម្បីបង្កើនសមត្ថភាពក្នុងការតាក់តែងគោលនយោបាយ ក៏ដូចជាសមត្ថភាពក្នុងការអនុវត្តគោលនយោបាយស្រាវជ្រាវ និងនវានុវត្តន៍តាមរយៈអង្គភាពថ្មី។

ប្រព័ន្ធនវានុវត្តន៍ដែលដំណើរការយ៉ាងល្អ ត្រូវអនុវត្តមុខងារមួយចំនួន ដូចជា លើកទឹកចិត្តសកម្មភាពសហគ្រិនភាព ព្រមទាំងការអភិវឌ្ឍ និងការបញ្ជ្រាបចំណេះដឹង ផ្តល់ជាទិសដៅ និងកៀរគរធនធានគ្រប់គ្រាន់ ព្រមទាំងបង្កលទ្ធភាពក្នុងការបង្កើតទីផ្សារ និងផ្តល់ភាពស្របច្បាប់ (សូមមើលតារាង ៣.១)។

### តារាង ៣.១ ក្របខ័ណ្ឌប្រព័ន្ធនវានុវត្តន៍ជាតិ

| សមាសធាតុ | សេចក្តីពន្យល់ |
|---|---|
| សកម្មភាពសហគ្រិនភាព | សហគ្រិនមានសារសំខាន់ណាស់សម្រាប់ប្រព័ន្ធនវានុវត្តន៍មួយដែលមានដំណើរការល្អ។ មុខងារនេះអាចវិភាគទៅបាន តាមរយៈការរៀបចំចំណាត់ថ្នាក់តួលេខនៃចំនួនសហគ្រិនថ្មី ចំនួនសកម្មភាពចម្រុះជាច្រើនចេញពីសហគ្រិនបច្ចុប្បន្ន និងចំនួននៃការធ្វើពិសោធន៍ជាមួយបច្ចេកវិទ្យាថ្មី។ |
| ការអភិវឌ្ឍចំណេះដឹង | ការអភិវឌ្ឍចំណេះដឹងរួមបញ្ចូលនូវការរៀនសូត្រដោយការស្រាវជ្រាវ និងការរៀនសូត្រដោយការអនុវត្ត។ សូចនាករចំនួនបីក្នុងការចំណាត់ថ្នាក់សម្រាប់ការអភិវឌ្ឍចំណេះដឹងទៅតាមពេលវេលាគឺ៖ ១)គម្រោងស្រាវជ្រាវនិងអភិវឌ្ឍន៍ ២) ប្រកាសនីយបត្រតក្កកម្ម និង ៣)ការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍន៍។ ខណៈដែលសូចនាករទាំងនេះបង្ហាញពីកិច្ចខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍចំណេះដឹង គេក៏អាចធ្វើចំណាត់ថ្នាក់ពីកំណើននៃសមិទ្ធកម្មបច្ចេកវិទ្យា ដោយមធ្យោបាយមួយហៅថាខ្សែកោងនៃការសិក្សា។ |
| ការបញ្ជ្រាបចំណេះដឹងតាមរយៈបណ្តាញ ដោយរាប់បញ្ចូលទាំងបណ្តាញគោលនយោបាយ | សេចក្តីសម្រេចខាងគោលនយោបាយ រួមមានស្តង់ដារ គោលដៅរយៈពេលវែង ជាដើម គួរតែមានសង្គតិភាពជាមួយនឹងការយល់ដឹងផ្នែកបច្ចេកវិទ្យាចុងក្រោយបំផុត ស្របពេលជាមួយគ្នានេះដែរ របៀបវារៈនៃការស្រាវជ្រាវនិងអភិវឌ្ឍន៍គួរឆ្លើយតបទៅនឹងការផ្លាស់ប្តូរបទដ្ឋាននិងគុណតម្លៃ។ មុខងារនេះអាចវិភាគទៅបាន តាមរយៈការធ្វើចំណាត់ថ្នាក់ |

[41] Cicera & Maloney 2017.

| | |
|---|---|
| | ចំនួនសិក្ខាសាលា និងសន្និសីទដែលផ្តោតលើប្រធានបទបច្ចេកវិទ្យាជាក់លាក់ណាមួយ និងការធ្វើចំណាត់ថ្នាក់ទំហំ និងកម្លាំងនៃបណ្តាញ ទៅតាមពេលវេលា។ |
| ការកំណត់ទិសដៅ | ដោយសារធនធានតែងតែមានកម្រិតជាប្រចាំ គេត្រូវតែផ្តោតលើបច្ចេកវិទ្យាជាក់លាក់សម្រាប់ការវិនិយោគបន្ថែម នៅពេលដែលមានជម្រើសបច្ចេកវិទ្យាជាច្រើន។ បើគ្មានចំណាត់ការបែបនេះទេ គេមិនមានធនធានគ្រប់គ្រាន់ដើម្បីវិនិយោគលើជម្រើសទាំងអស់ឡើយ។ មុខងារនេះអាចវិភាគទៅបានដោយការធ្វើចំណាត់ថ្នាក់គោលដៅជាក់លាក់ដែលកំណត់ដោយរដ្ឋាភិបាល ឬឧស្សាហកម្ម ពាក់ព័ន្ធនឹងការប្រើប្រាស់បច្ចេកវិទ្យាជាក់លាក់ណាមួយ និងដោយការធ្វើចំណាត់ថ្នាក់ចំនួនអត្ថបទនៅក្នុងទិនានុប្បវត្តិវិជ្ជាជីវៈដែលធ្វើឱ្យមានពីក្តីរំពឹងទុកជុំវិញការអភិវឌ្ឍបច្ចេកវិទ្យាថ្មីៗ។ |
| ការបង្កើតទីផ្សារ (market formation) | បច្ចេកវិទ្យាថ្មី ជាញឹកញាប់ មានការលំបាកក្នុងការប្រកួតប្រជែងជាមួយបច្ចេកវិទ្យាដែលមានស្រាប់ជាយូរមកហើយ។ ដូច្នេះ វាជាការចាំបាច់ដែលត្រូវបង្កើតចន្លោះជាក់លាក់ណាមួយសម្រាប់បច្ចេកវិទ្យាថ្មីៗ។ មុខងារនេះអាចវិភាគទៅបានដោយការធ្វើចំណាត់ថ្នាក់ចំនួនទីផ្សារពិសេស (niche markets) ដែលត្រូវបានបង្កើតឡើង ក៏ដូចជារបបពន្ធពិសេសសម្រាប់បច្ចេកវិទ្យាថ្មីៗ និងស្តង់ដារបរិស្ថានដែលបង្កើនឱកាសសម្រាប់បច្ចេកវិទ្យាថ្មីបរិស្ថាន។ |
| ការកៀរគរធនធាន | សម្រាប់បច្ចេកវិទ្យាជាក់លាក់មួយ ការបែងចែកធនធានឱ្យបានគ្រប់គ្រាន់គឺជាការចាំបាច់ដើម្បីដំណើរការផលិតកម្មចំណេះដឹង (knowledge production) អាចប្រព្រឹត្តទៅបាន។ មុខងារនេះពិបាកក្នុងការធ្វើចំណាត់ថ្នាក់ដោយមធ្យោបាយនៃការធ្វើសូចនាករជាក់លាក់ទៅតាមពេលវេលា។ |
| ការបង្កើតភាពស្របច្បាប់ និង/ឬ ការប្រឆាំងនឹងការផ្លាស់ប្តូរ | ដើម្បីអភិវឌ្ឍខ្លួនឱ្យបានល្អ បច្ចេកវិទ្យាថ្មីត្រូវតែជាផ្នែកមួយនៃបរិបទដែលមានស្រាប់ ឬក៏ផ្តួលបរិបទចាស់។ ភាគីពាក់ព័ន្ធដែលមានផលប្រយោជន៍ជាច្រើន នឹងប្រឆាំងតបតវិញចំពោះផលប៉ះពាល់ពីការបំបាត់ទម្លាប់ចាស់ដោយទម្លាប់ថ្មី (Creative Destruction)។ ដូច្នេះ ការចងសម្ព័ន្ធដើម្បីតស៊ូមតិអាចដើរតួជាកាតាលីករដ៏សំខាន់ ដូចជា ការបញ្ចូលបច្ចេកវិទ្យាថ្មីទៅក្នុងរបៀបវារៈ និងបញ្ចុះបញ្ចូលឱ្យមានធនធាន និងរបបពន្ធអនុគ្រោះ។ ការអនុវត្តបែបនេះនឹងបង្កើតភាពស្របច្បាប់សម្រាប់គន្លងថ្មីនៃបច្ចេកវិទ្យា។ មុខងារនេះអាចវិភាគទៅបានដោយការធ្វើចំណាត់ថ្នាក់អំពីការកើនឡើងនិងការរីកចម្រើនរបស់ក្រុមទទួលផលប្រយោជន៍ (interest groups) និងសកម្មភាពបញ្ចុះបញ្ចូលរបស់ក្រុមទាំងនោះ។ |
| ប្រភព: M.P. Hekkerta, R.A.A. Suursa, S.O. Negroa, S. Kuhlmanna, R.E.H.M. Smits (2007). “Functions of innovation systems: A new approach for analysing technological change”, in Technological Forecasting and Social Change, 74, pp. 413–432. | |

## ៣.២ ការចាប់បដិសន្ធិនៃប្រព័ន្ធនវានុវត្តន៍ជាតិ

ប្រទេសកម្ពុជាមានប្រព័ន្ធនវានុវត្តន៍ជាតិទន់ខ្សោយដូចដែលបានបង្ហាញនៅក្នុងសន្ទស្សន៍នវានុវត្តន៍សកល ឆ្នាំ២០២០ (GII 2020) ដែលក្នុងនោះ កម្ពុជាមានលំដាប់លេខ ១១០ ក្នុងចំណោម ១៣១ ប្រទេសនៅលើពិភពលោក និងជាប់ចំណាត់ថ្នាក់ចុងក្រោយគេទី ៣ នៅក្នុងចំណោមបណ្តាប្រទេសអាស៊ាន។ ជាពិសេសទៀតនោះ កម្ពុជាទទួលបានពិន្ទុទាបទៅលើការចំណាយក្នុងវិស័យអប់រំ ការចុះឈ្មោះចូលរៀននៅថ្នាក់ឧត្តមសិក្សា និងការងារផ្អែកលើចំណេះដឹង ជាដើម។ គួរឱ្យកត់សម្គាល់ ប្រទេសកម្ពុជាមានពិន្ទុល្អជៀបទៅនឹងបណ្តាប្រទេសប្រកួតប្រជែងក្នុងអាស៊ានទៅលើផ្នែក លំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស ដែលបង្ហាញឱ្យឃើញថា ការវិនិយោគផ្ទាល់ពីបរទេសអាចជួយជំរុញឱ្យមានការស្រូបយកបច្ចេកវិទ្យា និងនវានុវត្តន៍នៅក្នុងប្រទេសកម្ពុជា។ រូបភាពទី ៣.២ បង្ហាញពីចំណាត់ថ្នាក់របស់កម្ពុជាលើកត្តាដែលជំរុញឱ្យមាននវានុវត្តន៍ផ្សេងៗ ដែលត្រូវបានវាស់វែងនៅក្នុង "របាយការណ៍ស្តីពីភាពប្រកួតប្រជែងជាសកល" របស់វេទិកាសេដ្ឋកិច្ចពិភពលោក។[42]

ជំពូកពីរបន្ទាប់នឹងសិក្សាស៊ីជម្រៅបន្ថែមទៀតទៅលើភាពខ្លាំង និងខ្សោយនៃប្រព័ន្ធនវានុវត្តន៍ជាតិកម្ពុជា។

[42] World Bank 2018, p. 20.

## រូបភាព ៣.២ ព័ត៌មានស្ដីអំពីកម្ពុជា សន្ទស្សន៍នវានុវត្តន៍សកល ឆ្នាំ២០២០

| ចំណាត់ថ្នាក់ GII 2020 | ចំណាត់ថ្នាក់ធាតុចេញ | ចំណាត់ថ្នាក់ធាតុចូល | ចំណាត់ថ្នាក់ GII 2019 |
|---|---|---|---|
| ១១០ | ១០១ | ១១៧ | ៩៨ |

| | ពិន្ទុ | ចំណាត់ថ្នាក់ | |
|---|---|---|---|
| **គ្រឹះស្ថាន-ស្ថាប័ន** | **៥០.០** | **១១២** | |
| **១.១ បរិស្ថាននយោបាយ** | **៤៩.៤** | **៩០** | |
| ១.១.១ ស្ថេរភាពនយោបាយ និងដំណើរការ | ៧៣.២ | ៤៩ | ● ◆ |
| ១.១.២ ប្រសិទ្ធភាពនៃរដ្ឋាភិបាល | ៣៧.៤ | ១០៣ | |
| **១.២ បរិស្ថាននីតិយុត្ត** | **៥៣.៣** | **១០៣** | |
| ១.២.១ គុណភាពនៃនីតិយុត្ត | ២៨.៥ | ១០៤ | |
| ១.២.២ គោលការណ៍ផ្លូវច្បាប់ | ១៧.៦ | ១២៦ | ◊ |
| ១.២.៣ តម្លៃនៃការកាត់បន្ថយការជាន់គ្នា ប្រាក់សប្ដាហ៍ | ១៩.៤ | ៨១ | |
| **១.៣ ស្ថានភាពធុរកិច្ច** | **៥០.៥** | **១២៧** | ○ ◊ |
| ១.៣.១ ភាពងាយស្រួលក្នុងការបើកអាជីវកម្ម | ៥២.៤ | ១៣១ | ○ ◊ |
| ១.៣.២ ភាពងាយស្រួលក្នុងការដោះស្រាយភាពក្ស័យធននៃអជីវកម្ម | ៤៨.៥ | ៧៤ | |
| **មូលធនមនុស្ស និងការស្រាវជ្រាវ** | **១១.១** | **១២២** | ◊ |
| **២.១ ការអប់រំ** | **២០.០** | **[១២៧]** | |
| ២.១.១ ការចំនាយទៅលើការអប់រំ , % ផ.ស.ស. | ២.២ | ១១៣ | |
| ២.១.២ មូលនិធិរបស់រដ្ឋាភិបាល មធ្យមសិក្សា % ផ.ស.ស./ម្នាក់ | គ្មាន | គ្មាន | |
| ២.១.៣ ការរំពឹងទុកចំនួនឆ្នាំសិក្សា | គ្មាន | គ្មាន | |
| ២.១.៤ PISA ក្នុងការអាន គណិតវិទ្យា និងវិទ្យាសាស្រ្ត | គ្មាន | គ្មាន | |
| ២.១.៥ ផលធៀបរវាងគ្រូ/សិស្ស ថ្នាក់មធ្យមសិក្សា | ២១.៩ | ១០២ | |
| **២.២ ការអប់រំថ្នាក់ឧត្តមសិក្សា** | **១២.៨** | **១១០** | |
| ២.២.១ ការចុះឈ្មោះសរុបថ្នាក់ឧត្តមសិក្សា %សរុប | ១៣.៧ | ១០១ | |
| ២.២.២ បញ្ចប់ការសិក្សាផ្នែកវិទ្យាសាស្រ្តនិងវិស្វករ %វិស្វកម្ម | ១៥.៤ | ៩៣ | |
| ២.២.៣ សិស្សបរទេសចល័តចូលប្រទេស | គ្មាន | គ្មាន | |
| **២.៣ ការស្រាវជ្រាវនិងអភិវឌ្ឍន៍** | **០.៦** | **១១១** | |
| ២.៣.១ចំនួនអ្នកស្រាវជ្រាវ FTE/mn Pop | ៣០.៤ | ១០២ | ○ |
| ២.៣.២ ការចំនាយសរុបទៅលើការស្រាវជ្រាវនិងអភិវឌ្ឍន៍ % ផ.ស.ស. | ០.១ | ១០២ | |
| ២.៣.៣ ក្រុមហ៊ុនស្រាវជ្រាវនិងអភិវឌ្ឍន៍លំដាប់ពិភពលោក | ០.០ | ៤២ | ○ ◊ |
| ២.៣.៤ Qs university ranking, average score top 3 | ០.០ | ៧៧ | ○ ◊ |
| **ហេដ្ឋារចនាសម្ព័ន្ធ** | **២៣.១** | **១២០** | ○ ◊ |
| **៣.១ បច្ចេកវិទ្យាបណ្ដាញនិងព័ត៌មាន** | **៣២.៧** | **១១៧** | ◊ |
| ៣.១.១ ការទទួលបានបច្ចេកវិទ្យាបណ្ដាញនិងព័ត៌មាន | ៤៦.៨ | ៩៥ | |
| ៣.១.២ ការប្រើប្រាសក្នុងវិស័យបច្ចេកវិទ្យា បណ្ដាញនិងព័ត៌មាន | ៤១.៥ | ៩៦ | |
| ៣.១.៣ សេវាអនឡាញរបស់រាជរដ្ឋាភិបាល | ២៥.០ | ១២៣ | ○ ◊ |
| ៣.១.៤ ការចូលរួមតាមអេឡិចត្រូណិក | ១៧.៤ | ១២៦ | ○ ◊ |
| **៣.២ ហេដ្ឋារចនាសម្ព័ន្ធទូទៅ** | **១៧.៦** | **១១៤** | |
| ៣.២.១ ទិន្នផលនៃការបង្កើតថាមពលអគ្គីសនី | ៤៣៧.១ | ១០៩ | |
| ៣.២.២ សមិទ្ធកម្មនៃភស្តុភាកម្ម | ២៣.៩ | ៩៤ | |
| ៣.២.៣ ការបង្កើតមូលធនសរុប, % ផ.ស.ស | ២៣.៥ | ៦៤ | |
| **៣.៣ ចីរភាពនៃប្រព័ន្ធអេកូឡូស៊ី** | **១៩.០** | **១០៩** | |
| ៣.៣.១ ផ.ស.ស./ឯកតាការប្រើប្រាស់ថាមពល | ៧.១ | ៨៨ | |
| ៣.៣.២ សមិទ្ធកម្មបរិស្ថាន | ៣៣.៦ | ១០៨ | |
| ៣.៣.៣ វិញ្ញាបនបត្របរិស្ថាន ISO 14001/bn PPP$ ផ.ស.ស | ០.៧ | ៧១ | |
| **ទំនើបកម្មនៅក្នុងទីផ្សារ** | **៤៦.៦** | **៧២** | ● ◆ |
| **៤.១ ឥណទាន** | **៦៦.៤** | **១១** | ● ◆ |
| ៤.១.១ ភាពងាយស្រួលក្នុងការទទួលបានឥណទាន | ៨០.០ | ២៣ | ● |
| ៤.១.២ ការទទួលបានឥណទានក្នុងស្រុកនៃវិស័យឯកជន, % ផ.ស.ស. | ៩៩.៦ | ២៤ | ● ◆ |
| ៤.១.៣ ប្រាក់កម្ចីសរុបរបស់មីក្រូហិរញ្ញវត្ថុធៀបទៅនិងGDP | ៣៨.៣ | ២ | ● ◆ |
| **៤.២ ការវិនិយោគ** | **២៥.៦** | **១១៤** | |
| ៤.២.១ ភាពងាយស្រួលក្នុងការការពារវិនិយោគិនភាគតិច | ៤០.០ | ១១០ | |
| ៤.២.២ ការផ្ញើមូលធនទីផ្សារ % ផ.ស.ស | គ្មាន | គ្មាន | |
| ៤.២.៣ ការបណ្ដាក់ទុនលើវិនិយោគ/bn PPP$ GDP | ០.១ | ៣៣ | |
| **៤.៣ ទំហំពាណិជ្ជកម្ម ការប្រកួតប្រជែង និងទីផ្សារ** | **៤៧.៩** | **១២១** | ◊ |
| ៤.៣.១ ការអនុវត្តអត្រាពន្ធ | ៩.៨ | ១១៣ | |
| ៤.៣.២ ទំហំនៃការប្រកួតប្រជែងក្នុងស្រុក | ៥៩.៦ | ១០៨ | ◊ |
| ៤.៣.៣ ទំហំទីផ្សារក្នុងស្រុក | ៧៦.៩ | ៩១ | |

| | ពិន្ទុ | ចំណាត់ថ្នាក់ | |
|---|---|---|---|
| **ទំនើបកម្មនៅក្នុងធុរកិច្ច** | **១៧.៣** | **១១៩** | |
| **៥.១ បុគ្គលិកដែលមានចំណេះដឹង** | **១១.៨** | **១២១** | ◊ |
| ៥.១.១ ការងារដែលពឹងផ្អែកលើចំនេះដឹង | ៥.៣ | ១១៤ | ◊ |
| ៥.១.២ ក្រុមហ៊ុនផ្ដល់ការបណ្ដុះបណ្ដាលផ្លូវការ/សរុប | ២២.២ | ៦៦ | |
| ៥.១.៣ ការចំណាយសរុបលើ R&D ប្រតិបត្តិដោយធុរកិច្ច % ផ.ស.ស | ០.០ | ៨២ | |
| ៥.១.៤ ការចំណាយសរុបលើ R&D ផ្ដល់ទុនដោយធុរកិច្ច % ផ.ស.ស | ១៩.៤ | ៦៥ | |
| ៥.១.៥ ស្រ្តីបម្រើការងារដែលមានសញ្ញាបត្រខ្ពស់, % | ២.៣ | ៩៩ | |
| **៥.២ ការតភ្ជាប់នវានុវត្តន៍** | **២៥.៧** | **៤៥** | ● ◆ |
| ៥.២.១ កិច្ចសហការស្រាវជ្រាវរវាងសកលវិទ្យាល័យនិងសហគ្រាស | ៣៦.៧ | ៩១ | |
| ៥.២.២ ស្ថានភាពនៃការអភិវឌ្ឍបណ្ដុំ | ៤៨.១ | ៦១ | ● |
| ៥.២.៣ ការចំណាយសរុបលើ R&D ផ្ដល់ទុនដោយបរទេស | ០.០ | ៥៣ | ● ◆ |
| ៥.២.៤ សម្ព័នភាពយុទ្ធសាស្រ្តលើការបណ្ដាក់ទុនរួម/bn PPP$ ផ.ស.ស | ០.១ | ៣៦ | ● |
| ៥.២.៥ គ្រួសារប្រកាសនីយបត្រតក្កកម្ម 2+ offices/bn PPP$ GDP | គ្មាន | គ្មាន | ○ ◊ |
| **៥.៣ ការស្រូបយកចំណេះដឹង** | **១៤.៣** | **១២៩** | ◊ |
| ៥.៣.១ ការបង់ថ្លៃកម្មសិទ្ធបញ្ញាធៀបទៅនិងពាណិជ្ជកម្មសរុប | ០.១ | ១០៤ | |
| ៥.៣.២ ការនាំចូលបច្ចេកវិទ្យាខ្ពស់ធៀបទៅនិងពាណិជ្ជកម្មសរុប | ២.៨ | ១២៧ | ○ ◊ |
| ៥.៣.៣ ការនាំចូល ICT ធៀបទៅនិងពាណិជ្ជ៥.៣.៤ កម្មសរុប | ០.៨ | ៨៥ | |
| ៥.៣.៤ លំហូរចូលនៃវិនិយោគផ្ទាល់ពីបរទេស, % ផ.ស.ស | ១២.៦ | ៧ | ● ◆ |
| ៥.៣.៥ ទេពកោសល្យស្រាវជ្រាវ %ក្នុងសហគ្រាសនិងធុរកិច្ច | ៤.៣ | ៧៣ | |
| **លទ្ធផលចំណេះដឹង និងបច្ចេកវិទ្យា** | **១៣.២** | **៩៦** | |
| **៦.១ ការបង្កើតចំនេះដឹង** | **៣.១** | **១២១** | |
| ៦.១.១ ប្រកាសនីយបត្រតក្កកម្មដោយប្រភពដើម/bn PPP$ ផ.ស.ស | ០.១ | ១២៦ | ○ |
| ៦.១.២ សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម/bn PPP$ ផ.ស.ស | ០.០ | ១០០ | ○ ◊ |
| ៦.១.៣ ម៉ូដែលមានអត្ថប្រយោជន៍ដោយប្រភពដើម/bn PPP$ ផ.ស.ស | គ្មាន | គ្មាន | |
| ៦.១.៤ កាលិកបត្រវិទ្យាសាស្រ្ត និងបច្ចេកទេស/bn PPP$ ផ.ស.ស | ២.៣ | ១១៣ | |
| ៦.១.៥ ឯកសារដែលអាចយោង H-index | ៥.៦ | ៩៩ | |
| **៦.២ ផលជះនៃចំណេះដឹង** | **២១.៩** | **៧៣** | |
| ៦.២.១ អាត្រាកំណើននៃ PPP$ ផ.ស.ស./បុគ្គលិក, % | ៥.១ | ៨ | ● |
| ៦.២.២ ធុរកិច្ចថ្មី/th pop. 15-64 | ០.៧ | ៩០ | |
| ៦.២.៣ ការចំណាយលើសូហ្វែរកុំព្យូទ័រធៀបទៅនិងផ.ស.ស | ០.០ | ១១៣ | ◊ |
| ៦.២.៤ វិញ្ញាបនបត្រគុណភាព ISO 9001/bn PPP$ ផ.ស.ស | ២.៦ | ៧៩ | |
| ៦.២.៥ កម្មន្តសាលបច្ចេកវិទ្យាកម្រិតខ្ពស់និងខ្ពស់មធ្យម | គ្មាន | គ្មាន | |
| **៦.៣ ការបញ្ជ្រាបចំណេះដឹង** | **១៤.៦** | **៩៧** | |
| ៦.៣.១ ការទទួលបានរ៉ក៏យបត្រកម្មសិទ្ធិបញ្ញាធៀបទៅនិងពាណិជ្ជកម្មសរុប | ០.០ | ៨៨ | |
| ៦.៣.២ ការនាំចេញសរុបនៃបច្ចេកវិទ្យាទំនើបធៀបទៅនិងពាណិជ្ជកម្មសរុប | ១.១ | ៦៦ | |
| ៦.៣.៣ ការនាំចេញសេវាកម្ម ICT ធៀបទៅនិងពាណិជ្ជកម្មសរុប | ០.៣ | ១០៨ | |
| ៦.៣.៤ លំហូរចេញសរុបនៃវិនិយោគផ្ទាល់ទៅបរទេស | ០.៥ | ៧៨ | |
| **លទ្ធផលនៃភាពច្នៃប្រឌិត** | **១៣.៤** | **១០២** | |
| **៧.១ ទ្រព្យអរូបិយ** | **២១.៦** | **៨៨** | |
| ៧.១.១ ពាណិជ្ជសញ្ញាដោយប្រភពដើម/bn PPP$ ផ.ស.ស | ៣៤.២ | ៧១ | |
| ៧.១.២ តម្លៃយីហោសកល top 5000 % ផ.ស.ស. | ០.០ | ៨០ | |
| ៧.១.៣ ការរចនាឧស្សាហកម្មដោយប្រភពដើម/bn PPP$ ផ.ស.ស | ០.២ | ១០៥ | |
| ៧.១.៤ ការបង្កើតម៉ូដែលរចនាសម្ព័ន្ធនិង ICT ផ្សេងៗ | ៦០.៦ | ៤១ | ● ◆ |
| **៧.២ ទំនិញនិងសេវាដែលមានភាពច្នៃប្រឌិត** | **៧.២** | **[៩៣]** | |
| ៧.២.១ ការនាំចេញសេវាមានភាពច្នៃប្រឌិតនិងវប្បធម៌ | គ្មាន | គ្មាន | |
| ៧.២.២ ភាពយន្តលក្ខណៈជាតិ | ៣.២ | ៥៧ | |
| ៧.២.៣ ទីផ្សារកំសាន្ត និងប្រព័ន្ធផ្សព្វផ្សាយ | គ្មាន | គ្មាន | |
| ៧.២.៤ ការបោះពុម្ពផ្សាយ និងប្រព័ន្ធផ្សព្វផ្សាយ, %manufacturing | គ្មាន | គ្មាន | |
| ៧.២.៥ ការនាំចេញទំនិញដែលមានភាពច្នៃប្រឌិតធៀបទៅនិងពាណិជ្ជកម្មសរុប | ០.៤ | ៦៦ | |
| **៧.៣ ការច្នៃប្រឌិតតាមអនឡាញ** | **០៣១** | **១១៦** | |
| ៧.៣.១ Generic top-level domains (TLDs)/th pop. 15-69 | ០.៨ | ១០០ | |
| ៧.៣.២ លេខកូដប្រទេស TLDs/th pop 15-69 | ០.១ | ១១៧ | |
| ៧.៣.៣ ការកែសម្រួល Wikipedia /mn pop. 15-69 | ១៦.២ | ១១៤ | |
| ៧.៣.៤ ការបង្កើតកម្មវិធីទូរស័ព្ទ | ០.១ | ៨៤ | |

ប្រភព៖ Cornell University, INSEAD, WIPO. Global Innovation Index 2020. Available at www.wipo.int/edocs/pubdocs/en/wipo_pub_gii_2020.pdf

# ជំពូកទី ៤

# ភាពខ្លាំងនៃប្រព័ន្ធនវានុវត្តន៍ជាតិ

ប្រព័ន្ធនវានុវត្តន៍ជាតិរបស់ប្រទេសកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងរយៈពេល ៦ ឆ្នាំចុងក្រោយនេះ។ រាជរដ្ឋាភិបាលបានបង្កើតគំនិតផ្តួចផ្តើមមួយចំនួនដែលត្រូវបន្តកសាងក្នុងរយៈពេល ១០ ឆ្នាំខាងមុខ (រូបភាពទី ៤.១)។

## រូបភាព ៤.១ ភាពខ្លាំងនៃប្រព័ន្ធនវានុវត្តន៍ជាតិកម្ពុជា



# ៤.១ និន្នាការទូទៅនៃរដ្ឋាភិបាល និងអភិបាលកិច្ចដែលបង្ករិយាកាសដល់ការអភិវឌ្ឍវិស័យ វ.ប.ន.

## ការរៀបចំរចនាសម្ព័ន្ធថ្មីរបស់ក្រសួងក្នុងការដឹកនាំវិស័យ វ.ប.ន.

រចនាសម្ព័ន្ធថ្មីរបស់រាជរដ្ឋាភិបាល ក្នុងនោះរួមមាន ក្រសួង ឧ.វ.ប.ន. ដែលទើបបង្កើតថ្មី និង ក.ជ.វ.ប.ន. ដែលជាស្ថាប័នអន្តរក្រសួង នឹងផ្ដល់ជាមូលដ្ឋានដ៏រឹងមាំដល់ការអភិវឌ្ឍប្រព័ន្ធនវានុវត្តន៍ជាតិ ខណៈដែលការបង្កើនកិច្ចសម្របសម្រួល និងការអនុវត្តសកម្មភាពការងារឱ្យមានប្រសិទ្ធភាពគឺនៅតែជាការចាំបាច់។

បន្ទាប់ពីច្បាប់ស្ដីពីការបង្កើតក្រសួង ឧ.វ.ប.ន. ត្រូវបានអនុម័តជាផ្លូវការកាលពីខែមីនា ឆ្នាំ២០២០ ក្រសួង ឧ.វ.ប.ន. ត្រូវអនុវត្តអាណត្តិការងារបន្តពីអតីតក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្រសួង ឧ.វ.ប.ន. មានរចនាសម្ព័ន្ធដូចខាងក្រោម (តារាង ៤.១)។

តារាង ៤.១ រចនាសម្ព័ន្ធក្រសួង ឧ.វ.ប.ន.

| |
|---|
| ទេសរដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ |
| ខុទ្ទកាល័យរដ្ឋមន្ត្រី |
| អគ្គនាយកដ្ឋានកិច្ចការទូទៅ |
| អគ្គនាយកដ្ឋានឧស្សាហកម្ម |
| អគ្គនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម |
| អគ្គនាយកដ្ឋានទឹកស្អាត |
| អគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| វិទ្យាស្ថានស្តង់ដារកម្ពុជា |
| វិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ |
| នាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| អគ្គាធិការដ្ឋាន |
| មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍រាជធានី ខេត្ត |

ក្នុងការងារដឹកនាំសម្របសម្រួលរវាងអន្តរក្រសួង ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៤ ដែលស្ថិតក្រោមក្រសួងផែនការ ។ ក៏ប៉ុន្តែ នៅឆ្នាំ២០២០ ក្រុមប្រឹក្សានេះត្រូវបានប្តូរឈ្មោះជា ក្រុមប្រឹក្សាជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ក.ជ.វ.ប.ន) ដោយស្ថិតនៅក្រោមក្រសួង ឧ.វ.ប.ន. វិញ និងដែលមានសមាសភាពដូចខាងក្រោម (តារាង ៤.២)។

**តារាង ៤.២ សមាជិកក្រុមប្រឹក្សាជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

| នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា | ប្រធានកិត្តិយស |
|---|---|
| រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ប្រធាន |
| រដ្ឋមន្ត្រីក្រសួងផែនការ | អនុប្រធាន |
| រដ្ឋមន្ត្រីក្រសួងសុខាភិបាល | អនុប្រធាន |
| រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល | អនុប្រធាន |
| រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | អនុប្រធាន |
| រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ១ រូប | អនុប្រធានអចិន្ត្រៃយ៍ |
| រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ១ រូប | សមាជិក |
| រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ១ រូប | សមាជិក |
| រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ១ រូប | សមាជិក |
| រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១ រូប | សមាជិក |
| រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ១ រូប | សមាជិក |
| រដ្ឋលេខាធិការក្រសួងព័ត៌មាន ១ រូ ប | សមាជិក |
| រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន ១ រូប | សមាជិក |
| រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ១ រូប | សមាជិក |
| រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ១ រូប | សមាជិក |
| រដ្ឋលេខាធិការក្រសួងបរិស្ថាន ១ រូប | សមាជិក |
| រដ្ឋលេខាធិការក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ១ រូប | សមាជិក |
| រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម ១ រូប | សមាជិក |
| រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ១ រូប | សមាជិក |
| រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ១ រូប | សមាជិក |
| រដ្ឋលេខាធិការក្រសួងទេសចរណ៍ ១ រូប | សមាជិក |
| រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ១ រូប | សមាជិក |
| អគ្គលេខាធិការរងគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា ១ រូប | សមាជិក |
| អនុប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ១ រូប | សមាជិក |

| | |
|---|---|
| តំណាងស្ថាប័នសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងការងារវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ១ រូប | សមាជិក |
| តំណាងសភាពាណិជ្ជកម្មកម្ពុជា ១ រូប | សមាជិក |
| អគ្គនាយកនៃវិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ១ រូប | សមាជិក |
| អគ្គនាយកនៃអគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ១ រូប | សមាជិកអចិន្ត្រៃយ៍ |

ក្រៅពីនេះ ប្រទេសកម្ពុជាបានចូលរួមនៅក្នុងគណៈកម្មាធិការជាតិសម្រាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែក វ.ប.ន.។ គណៈកម្មាធិការនេះមានតួនាទីជួយទ្រទ្រង់ដល់កិច្ចសហប្រតិបត្តិការអាស៊ានក្នុងវិស័យ វ.ប.ន. និងជំរុញការអនុវត្តកម្មវិធី និងសកម្មភាពមួយចំនួននៅក្នុងវិស័យដែលបានកំណត់នៅក្នុងផែនការសកម្មភាពអាស៊ានស្តីពីវិស័យ វ.ប.ន. ឆ្នាំ២០១៦-២០២៥។ នៅកម្ពុជា គណៈកម្មាធិការនេះស្ថិតនៅក្រោមការដឹកនាំរបស់ក្រសួង ឧ.វ.ប.ន។

### កាលានុវត្តភាពច្បាស់លាស់ ក្នុងការជំរុញអភិវឌ្ឍន៍យ៉ាងឆាប់រហ័សរបស់កម្ពុជា ឆ្ពោះទៅរកវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

ការអភិវឌ្ឍយ៉ាងឆាប់រហ័សរបស់ប្រទេសកម្ពុជាគឺជាកត្តាលីករជំរុញបរិវត្តកម្មសេដ្ឋកិច្ច (Economy Transformation)។ ខឿនសេដ្ឋកិច្ចកម្ពុជាកំពុងធ្វើឧស្សាហូបនីយកម្ម និងទំនើបកម្មឥតឈប់ឈរ រួមមានវិស័យកសិកម្មផងដែរ។ ដោយមានការគាំទ្រសមស្រប និន្នាការនេះនឹងជំរុញដល់ការបង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងការស្រាវជ្រាវ និងអភិវឌ្ឍន៍នៅក្នុងប្រទេស។

ស្របគ្នានឹងការអភិវឌ្ឍសេដ្ឋកិច្ច ឥណទានក្នុងស្រុកដែលផ្តល់លើវិស័យសេវាកម្មកំពុងមានការកើនឡើង ក្នុងនោះរួមមាន ការលក់ដុំ ការដឹកជញ្ជូន ទូរគមនាគមន៍ និងការប្រើប្រាស់ផ្ទាល់ខ្លួនជាដើម។ និន្នាការនេះបង្ហាញពីការកើនឡើងនៅក្នុងតម្រូវការនៃការប្រើប្រាស់សេវាកម្ម និងសំណង់ ដែលបានជំរុញឱ្យអាជីវកម្មលក់ដុំធំៗបង្កើនការផ្តល់សេវាកម្ម តាមរយៈការនាំចូលទំនិញប្រើប្រាស់បានយូរដូចជា យានយន្ត និងសម្ភារសំណង់។ កំណើននៃការប្រើប្រាស់នេះ ត្រូវតែតម្រង់ឆ្ពោះទៅរកនវានុវត្តន៍ និងការបង្កើតផលិតផលថ្មីៗ ហើយក៏ជាប្រភពដ៏សំខាន់សម្រាប់ការលើកទឹកចិត្តនវានុវត្តន៍។

ការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃគោលនយោបាយជាតិស្តីពី វ.ប.ន. គឺជាកាលានុវត្តភាពដ៏សំខាន់ក្នុងការអភិវឌ្ឍវិស័យ វ.ប.ន. នៅក្នុងប្រទេស។ ការធ្វើផែនការ និងការវិភាគយ៉ាងទូលំទូលាយរបស់ប្រទេសកម្ពុជា បាននាំទៅដល់ការកំណត់វិស័យអាទិភាពមួយចំនួនក្នុងកិច្ចអន្តរាគមន៍។ ជាឧទាហរណ៍ ក្នុងចំណោមបច្ចេកវិទ្យាអាទិភាពដែលបានលើកជាយោបល់ដោយក្រសួង/ស្ថាប័នពាក់ព័ន្ធ (សូមមើលផ្នែកទី ៩) មានបច្ចេកវិទ្យាអាទិភាពចំនួន ៣ ត្រូវបានកំណត់ ដូចជា បច្ចេកវិទ្យាកែច្នៃផលិតផលកសិកម្ម បច្ចេកវិទ្យាមាតិកាឌីជីថលនិងសូហ្វវែរ និងជីវបច្ចេកវិទ្យា។ ផែនទីបង្ហាញផ្លូវគឺជាឯកសារដ៏សំខាន់សម្រាប់កៀរគរធនធានឆ្ពោះទៅរកវិស័យដែលជាអាទិភាពបំផុត និងដើម្បីលើកកម្ពស់កិច្ចអន្តរាគមន៍របស់រាជរដ្ឋាភិបាល។

## ៤.២ ពន្លកនៃប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធនវានុវត្តន៍

### ការកើនឡើងនៃការគាំទ្រនវានុវត្តន៍

កន្លែងធ្វើការងាររួមគ្នា និងកន្លែងភ្ញាស់ កំពុងមានការអភិវឌ្ឍយ៉ាងឆាប់រហ័សនៅក្នុងប្រទេស។ ដោយមិនរាប់បញ្ចូលទីតាំងដែលផ្តល់ជាតុការិយាល័យ និងអ៊ីនធឺណិតបណ្តោះអាសន្ន គេសង្កេតឃើញមានកន្លែងធ្វើការរួមគ្នាសម្រាប់ក្រុមហ៊ុនដំណើរការដំបូង (seed-stage co-working spaces) លើសពី ១៧ កន្លែង ដោយក្នុងនោះ ១៤ កន្លែងនៅរាជធានីភ្នំពេញ និង ៣ កន្លែងទៀតនៅខេត្តសៀមរាប ដែលមានសមត្ថភាពដាក់បានចំនួន លើសពី ៥០០ តុការិយាល័យ។ ទីកន្លែងទាំងនោះភាគច្រើនគឺជាកម្មសិទ្ធិឯកជន និងមួយចំនួនតូចដំណើរការដោយមូលនិធិមិនស្វែងរកប្រាក់ចំណេញ។ ទីកន្លែងធ្វើការរួមគ្នាទាំងនោះ ភាគច្រើនទើបតែបង្កើតនាពេលថ្មីៗនេះ។

កន្លែងធ្វើការងាររួមគ្នាមួយចំនួនតូចប៉ុណ្ណោះមានអ្នកគ្រប់គ្រងសហគមន៍ ដែលជួយសម្រួលដល់ការផ្តល់សេវាកម្ម និងបង្កើតកម្មវិធីមួយចំនួន ក្នុងនោះរួមមានសកម្មភាពជាច្រើន រាប់ពីការរៀបចំព្រឹត្តិការណ៍ទាក់ទិននឹងការកសាងសហគមន៍ រហូតដល់ សិក្ខាសាលាបណ្តុះបណ្តាល ការណែនាំ (mentorship) និងការបង្កើតបណ្តាញទំនាក់ទំនងវិនិយោគិន។

ទោះបីជាថ្មីថ្មោងសម្រាប់ប្រទេសកម្ពុជា ស្របពេលជាមួយនឹងការកើនឡើងនៃកន្លែងធ្វើការងាររួមគ្នាក៏ដោយ គេឃើញមានលេចឡើងនៅក្នុងតំបន់នូវការភ្ញាស់អាជីវកម្មដំណាក់កាលដំបូង ឬកម្មវិធីពន្លឿនធុរកិច្ចថ្មីមួយចំនួន។ ជាធម្មតា កម្មវិធីទាំងនេះរាប់បញ្ចូល ការប្រកួតប្រជែងបង្ហាញពីគំនិតអាជីវកម្ម (pitching competitions) អមជាមួយនឹងសមាសធាតុសំខាន់ៗនៃការអភិវឌ្ឍធុរកិច្ចក្នុងរយៈពេលខ្លី (ជាថ្ងៃ សប្តាហ៍ ឬខែ) ឬក៏ជាស៊េរីកម្មវិធីបង្រៀនពីរបៀបបង្កើតធុរកិច្ចថ្មីដោយមានការចូលរួមជាជំនាន់ៗ (cohort-based bootcamps) ជាមួយនឹងមូលនិធិរួមក្នុងកម្រិតណាមួយ។ កម្មវិធីទាំងនេះផ្តោតជាចម្បងនៅរាជធានីភ្នំពេញ និងមានចំនួនតិចនៅឡើយនៅខេត្តសៀមរាប និងខេត្តបាត់ដំបង។

កម្មវិធីពន្លឿនធុរកិច្ចថ្មីក្នុងស្រុកមួយចំនួនបានលេចឡើងនៅក្នុងប្រទេសកម្ពុជា នារយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយផ្តោតលើការជួយធុរកិច្ចដែលត្រៀមពង្រីកខ្លួន ប៉ុន្តែពុំមានកម្មវិធីណាមួយដែលផ្តោតជាពិសេសលើការបណ្តុះធុរកិច្ចថ្មីពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យានៅឡើយទេ។

កម្មវិធីពន្លឿនធុរកិច្ចថ្មីក្នុងតំបន់ក៏បានអភិវឌ្ឍក្នុងពេលថ្មីៗនេះដែរ រួមមាន៖ កម្មវិធី TigerMekong, Echelon Top100 APAC, Mekong Business Initiative, Seedstars Bootcamp ជាដើម។ ធុរកិច្ចថ្មីនៅកម្ពុជា ក៏អាចរៀនសូត្រពីគំនិតថ្មីៗ បណ្តាញទំនាក់ទំនង និងបង្ហាញវត្តមានរបស់ខ្លួន ព្រមទាំងស្វែងរកមូលនិធិតាមរយៈការចូលរួមក្នុងការប្រកួតប្រជែង និងព្រឹត្តិការណ៍ក្នុងតំបន់ជាច្រើន។

ក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាលបានបង្កើតគំនិតផ្តួចផ្តើមគោលនយោបាយ និងការជជែកពិភាក្សានានា ជុំវិញការជំរុញវិស័យបច្ចេកវិទ្យា និងប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មី ក្នុងនោះរួមទាំងការដាក់ចេញនូវចក្ខុវិស័យសេដ្ឋកិច្ចឌីជីថលរបស់កម្ពុជាទៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤។ នេះជាលើកទីមួយហើយដែលសេដ្ឋកិច្ចឌីជីថលត្រូវបានដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ជាតិ។

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានផ្តួចផ្តើមការចូលរួមជាសាធារណៈ តាមរយៈការណែនាំយុទ្ធនាការលើកកម្ពស់ការយល់ដឹងយ៉ាងទូលំទូលាយ ដូចជា កម្មវិធី «ពានរង្វាន់ ICT កម្ពុជាប្រចាំឆ្នាំ» និង «ពានរង្វាន់ស្ត្រីក្នុងវិស័យបច្ចេកវិទ្យា» ដែលជាការលើកស្ទួយមុខមាត់ធុរកិច្ចថ្មី និងសហគ្រិនក្នុងស្រុក។ ទាំងអស់នេះគឺមានសារសំខាន់ណាស់សម្រាប់ធ្វើជាគំរូម៉ូដែល និងជាការបង្ហាញពីវិស័យនេះទៅដល់ប្រព័ន្ធផ្សព្វផ្សាយ។ កម្មវិធីនេះត្រូវបានគាំទ្រដោយកម្មវិធីភ្ញាស់ និងកម្មវិធីប្រកួតប្រជែងបង្ហាញពីគំនិតអាជីវកម្ម (Pitching

Competitions) ដែលមានការជំរុញពីឧស្សាហកម្ម រួមមាន SmartStart EchelonTop100APAC និង Seedstars Bootcamp ជាមួយនឹងកំណើនវត្តមាននៅតាមសាកលវិទ្យាល័យ និងប្រព័ន្ធផ្សព្វផ្សាយ។ បន្ទាប់ពីបានពិគ្រោះយោបល់ជាបន្តបន្ទាប់ជាមួយក្រុមសហគ្រិន និងវិស័យឯកជន ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ នឹងដាក់ចេញនូវ «គោលនយោបាយស្តីពីធុរកិច្ចថ្មីនៅកម្ពុជា» ដែលជាគោលនយោបាយដំបូងបង្អស់នៅក្នុងតំបន់នេះ។

ដោយមានសហប្រតិបត្តិការជាមួយក្រសួងពាណិជ្ជកម្ម ក្រសួងឧ.វ.ប.ន.ក៏បានគាំទ្រគំនិតផ្តួចផ្តើមនានា ដូចជា ពានរង្វាន់សហគ្រិនឆ្នើមវ័យក្មេងកម្ពុជាប្រចាំឆ្នាំ ក្រោមការចូលរួមពីសមាគមសហគ្រិនវ័យក្មេងកម្ពុជា និងសភាយុវពាណិជ្ជករអន្តរជាតិ។ ក្រោមការដឹកនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ «មូលនិធិអភិវឌ្ឍន៍ជំនាញ» ដែលមានដើមទុនសរុបចំនួន ៥ លានដុល្លារ ត្រូវបានបម្រុងទុកសម្រាប់គាំទ្រការបន្សុីគ្នារវាងកម្មវិធីសិក្សានៅសាកលវិទ្យាល័យ ជាមួយនឹងសមត្ថលទ្ធភាពសហគ្រិនដែលមានស្រាប់ និងតម្រូវការទីផ្សារ។ មូលនិធិនេះនឹងនាំមកនូវទេពកោសល្យ ជំនាញបច្ចេកទេសកាន់តែខ្ពស់ និងបង្កើនភាពជាដៃគូក្នុងវិស័យឯកជន ដើម្បីធានាបាននូវទេពកោសល្យដែលឆ្លើយតបនឹងតម្រូវការរបស់និយោជក ជាពិសេសសហគ្រាសធុនតូចនិងមធ្យម និងធុរកិច្ចថ្មី។ មូលនិធិមួយទៀតគឺ «មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព» ដែលមានថវិកាចំនួន ៥ លានដុល្លារ ត្រូវបានបង្កើតឡើងសម្រាប់ចូលរួមចំណែកបង្កើតផ្នត់គំនិតដែលជំរុញនវានុវត្តន៍ និងការលើកទឹកចិត្តឱ្យចាប់យកអាជីព ក្រៅពីរង្វង់នៃអាជីពប្រពៃណី។ មូលនិធិអាចផ្តល់ការគាំទ្រមជ្ឈមណ្ឌលភ្ញាស់ និងគម្រោងនានាដែលកសាងសមត្ថភាពក្នុងប្រព័ន្ធអេកូឡូស៊ី។

## នវានុវត្តន៍ដោយមានគោលបំណង

នវានុវត្តន៍អាជីវកម្មមានសារសំខាន់ណាស់ក្នុងការផ្តល់នូវឱកាសចិញ្ចឹមជីវិត ក៏ដូចជាការផ្តល់ទំនិញនិងសេវាកម្មនានាដែលឆ្លើយតបទៅនឹងតម្រូវការសង្គម។ ប្រទេសកម្ពុជាមានវិស័យសហគ្រាសសង្គមដ៏ធំឧទាហរណ៍ សហគ្រាសសង្គមខ្នាតតូចមួយចំនួនធំកំពុងធ្វើការងារដើម្បីឆ្លើយតបទៅនឹងតម្រូវការសង្គម និងបរិស្ថាន ប៉ុន្តែគួរឱ្យសោកស្តាយ វិស័យនេះនៅតែពឹងផ្អែកខ្លាំងលើជំនួយឥតសំណង។

នៅក្នុងប្រទេសកម្ពុជា មានសក្តានុពលដ៏ធំធេងក្នុងការគាំទ្រដល់អាជីវកម្មនវានុវត្តន៍ ដែលឆ្លើយតបទៅនឹងតម្រូវការសង្គម និងបរិស្ថានសំខាន់ៗ រួមមាន សុខាភិបាល ការអប់រំ ការបណ្តុះបណ្តាលនិងកន្លែងការងារ ការធានារ៉ាប់រង ការទទួលបានថាមពលកកើតឡើងវិញ និងការទទួលបានទឹកស្អាតគ្រប់គ្រាន់។ គេអាចអនុវត្តកិច្ចការនេះបាន តាមរយៈការលើកទឹកចិត្តទាំងសហគ្រាសសង្គម ដែលធ្វើការងារក្នុងទំហំតូចនិងពឹងផ្អែកលើការផ្តល់ជំនួយ និងទាំងអាជីវកម្មបរិយាប័ន្ន រួមមានក្រុមហ៊ុនធំៗដែលផ្តល់ដំណោះស្រាយផ្សេងៗដោយផ្អែកលើតម្រូវការរបស់អតិជន។ មានឧទាហរណ៍ល្អៗជាច្រើនពាក់ព័ន្ធនឹងក្រុមហ៊ុនប្រភេទនេះនៅកម្ពុជា ជាពិសេសនៅក្នុងវិស័យ កសិពាណិជ្ជកម្ម ដូចជា Amru Rice, Lyly Foods ថាមពល ដូចជា ACE solar cooking, Khmer Green Charcoal, Okra Solar, Sun-eee សិប្បកម្ម ដូចជា Artisans d'Angkor ការផ្គត់ផ្គង់ទឹក ដូចជា Khmer Water Supply Holding បច្ចេកវិទ្យាហិរញ្ញវត្ថុ (fintech) ដូចជា BanhJi ធានារ៉ាប់រង ដូចជា Forte Insurance, Prevoir លំនៅដ្ឋាន ដូចជា My Dream Home, World Bridges Social housing ជាដើម។[43]

---

[43] ESCAP and iBAN 2021.

ក្រសួង ឧ.វ.ប.ន. កំពុងរៀបចំអនុម័តយុទ្ធសាស្ត្រលើកកម្ពស់បរិយាកាសអំណោយផលដល់ធុរកិច្ចបរិយាប័ន្នក្នុងប្រទេសកម្ពុជា។ យុទ្ធសាស្ត្រនេះមានគោលដៅលើកកម្ពស់ការយល់ដឹងអំពីធុរកិច្ចបរិយាប័ន្ន បង្កើតប្រព័ន្ធទទួលស្គាល់គុណភាពធុរកិច្ចបរិយាប័ន្ន ផ្តល់សេវាកម្មបង្វឹកអាជីវកម្ម និងជួយសម្រួលដល់ការផ្តល់ថវិកាសម្រាប់ធុរកិច្ចប្រភេទនេះ។[44]

## ភាពប្រសើរឡើងនៃលទ្ធភាពទទួលបានហិរញ្ញវត្ថុ

ទិដ្ឋភាពវិនិយោគនៅកម្ពុជាកំពុងតែមានការរីកចម្រើន ស្របគ្នានឹងការកើនឡើងនៃចំនួនវិនិយោគិនក្នុងស្រុកលើធុរកិច្ចថ្មី (Local Angels Investors) មូលធនឯកជន (Private Equity) និងមូលនិធិវិនិយោគផ្សងព្រេង (Venture Capital Funds) ដែលមាននៅលើទីផ្សារ។ ការអភិវឌ្ឍគួរឱ្យកត់សម្គាល់ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ បានពង្រីកវិសាលភាពលើដំណោះស្រាយផ្នែកហិរញ្ញវត្ថុ រួមមានការវិនិយោគនិងរចនាសម្ព័ន្ធគាំទ្រតាំងពីដំណាក់កាលដំបូងបង្អស់ រហូតទៅដល់ការរៀបចំការបោះផ្សាយមូលបត្រជាសាធារណៈ (Initial Public Offering – IPO)។ កាលានុវត្តភាពគួរឱ្យកត់សម្គាល់ទាំងនេះមានសម្រាប់វិនិយោគិនយុទ្ធសាស្ត្រនៅគ្រប់កម្រិតទាំងអស់។

គំនិតផ្តួចផ្តើមមួយចំនួនរបស់រាជរដ្ឋាភិបាលត្រូវបានចាប់ផ្តើមដាក់ឱ្យដំណើរការដើម្បីធ្វើឱ្យប្រសើរឡើងនូវការទទួលបានហិរញ្ញវត្ថុ រួមមាន ធនាគារឯកទេសរបស់រដ្ឋ (Specialized state-owned bank) សម្រាប់សហគ្រាសធុនតូចនិងមធ្យម ដូចជា ធនាគារសហគ្រាសធុនតូចនិងមធ្យមត្រូវបានចាប់ផ្តើមដាក់ឱ្យដំណើរការនៅដើមឆ្នាំ២០២០ និងមូលនិធិអភិវឌ្ឍន៍សហគ្រិនភាពរបស់រាជរដ្ឋាភិបាល (សូមមើលប្រអប់ទី ៤.១)។

**ប្រអប់ទី ៤.១. វិធានការដើម្បីបង្កើនការទទួលបានហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា**

**ធនាគារសហគ្រាសធុនតូចនិងមធ្យមកម្ពុជាត្រូវបានបង្កើតឡើងជាមួយដើមទុនដំបូងចំនួន ១០០ លានដុល្លារ**

ធនាគារសហគ្រាសធុនតូចនិងមធ្យមគឺស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ជាមួយដើមទុនដំបូង ១០០ លានដុល្លារ ធនាគារសហគ្រាសធុនតូចនិងមធ្យមផ្តល់សេវាហិរញ្ញប្បទាន និងសេវាធនាគារពាណិជ្ជ ដើម្បីគាំទ្រដល់សហគ្រាសធុនតូចនិងមធ្យមក្នុងស្រុក ក្នុងគោលបំណងបង្កើនពិពិធកម្មសេដ្ឋកិច្ច និងពង្រីកទំហំនៃការនាំចេញ។ គំនិតផ្តួចផ្តើមនេះ បង្កើតឱ្យមានការបណ្តាក់ទុនរួមគ្នារវាងធនាគារសហគ្រាសធុនតូចនិងមធ្យម និងធនាគារពាណិជ្ជចំនួន ២៣ ធនាគារឯកទេសចំនួន ២ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៧ ដែលក្នុងនោះ ៥ ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។ សហគ្រាសធុនតូចនិងមធ្យមអាចខ្ចីប្រាក់ចំនួន ២០ ម៉ឺនដុល្លារសម្រាប់ជាដើមទុនប្រតិបត្តិការ និង ៣០ ម៉ឺនដុល្លារសម្រាប់ជាដើមទុនវិនិយោគ ក្នុងអត្រាការប្រាក់ប្រចាំឆ្នាំ ៧% និងមានរយៈពេល ៤ ឆ្នាំសម្រាប់សងវិញ។ ចំពោះប្រាតិភោគ គឺអាស្រ័យលើលក្ខខណ្ឌវិនិច្ឆ័យរបស់ស្ថាប័នហិរញ្ញវត្ថុ។ សហគ្រាសធុនតូចនិងមធ្យមទាំងអស់អាចដាក់ពាក្យស្នើសុំខ្ចីប្រាក់ ប៉ុន្តែត្រូវតែចុះបញ្ជីជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ដោយសារបញ្ហាកូវីដ-១៩ ប្រតិបត្តិការរបស់ធនាគារសហគ្រាសធុនតូចនិងមធ្យម បានផ្តោតលើការផ្តល់មូលនិធិសង្គ្រោះសម្រាប់សហគ្រាសធុនតូចនិងមធ្យម ដែលមានការលំបាកក្នុងការខ្ចីប្រាក់ពីធនាគារពាណិជ្ជ។ ធនាគារសហគ្រាសធុនតូចនិងមធ្យមដែលបានប្រតិបត្តិការនៅខែមេសា ឆ្នាំ២០២០ បានផ្តល់ផលប្រយោជន៍ដល់សហគ្រាសធុនតូច និងមធ្យមចំនួន ៧៥២ នៅទូទាំងប្រទេសកម្ពុជារួចហើយ។ គម្រោងផ្តល់ហិរញ្ញប្បទានដល់សហគ្រាសធុនតូចនិងមធ្យមត្រូវបានដាក់ឱ្យដំណើរការកាលពីថ្ងៃទី ១ ខែមេសា ហើយត្រូវបានធ្វើបរិវិសកម្មពេញលេញនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០។ វិស័យដែលផ្តោតសំខាន់រួម

[44] Ibid.

មាន កសិកម្ម ផលិតកម្មនិងកែច្នៃចំណីអាហារ ផលិតកម្មនៃផលិតផលក្នុងស្រុក ការផលិតវត្ថុអនុស្សាវរីយ៍និងសិប្បកម្មសម្រាប់ភ្ញៀវទេសចរណ៍ ការកែច្នៃកាកសំណល់ ការដំឡើងនិងព័ត៌មានវិទ្យា និងការស្រាវជ្រាវនិងអភិវឌ្ឍន៍ រាប់បញ្ចូលទាំងសេវាកម្មគ្រប់គ្រងព័ត៌មានវិទ្យា។

**មូលនិធិអភិវឌ្ឍន៍សហគ្រិនភាពរបស់រាជរដ្ឋាភិបាល បង្កើនធុរកិច្ចថ្មីជាមួយនឹងថវិកាប្រចាំឆ្នាំ ៥ លានដុល្លារ**

មូលនិធិដែលមានថវិកាប្រចាំឆ្នាំ ៥ លានដុល្លារនេះ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៩ និងចាប់ផ្ដើមប្រតិបត្តិការតាំងពីដើមឆ្នាំ២០២០ មានគោលដៅ គាំទ្រសហគ្រិន ធុរកិច្ចថ្មីដែលមាននវានុវត្តន៍ សហគ្រាសធុនតូចនិងមធ្យមដែលមានសក្តានុពល និងស្ថាប័នដៃគូដើម្បីអនុវត្តសកម្មភាពនវានុវត្តន៍ ព្រមទាំងបង្កើតតម្លៃបន្ថែមនៅក្នុងសេដ្ឋកិច្ចកម្ពុជា។ មូលនិធិអភិវឌ្ឍន៍សហគ្រិនភាពផ្ដល់នូវជំនួយឥតសំណង និងមូលនិធិសមធម៌ ដល់សហគ្រាស រួមទាំងសម្ភារឧបទ្ទេសភ្ជាស់ជាមួយសេវាកម្ម ដល់សហគ្រិននិងធុរកិច្ចថ្មី។ មូលនិធិនេះបានអំពាវនាវឱ្យដាក់គម្រោងស្នើសុំជាលើកដំបូងដែលបានដាក់ឱ្យដំណើរកាលពីដើមឆ្នាំ២០២០ ប៉ុន្តែដោយសារជំងឺកូវីដ-១៩ គេបានផ្ដោតការជួយគាំទ្រជាចម្បងចំពោះសហគ្រាសធុនតូច និងមធ្យមបែបប្រពៃណី ជាជាងធុរកិច្ចថ្មីដែលមាននវានុវត្តន៍ និងសហគ្រាសធុនតូច និងមធ្យម។ វិស័យអាទិភាពចម្បងៗចំនួន ៤ ដែលត្រូវផ្ដោតសំខាន់ដូចជា (១) វិស័យ ICT រួមមានបច្ចេកវិទ្យាហិរញ្ញវត្ថុ-Fintech (២) សេវាកម្ម ដូចជា ទេសចរណ៍ (៣) ការកែច្នៃកសិ-ឧស្សាហកម្ម និង(៤) ផលិតកម្ម ដូចជា កសិកម្មសម្រាប់ការនាំចេញ និងផលិតកម្មនៃកន្សោមឧស្សាហកម្មសម្រាប់ជំនួសឱ្យការនាំចូល (Import substitution)។ អ្វីដែលគួរឱ្យចាប់អារម្មណ៍ មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព ត្រូវបានគ្រប់គ្រងដោយភាពជាដៃគូរវាងរដ្ឋនិងឯកជន និងក្រុមប្រឹក្សាភិបាលដែលមានសមាសភាពទាំងអាជ្ញាធរសាធារណៈ (រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាប្រធាន) និងវិស័យឯកជន។

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (MPTC) ក៏មានបំណងធ្វើបន្ថែមទៀត តាមរយៈគំនិតផ្តួចផ្តើមគោលនយោបាយប្រកបដោយមហិច្ឆតាមួយគឺ "មូលនិធិកសាងសមត្ថភាព និង មូលនិធិស្រាវជ្រាវនិងអភិវឌ្ឍន៍" (CBRDF) ដែលទទួលបានធនធានចំនួន ១% នៃចំណូលរបស់ក្រុមហ៊ុនទូរគមនាគមន៍ចាប់តាំងពីឆ្នាំ២០១៧។ មូលនិធិ CBRDF បានបង្ហាញគំនិតផ្តួចផ្តើមជាច្រើនក្នុងភាពជាដៃគូជាមួយវិស័យឯកជនក្នុងការជំរុញធុរកិច្ចថ្មី និងសហគ្រិនភាពផ្នែកបច្ចេកវិទ្យានៅក្នុងប្រទេស។

ជារួម គេរំពឹងថា ទិដ្ឋភាពវិនិយោគនឹងមានភាពប្រសើរឡើង ដោយសារស្ថិរភាពរូបិយប័ណ្ណ ភាពងាយស្រួលនៃលំហូរមូលធន និងការបើកចំហទីផ្សារ។[45]

## សេវាកម្មកម្មសិទ្ធិបញ្ញានិងព័ត៌មានកំពុងនៅលើផ្លូវត្រូវ

ជាទូទៅការស្នើសុំប្រកាសនីយបត្រតក្កកម្ម (Patent) ត្រូវចុះបញ្ជីជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលបច្ចុប្បន្នគឺជាក្រសួងឧ.វ.ប.ន. រីឯ សិទ្ធិអ្នកនិពន្ធ (Copyrights) អាចត្រូវចុះបញ្ជីជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ ភាពជាដៃគូជាមួយការិយាល័យកម្មសិទ្ធិបញ្ញារបស់សិង្ហបុរី អនុញ្ញាតឱ្យម្ចាស់ប្រកាសនីយបត្រតក្កកម្ម និងអ្នកដាក់ពាក្យស្នើសុំនៅសិង្ហបុរី អាចចុះបញ្ជីជាមួយក្រសួងឧ.វ.ប.ន.។ នីតិវិធីតាមដានលឿនរហ័សក៏ត្រូវបានបង្កើតឡើងជាមួយនឹងអាជ្ញាធរកម្មសិទ្ធិបញ្ញារបស់ជប៉ុនផងដែរ។ ចាប់តាំងពីខែធ្នូ ឆ្នាំ២០១៦ ការការពារប្រកាស នីយបត្រតក្កកម្ម ក៏មានចែងផងដែរនៅក្នុងក្របខ័ណ្ឌនៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម។[46] គំនិតផ្តួចផ្តើមទាំងនេះឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីកិច្ចខិតខំប្រឹងប្រែងដើម្បីកែលម្អដំណើរការចុះបញ្ជី។

---

[45] Kem et al.2019

[46] See www.southeastasia-iprhelpdesk.eu/sites/default/files/bean_files/cambodia_factsheet.pdf.

ការបន្តកិច្ចខិតខំប្រឹងប្រែងដើម្បីធ្វើឱ្យប្រសើរឡើងនូវដំណើរការក្នុងប្រព័ន្ធតុលាការ នឹងផ្តល់អត្ថប្រយោជន៍ដល់ម្ចាស់កម្មសិទ្ធិបញ្ញា តាមរយៈការបង្កភាពងាយស្រួលដើម្បីពង្រឹងការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា។

ច្បាប់កម្មសិទ្ធិបញ្ញារបស់ប្រទេសកម្ពុជាមានភាពជឿនលឿនជាងបណ្តាប្រទេសសមាជិកអាស៊ានដទៃទៀត។ ច្បាប់នេះបានលើកទឹកចិត្តក្រុមហ៊ុនបរទេស ឱ្យបន្តការកែលម្អបច្ចេកវិទ្យាដល់ប្រព័ន្ធផលិតកម្មរបស់ខ្លួន។[47]

## ៤.៣ វឌ្ឍនភាពឈានឡើងនៃប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មីផ្នែកបច្ចេកវិទ្យាទំនើប

ប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មីផ្នែកបច្ចេកវិទ្យានៅកម្ពុជា មានការរីកចម្រើនយ៉ាងឆាប់រហ័សក្នុងរយៈពេលពី ៣ ទៅ ៥ ឆ្នាំចុងក្រោយនេះ។ ធុរកិច្ចថ្មីផ្នែកបច្ចេកវិទ្យាដែលសកម្ម ចំនួនជាង ៣OO គឺកំពុងដំណើរការនៅក្នុងដំណាក់កាលផ្សេងៗគ្នានៃការអភិវឌ្ឍខ្លួន។ ធុរកិច្ចថ្មីទាំងនេះ ភាគច្រើនជាប់ទាក់ទងនឹងការបង្កើតថ្នាលឌីជីថលដំបូង និងហេដ្ឋារចនាសម្ព័ន្ធ ទីផ្សារ និងអាជីវកម្មដែលផ្តោតលើបច្ចេកវិទ្យាសម្រាប់អតិថិជន។ នៅក្នុងទីផ្សារទាំងនេះអ្នកបោះជំហ៊ានដំបូងគេរួមជាមួយប្រតិបត្តិករល្អ អាចនឹងប្រមូលបានចំណែកទីផ្សារមួយភាគធំ។ កម្ពុជាបង្ហាញកាលានុវត្តភាពជាច្រើនសម្រាប់ធុរកិច្ចថ្មីផ្នែកឌីជីថល (សូមមើលប្រអប់ទី ៤.២)។

កាលានុវត្តភាពដ៏មានសក្តានុពលសម្រាប់ការអភិវឌ្ឍវិស័យ វ.ប.ន. នៅក្នុងប្រទេសគឺការធ្វើពិពិធកម្មនិងការពង្រីកមូលដ្ឋានកម្មន្តសាល ដោយការផ្លាស់ប្តូរចេញពីឧស្សាហកម្មអតិពលកម្ម ជាពិសេសសកម្មភាពពាក់ព័ន្ធនឹងផ្នែក កាត់ តម្រឹម និងដេរ ក្នុងឧស្សាហកម្មកាត់ដេរ ទៅជាឧស្សាហកម្មដែលទាមទារកម្លាំងពលកម្មជំនាញជាច្រើន បច្ចេកវិទ្យាជឿនលឿននិងឈានមុខបន្ថែម និងមានតម្លៃបន្ថែមខ្ពស់។

កាលានុវត្តភាពដ៏មានសក្តានុពលមួយទៀតគឺ វត្តមានដែលមានកម្រិតនៃបច្ចេកវិទ្យាស៊ីជម្រៅ (Deep technology) មួយចំនួនដូចជា ម៉ាស៊ីនស្វ័យសិក្សា (Machine-learning) ឬ ទិន្នន័យខ្នាតធំ (Big data) ដែលបើកឱកាសសម្រាប់អ្នកដែលមានបំណងនិងជំនាញចាំបាច់នាពេលបច្ចុប្បន្ន។

ចំនួនធុរកិច្ចថ្មីដែលកំពុងដំណើរការនៅក្នុងប្រទេសកម្ពុជា ត្រូវគេប៉ាន់ប្រមាណថាកើនឡើងទ្វេដងនៅចន្លោះឆ្នាំ២០១៩ និង ២០២២ ជាពិសេសដោយសារតែកំណើននៃការយល់ដឹងអំពីតម្រូវការឌីជីថលជាមូលដ្ឋានដូចជាពាណិជ្ជកម្មអេឡិចត្រូនិក បច្ចេកវិទ្យាហិរញ្ញវត្ថុ (Fintech) ភស្តុភារកម្ម ជាដើម និងការរីកចម្រើននៃឱកាសទីផ្សារទាក់ទងនឹងសេដ្ឋកិច្ចឌីជីថល នៅពេលដែលអ្នកប្រើប្រាស់កាន់តែយល់ដឹងពីបច្ចេកវិទ្យា និងជាសម្ទុះឆ្ពោះទៅរកបរិវត្តកម្មឌីជីថលបន្ទាប់ពីរងផលប៉ះពាល់នៃជំងឺកូវីដ-១៩។ បណ្តាក្រុមហ៊ុនបច្ចេកវិទ្យាថ្នាក់សកល ឬតំបន់ ដែលបន្តចូលមកក្នុងប្រទេសកម្ពុជាឥតឈប់ឈរ កំពុងបង្កើតឱកាសទីផ្សារ និងការបណ្តុះបណ្តាលសម្រាប់អនាគតស្ថាបនិកធុរកិច្ចថ្មី។ សហគ្រិនភាពកំពុងក្លាយជាជម្រើសអាជីពមួយ នេះបើយោងតាមការស្រាវជ្រាវទ្រង់ទ្រាយធំអំពីប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មីផ្នែកបច្ចេកវិទ្យានៅកម្ពុជា។[48] លើសពីនេះទៀត ធុរកិច្ចថ្មីថ្នាក់តំបន់មួយចំនួនទំនងជានឹងពង្រីកខ្លួនចូលមកក្នុងប្រទេសកម្ពុជា ដើម្បីស្វែងរកអតិថិជនថ្មី និងពិសោធន៍ជាមួយគ្នានឹងការសង្កេតឃើញកំណើននៃដំណើរទស្សនកិច្ចពាណិជ្ជកម្មដែលផ្តោតលើបច្ចេកវិទ្យាពីសំណាក់

[47] UNESCO 2015, p 711.
[48] Kem et al. 2019

សហគមន៍ បច្ចេកវិទ្យាក្នុងតំបន់។ ជាចុងក្រោយ ការអភិវឌ្ឍមជ្ឈមណ្ឌលភ្ញាស់និងពន្លឿន នឹងរួមចំណែកយ៉ាងធំធេងដល់ការរីកដុះដាលនៃធុរកិច្ចថ្មីៗនៅក្នុងប្រទេស។

### ប្រអប់ ៤.២. កាលានុវត្តភាពដែលមិនទាន់ប្រើប្រាស់ សម្រាប់ការបណ្ដុះធុរកិច្ចថ្មីឌីជីថលនៅប្រទេសកម្ពុជា

នៅពេលដែលការបណ្ដុះធុរកិច្ចថ្មីដំបូងនៅកម្ពុជា អាចបង្កើតភាពលេចធ្លោនៅក្នុងអាជីវកម្មតាមជំនាញរបស់ពួកគេរៀងៗខ្លួន ការស្រាវជ្រាវនានាបង្ហាញឱ្យឃើញពីកាលានុវត្តភាពគួរឱ្យកត់សម្គាល់ជាច្រើនដែលមិនទាន់ប្រើប្រាស់។

- សេវាកម្មអភិវឌ្ឍន៍ (Development Service)៖ ខណៈដែលសមត្ថភាពរបស់អ្នកអភិវឌ្ឍន៍ និងតម្រូវការរបស់អតិថិជនបច្ចុប្បន្នផ្ដោតសំខាន់ទៅលើបច្ចេកវិទ្យាសម្រាប់អ្នកប្រើប្រាស់ដូចជា ការអភិវឌ្ឍគេហទំព័រនិងកម្មវិធី (Application) តម្រូវការអភិវឌ្ឍន៍នាពេលអនាគតនឹងទាមទារឱ្យមានទាំងចំណេះដឹងបច្ចេកទេសថ្មីៗ ព្រមទាំងកម្មវិធីបច្ចេកវិទ្យាស៊ីជម្រៅ រួមមាន ស្វ័យប្រវត្តិកម្ម បច្ចេកវិទ្យាប្លុកឆេន (Blockchain) និង បច្ចេកវិទ្យាបន្ថែមទិន្នន័យលើរូបភាព(AR) បច្ចេកវិទ្យារូបភាពប្រត្យក្សនិម្មិត(VR)។ ទោះបីជាភ្នាក់ងារអភិវឌ្ឍន៍កម្មវិធីដែលមានស្រាប់អាចមិនទាន់មានសមត្ថភាពក្នុងការបង្កើតវេទិកា និងបែបបទស្តង់ដារ (Standard Protocols) ថ្មីក៏ដោយ ក្រុមហ៊ុនសេវាកម្មអភិវឌ្ឍន៍ដែលទទួលបានជោគជ័យបំផុត នឹងមានលទ្ធភាពកែសម្រួលដំណោះស្រាយ (Solutions) ដោយប្រើវេទិកាអភិវឌ្ឍន៍ដែលឈានមុខគេ។ ដើម្បីចាប់យកទីផ្សារនេះ ពួកគេត្រូវបន្តវិនិយោគលើការវិវត្តនៃជំនាញបច្ចេកទេសនិងវប្បធម៌ចែកបន្ត។
- ពាណិជ្ជកម្មអេឡិចត្រូនិកនិងភស្តុភារកម្ម៖ ការលក់តាមបណ្ដាញសង្គម (Social Selling) អាចដំណើរការទៅបាន អាស្រ័យដោយមានការរីកដុះដាលនៃបណ្ដាញទំនាក់ទំនងសង្គម ដែលមានជំនួយពីប្រព័ន្ធភស្តុភារកម្ម និងសេវាកម្មដឹកជញ្ជូន រួមជាមួយការចូលប្រើប្រាស់បាននូវវេទិកាហាងលក់ទំនិញអនឡាញ (Online Store Platforms)។ ការទូទាត់ទំនងជានឹងដំណើរការបានល្អនាពេលអនាគតដ៏ខ្លី ដែលនឹងអនុញ្ញាតឱ្យមានប្រតិបត្តិការតាមអនឡាញកាន់តែរលូនសម្រាប់អ្នកទិញនិងអ្នកលក់។ វេទិកាដែលមានស្រាប់សម្រាប់សេវាកម្មដឹកជញ្ជូនទំនិញចុងក្រោយគេ អាចត្រូវបានកែលម្អតាមរយៈការលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធ «សេដ្ឋកិច្ចចែករំលែក» (Shared Economy)។ កាលានុវត្តភាពបន្ថែមទៀតនៅក្នុងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននិងភស្តុភារកម្ម ក៏មានផងដែរក្នុងកម្រិតម៉ាក្រូ នៅទូទាំងប្រទេស។
- សេវាកម្មហិរញ្ញវត្ថុឌីជីថល (បច្ចេកវិទ្យាហិរញ្ញវត្ថុ)៖ ប្រជាជនជាច្រើនដែលមិនមានគណនីធនាគារ ឬមិនទាន់បានប្រើប្រាស់សេវាកម្មធនាគារ នឹងផ្លាស់ប្ដូរទៅប្រើប្រព័ន្ធហិរញ្ញវត្ថុផ្លូវការវិញ ដែលមួយផ្នែកធំនឹងលោតផ្លោះ (Leapfrog) ទៅប្រើទម្រង់ដំណោះស្រាយបច្ចេកវិទ្យាហិរញ្ញវត្ថុ ដែលនឹងត្រូវផ្ដល់ជូនអតិថិជននៅកម្រិតផ្សេងៗគ្នា។ ក្នុងពេលដំណាលគ្នា ធនាគារនិងស្ថាប័នមីក្រូហិរញ្ញវត្ថុចាំបាច់ត្រូវឆ្លើយតបនឹងតម្រូវការរបស់អតិថិជនសម្រាប់ឧបករណ៍ធនាគារអនឡាញ និងត្រូវបន្តស្វែងរកមធ្យោបាយដើម្បីកាត់បន្ថយថ្លៃដើម ប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព និងកាត់បន្ថយហានិភ័យនៃសូហ្វវែរសម្រាប់សហគ្រាសដែលមាននវានុវត្តន៍ (innovative Enterprise Software)។ បើតាមការបញ្ជាក់នៅក្នុងបទសម្ភាសន៍ជាច្រើនក្នុងវិស័យឧស្សាហកម្មនិងតួអង្គពាក់ព័ន្ធដទៃទៀត សេវាកម្មផ្ដល់សូហ្វវែរកម្រិតសហគ្រាស (Enterprise-level Software As-a-Service) ធនាគារនិម្មិត (Virtual Banks) ការវាយតម្លៃឥណទានបែបថ្មី និងវេទិកាផ្ដល់ប្រាក់ខ្ចីបែបឌីជីថល គឺសុទ្ធសឹងតែជាឱកាសសម្រាប់ការវិនិយោគ។ បញ្ហាសំខាន់គឺនៅត្រង់ថាតើគេអាចបង្កើតប្រព័ន្ធអេកូឡូស៊ីធនាគារមួយដែលច្របាច់បញ្ចូលគ្នាបានដែរឬទេ ក្នុងនោះរួមមាន ស្ថាប័នហិរញ្ញវត្ថុ អតិថិជន អ្នកជំនួញ និយ័តករ។

ខណៈដែលធនាគារជាតិនៃកម្ពុជាបាននិងកំពុងផ្តោតការយកចិត្តទុកដាក់ជាបណ្តើរៗលើនវានុវត្តន៍ថ្មីៗ ដូចជាបច្ចេកវិទ្យាប្លុកឆេន ធនាគារកំពុងតែបន្តស្វែងរកក្របខ័ណ្ឌគតិយុត្ត និងអនុលោមភាពសមស្រប រួមទាំងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ដែលកំពុងស្ថិតនៅក្នុងការដំណាក់កាលតាក់តែង ការគ្រប់គ្រងស្ថាប័ន និងការកាត់បន្ថយហានិភ័យជាប្រព័ន្ធ។

- ទីផ្សារឌីជីថល៖ ទីផ្សារដែលមានស្រាប់ ដូចជាការផ្សាយពាណិជ្ជកម្មខ្លីៗ បានជួយសម្រួលប្រតិបត្តិការក្នុងទម្រង់ជាវេទិកាព័ត៌មានរហូតដល់ពេលបច្ចុប្បន្ន។ ទោះយ៉ាងណាក៏ដោយ តាមរយៈកាលានុវត្តភាពនៃទិន្នន័យសង្គម (Socialized Data) និងរូបមន្តព្យាករណ៍ (Predictive Algorithms) ការស្វែងរកព័ត៌មានកាន់តែមានលក្ខណៈផ្ទាល់ខ្លួននិងចំគោលដៅ។ ការណ៍នេះជួយបង្កើនសក្តានុពលនៃវេទិកានិងទីផ្សារ នៅក្នុងការបង្កើនចំនួនប្រតិបត្តិការ ហើយទន្ទឹមគ្នានេះផ្តល់ទំនុកចិត្តក្នុងរូបភាពជាភាគីទីបី។
- ប្រព័ន្ធផ្សព្វផ្សាយ និងការផ្សាយពាណិជ្ជកម្មឌីជីថល៖ ស្របនឹងនិន្នាការសកលរបស់អ្នកប្រើប្រាស់ដែលផ្លាស់ប្តូរពីការមើលទូរទស្សន៍ ទៅជាការចូលទៅមើលព័ត៌មាននិងការកម្សាន្តតាមអនឡាញ ក្រុមហ៊ុនានាមានឱកាសកាន់កាប់ទីផ្សារតាមរយៈការធ្វើមាតិកាក្នុងស្រុក (Localized Content) និងការប្រើប្រព័ន្ធផ្សព្វផ្សាយតាមអនឡាញ។ ក្រុមហ៊ុនប្រព័ន្ធផ្សព្វផ្សាយដែលជោគជ័យត្រូវតែផ្តោតលើមាតិការឿង (Content Focused) និងទាញយកអត្ថប្រយោជន៍ពីវេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គមដែលមានស្រាប់ ធៀបនឹងការប្រកួតប្រជែងជាក់ស្តែង។
- ផលិតផលឌីជីថលលេចធ្លោ (Digital Disruptor)៖ នៅខណៈដែលការប្រកួតប្រជែងកំពុងវិវត្តនៅក្នុងវិស័យដឹកជញ្ជូន ដូចជាកម្មវិធីសម្រាប់ជួលយានជំនិះតាមទូរស័ព្ទដៃនៅក្នុងរាជធានីភ្នំពេញ និងបណ្តាខេត្តក្រុងរីកចម្រើនមួយចំនួន គេសង្កេតឃើញមានឱកាសទីផ្សារជាច្រើនដែលមិនទាន់ប្រើប្រាស់ នៅខាងក្រៅរាជធានីភ្នំពេញ។ ជាឧទាហរណ៍ ធុរកិច្ចថ្មីពាក់ព័ន្ធនឹងបច្ចេកវិទ្យាអប់រំ( Edtech) និង បច្ចេកវិទ្យាកសិកម្ម(Agritech) មានសក្តានុពលក្នុងការបម្រើអតិថិជននៅតាមតំបន់ជនបទក្នុងប្រទេស ដែលមានចំនួនប្រជាជនរស់នៅច្រើន។ ប៉ុន្តែ មានធុរកិច្ចថ្មីផ្នែកបច្ចេកវិទ្យា (Agritech) តិចតួចប៉ុណ្ណោះដែលបានពង្រីកទីផ្សាររបស់ខ្លួនឱ្យបានធំ ជាពិសេសនៅក្នុងបច្ចេកវិទ្យាជឿនលឿនដែលទាក់ទិននឹងទិន្នន័យ ដូចជាការដាំដុះ និងការផ្តោតលើទិន្នផល ឬខ្សែច្រវ៉ាក់ផ្គត់ផ្គង់ ដូចជាទំនាក់ទំនង ឬប្រតិបត្តិការរវាងកសិករ និងឈ្មួញ។ បើផ្អែកទៅលើទំហំវិស័យកសិកម្មធៀបនឹងផលិតផលក្នុងស្រុកសរុប នេះគឺជាកាលានុវត្តភាពដែលមិនទាន់ប្រើប្រាស់នៅឡើយ។ ដូចគ្នានេះដែរ ធុរកិច្ចថ្មីផ្នែកបច្ចេកវិទ្យាសុខាភិបាល (Healthtech) អាចដោះស្រាយបញ្ហាយល់ដឹងអំពីសុខភាព និងការកំណត់ឃើញរោគសញ្ញាជំងឺបានឆាប់រហ័ស តាមរយៈវេទិកាព័ត៌មានទាក់ទិននឹងការថែទាំសុខភាព ដែលឆ្លុះបញ្ចាំងពីដំណោះស្រាយដែលទទួលបានជោគជ័យខ្លាំងនៅតាមតំបន់ជនបទនិងទីផ្សារ កំពុងមានសក្តានុពលនៅក្នុងតំបន់អាហ្វ្រិកខាងលិច។

ប្រភព៖ CDRI 2019.

ថ្វីបើគុណតម្លៃ និងការអប់រំតាមបែបប្រពៃណីរបស់ប្រទេសកម្ពុជាមិនបានលើកទឹកចិត្តឱ្យហ៊ានប្រឈមនឹងហានិភ័យ និងការចាប់ផ្តើមធុរកិច្ចថ្មីក្តី ក៏គេសង្កេតឃើញមានការផ្លាស់ប្តូរនៅក្នុងចំណោមមនុស្សជំនាន់ថ្មីដែលអាចជួយគាំទ្រដល់នវានុវត្តន៍បន្ថែមទៀតនាពេលប៉ុន្មានឆ្នាំខាងមុខ។ ព្រឹត្តិការណ៍ធុរកិច្ចថ្មីយ៉ាងសកម្ម

ដែលបានរៀបចំជាង ២០ ដង កាលពីឆ្នាំ២០១៨ ការបង្កើតកន្លែងធ្វើការងាររួមគ្នានិងនវានុវត្តន៍ចំនួន ២៥ សកម្មភាពផ្សព្វផ្សាយអំពីសហគ្រិនភាពនៅក្នុងធុរកិច្ចថ្មីតាមរយៈបណ្តាញសង្គម ប្រព័ន្ធផ្សព្វផ្សាយ និងសាច់រឿងជោគជ័យរបស់សហគ្រិន ព្រមទាំងជាគំរូម៉ូឌែលអាជីវកម្ម ទាំងអស់នេះសុទ្ធតែបង្ហាញឱ្យឃើញច្បាស់ពីការផ្លាស់ប្តូរផ្នត់គំនិតក្នុងចំណោមយុវជនកម្ពុជា។ ដូចបានគូសបញ្ជាក់ខាងលើ សហគ្រិនភាពកំពុងក្លាយជាជម្រើសមួយសម្រាប់អាជីព។[49]

ដើម្បីធ្វើពិពិធកម្មទីផ្សារការងារ គេអាចប្រើកាលានុវត្តភាពផ្សារភ្ជាប់ប្រជាជនខ្មែរដែលបានធ្វើមាតុភូមិនិវត្តន៍និងមានការអប់រំពីអន្តរជាតិនិងបទពិសោធន៍វិជ្ជាជីវៈ ជាមួយនឹងការចាប់ផ្តើមធុរកិច្ចថ្មីផ្នែកបច្ចេកវិទ្យានៅក្នុងទីផ្សារក្នុងស្រុក។ ដើម្បីលុបបំបាត់គម្លាតជំនាញបច្ចេកទេស និងបង្កើតវប្បធម៌សហគ្រិនភាព ភាគច្រើននៃធុរកិច្ចថ្មីផ្នែកបច្ចេកវិទ្យានៅកម្ពុជាបានបម្រុងធនធានសម្រាប់កម្មវិធីបណ្តុះបណ្តាលផ្ទៃក្នុង និងមានឆន្ទៈឧបត្ថម្ភដល់ការបណ្តុះបណ្តាលដែលមានវិញ្ញាបនបត្រទទួលស្គាល់ដល់បុគ្គលិក ថ្វីបើគេកម្រនឹងឃើញមានការបណ្តុះបណ្តាលបែបនេះនៅក្នុងប្រទេសក៏ដោយ។[50]

អ្នកជំនាញឧស្សាហកម្មក៏បានកត់សម្គាល់ពីនិន្នាការសំខាន់មួយទៀតពាក់ព័ន្ធនឹងកំណើនប្រជាជនវ័យក្មេងដែលមានបំណងចង់បង្កើតក្រុមហ៊ុន និងចូលរួមបង្កើតធុរកិច្ចថ្មីភ្លាមៗក្រោយពីពួកគេបញ្ចប់ការសិក្សានៅថ្នាក់ឧត្តមសិក្សា ឬ មធ្យមសិក្សាក៏មាន។ ដោយសេដ្ឋកិច្ចឌីជីថលស្ថិតក្នុងដំណាក់កាលអភិវឌ្ឍន៍ តម្រូវការរបស់ឧស្សាហកម្ម និងអ្នកបច្ចេកទេសជំនាញនៅតែមានគម្លាតគួរឱ្យកត់សម្គាល់។ បន្ថែមពីលើទេពកោសល្យដែលបានទទួលការបណ្តុះបណ្តាលក្នុងស្រុក និងទោះជាមាននិស្សិតថ្មីបញ្ចប់ការសិក្សាផ្នែកបច្ចេកវិទ្យាប្រមាណ ២.០០០ ទៅ ៥.០០០ នាក់ក្នុងមួយឆ្នាំៗ និងកំពុងកើនឡើងបន្ថែមក៏ដោយ ក៏នៅមានកង្វះខាតអ្នកមានជំនាញខ្ពស់ ដែលទំនងជាបានបំពេញបន្ថែមមួយផ្នែកដោយវត្តមានរបស់ជនបរទេស និងអ្នកធ្វើការពីចម្ងាយតាមរយៈប្រព័ន្ធឌីជីថល (Digital Nomads)។ តួយ៉ាង មានធុរកិច្ចថ្មីផ្នែកបច្ចេកវិទ្យាជាច្រើន ដែលត្រូវបានបង្កើតឡើងដោយប្រើអ្នកជំនាញបច្ចេកវិទ្យាបរទេស និងតាមរយៈពលរដ្ឋកម្ពុជាវិលត្រឡប់ពីបរទេស។

## ៤.៤ ការបោះជំហានទៅមុខនៃប្រព័ន្ធអប់រំនិងស្រាវជ្រាវ

### ការអប់រំមូលដ្ឋានកំពុងមានវឌ្ឍនភាពនិងអាចជាគ្រឹះសម្រាប់ការអភិវឌ្ឍនវានុវត្តន៍ក្នុងរយៈពេល ១០ ឆ្នាំខាងមុខ

យោងតាមទិន្នន័យជាច្រើនបានបង្ហាញថា ប្រទេសកម្ពុជាសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់លើផ្នែកសំខាន់ៗជាច្រើននៅក្នុងវិស័យអប់រំ។ អត្រាបញ្ចប់ការសិក្សាបានកើនឡើងគួរឱ្យកត់សម្គាល់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៨។ ជាក់ស្តែង នៅកម្រិតបឋមសិក្សា អត្រាបញ្ចប់ការសិក្សាបានកើនឡើងពីចំនួន ៨០,០% ដល់ ៨៦,១% និងកម្រិតមធ្យមសិក្សាពីចំនួន ៣៩,០% ដល់ ៤៧,៦%។ សមាមាត្រនៃសិស្សថ្នាក់ទី ១ ដែលបានឆ្លងកាត់គ្រប់កម្រិតអប់រំកុមារតូច បានកើនឡើងពីចំនួន ៦២,០% ដល់ ៧២,០%។ ស្រដៀងគ្នានេះដែរ ប្រទេសកម្ពុជាក៏សម្រេចបានវឌ្ឍនភាពសមភាពយេនឌ័រនៅក្នុងវិស័យអប់រំតាមរយៈចំនួននៃការចុះឈ្មោះសរុប ហើយចំនួនសិស្សស្រីកំពុងកើនឡើងថែមទៀតក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ។

[49] Kem et al. 2019.
[50] Ibid.

នៅឆ្នាំ២០១០ ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តប្រព័ន្ធបែងចែកមុខវិជ្ជារវាងផ្នែកវិទ្យាសាស្ត្រពិតនិងផ្នែកវិទ្យាសាស្ត្រសង្គម ខណៈដែលសិស្សថ្នាក់មធ្យមសិក្សាទុតិយភូមិប្រមាណ ៨០% បានជ្រើសរើសយកផ្នែកវិទ្យាសាស្ត្រពិត។ នេះគឺជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការចុះឈ្មោះចូលរៀននៅថ្នាក់ឧត្តមសិក្សានៅក្នុងមុខវិជ្ជាទាក់ទងនឹងស្ទែម។ បន្ថែមទៀតនោះ ថ្មីៗនេះ រាជរដ្ឋាភិបាលបានដាក់ចេញគោលនយោបាយមួយចំនួនដូចជា ផែនទីបង្ហាញផ្លូវ ការអប់រំកម្ពុជា ឆ្នាំ២០៣០ និងគោលនយោបាយស្តីពីសាលារៀនជំនាន់ថ្មី ក្នុងគោលបំណងពង្រឹងវត្តមានរបស់នវានុវត្តន៍អប់រំនៅតាមប្រព័ន្ធសាលារៀនទាំងអស់ និងធ្វើឱ្យប្រព័ន្ធអប់រំអាចប្រកួតប្រជែងប្រកបដោយប្រសិទ្ធភាព ជាមួយប្រព័ន្ធអប់រំដទៃទៀតក្នុងតំបន់អាស៊ាន។

ទោះយ៉ាងណា ទន្ទឹមនឹងមានវឌ្ឍនភាពគួរឱ្យចាប់អារម្មណ៍ ក៏នៅតែមានបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយ ក្នុងនោះរួមមាន បញ្ហានៃការចូលរៀនសម្រាប់កុមារនៅគ្រប់កម្រិតនៃការអប់រំ និងបណ្តុះបណ្តាលប្រកបដោយសមធម៌ និងបរិយាប័ន្ន ការបន្តពីកម្រិតបឋមសិក្សាទៅមធ្យមសិក្សាបឋមភូមិ និងអត្រាបោះបង់ការសិក្សាខ្ពស់នៅកម្រិតមធ្យមសិក្សាបឋមភូមិ ក៏ដូចជាបញ្ហាគុណភាពគ្រូបង្រៀនចាប់ពីបឋមសិក្សារហូតដល់ឧត្តមសិក្សា និងការរៀនសូត្រពេញមួយជីវិត ជាដើម។

លើសពីនេះទៀត ទោះបីជាក្រសួង អប់រំ យុវជន និងកីឡា បានបោះពុម្ពផ្សាយផែនការគោលសម្រាប់ ICT ក្នុងវិស័យអប់រំ ជាយូរមកហើយក៏ដោយ ក៏ប្រទេសកម្ពុជានៅតែមានភាពយឺតយ៉ាវក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ ICT នៅក្នុងវិស័យអប់រំ ដោយសារតែកង្វះ គ្រូបណ្តុះបណ្តាល ICT ហេដ្ឋារចនាសម្ព័ន្ធបណ្តាញ (Network Infrastructure) និងឧបករណ៍បច្ចេកវិទ្យា។ យោងតាមរបាយការណ៍តាមដានត្រួតពិនិត្យការអប់រំសកល ឆ្នាំ២០១៤ មានសាលាបឋមសិក្សា និងមធ្យមសិក្សាវដ្តតែ ៨% ប៉ុណ្ណោះមានអគ្គិសនីប្រើប្រាស់បិតថេរសម្រាប់គាំទ្រដល់ការធ្វើសមាហរណកម្ម ICT ចូលទៅក្នុងថ្នាក់រៀន ហើយមានតែ ៧% ប៉ុណ្ណោះបានភ្ជាប់អ៊ីនធឺណិតប្រើប្រាស់។ ម្យ៉ាងទៀតនៅកម្ពុជា អត្រាសិស្សមានកុំព្យូទ័រនៅមានកម្រិតទាបខ្លាំងណាស់ ក្នុងនោះសិស្សមធ្យមសិក្សាចំនួន ៥០០ នាក់ ឬច្រើនជាងនេះ មានកុំព្យូទ័រមួយគ្រឿងសម្រាប់ប្រើប្រាស់រួមគ្នា។[51]

## គ្រឹះស្ថានឧត្តមសិក្សាចាប់ផ្តើមយកចិត្តទុកដាក់លើសហគ្រិនភាព និងនវានុវត្តន៍

នៅក្នុងប្រទេសកម្ពុជា ភាគច្រើននៃគ្រឹះស្ថានឧត្តមសិក្សាទាំងរដ្ឋនិងឯកជនចំនួន ១១៨ បង្រៀនមុខវិជ្ជាទាក់ទងនឹងធុរកិច្ច ហើយប្រហែល ៣០% ផ្តល់កម្មវិធីសិក្សាផ្នែកព័ត៌មានវិទ្យានិងវិស្វកម្ម។ បើទោះបីជាមុខជំនាញធុរកិច្ចទទួលបានប្រជាប្រិយភាពបំផុតក្តី ក៏ការអប់រំសហគ្រិនភាពគឺនៅតែជាកិច្ចការថ្មីថ្មោងនៅឡើយ។ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ដើម្បីឆ្លើយតបនឹងចំណាប់អារម្មណ៍កាន់តែខ្លាំងឡើងនៅក្នុងអាជីវកម្មបច្ចេកវិទ្យា មានសាកលវិទ្យាល័យឈានមុខមួយចំនួននៅរាជធានីភ្នំពេញ បានព្យាយាមភ្ជាប់សហគ្រិនភាពនិងការអប់រំបច្ចេកវិទ្យា។[52]

គំនិតផ្តួចផ្តើមសំខាន់ៗជាច្រើនបានលេចចេញជារូបរាងឡើងនាប៉ុន្មានឆ្នាំចុងក្រោយនេះ។ សាកលវិទ្យាល័យមួយចំនួន ដូចជា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាកលវិទ្យាល័យជាតិគ្រប់គ្រង វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងវិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន បានបង្កើត

[51] Konrad Adenauer-Stiftung Cambodia 2019, p 31.
[52] Kem et al. 2019, p.20.

មជ្ឈមណ្ឌលភ្ញាស់និងបណ្តុះធុរកិច្ចថ្មី ដែលមានទីតាំងក្នុងសាកលវិទ្យាល័យ ព្រមទាំងការិយាល័យភ្ជាប់ទំនាក់ទំនងសាកលវិទ្យាល័យនិងសហគ្រាស។

ផ្ទុយពីទស្សនៈយល់ឃើញនិងឯកសារមួយចំនួនធំ[53] ការរីកចម្រើនគួរឱ្យកត់សម្គាល់នៅតែមានលើការកែលម្អប្រព័ន្ធអេកូឡូស៊ីសហគ្រាសនៅក្នុងចំណោមសាកលវិទ្យាល័យ ជាពិសេសនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងសាកលវិទ្យាល័យជាតិគ្រប់គ្រង (សូមមើលប្រអប់ទី ៤.៣)។[54] សាកលវិទ្យាល័យទាំងពីរនេះមានតួនាទីសំខាន់ក្នុងប្រព័ន្ធអេកូឡូស៊ីអប់រំជាតិ។ សាកលវិទ្យាល័យមួយចំនួនកំពុងស្វែងរកគំរូផ្សេងៗសម្រាប់គាំទ្រដល់គម្រោងនិងការរៀនសូត្ររបស់និស្សិត។ សាកលវិទ្យាល័យចំនួនបួន គឺ សាកលវិទ្យាល័យជាតិគ្រប់គ្រង វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សាកលវិទ្យាល័យអន្តរជាតិផារ៉ាហ្គន (អតីតសាកលវិទ្យាល័យហ្សាម៉ាន់) និងសាកលវិទ្យាល័យពុទ្ធិសាស្ត្រ បានបង្កើតមន្ទីរពិសោធន៍នវានុវត្តន៍នៅក្នុងបរិវេណសាកលវិទ្យាល័យ ដោយមានគោលបំណងជំរុញផ្នត់គំនិតសហគ្រិនក្នុងចំណោមនិស្សិត។ ទោះជាយ៉ាងណា មជ្ឈមណ្ឌលភ្ញាស់របស់វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ត្រូវបានចាត់ទុកជាមជ្ឈមណ្ឌលដែលមានភាពជឿនលឿននិងឈានមុខបំផុត ហើយត្រូវគេយកធ្វើជាគំរូ។

សាកលវិទ្យាល័យជាតិគ្រប់គ្រងបាននិងកំពុងដំណើរការការប្រកួតប្រជែងធុរកិច្ចប្រចាំឆ្នាំ ដែលជាកម្មវិធីត្រាប់បង្ហាញតាមគំរូធុរកិច្ចថ្មី សម្រាប់និស្សិតសាកលវិទ្យាល័យ និងនិស្សិតបញ្ចប់ការសិក្សាថ្មីៗចាប់តាំងពីឆ្នាំ២០០៦ រហូតមក។ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សាកលវិទ្យាល័យន័រតុន វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន បានចាប់ដៃគូជាមួយក្រុមហ៊ុន Emerald Hub និង SmallWorld Ventures ដើម្បីអនុវត្តកម្មវិធីបង្រៀនពីរបៀបបង្កើតធុរកិច្ចថ្មី(Start-up Bootcamps) សម្រាប់និស្សិត។ សាកលវិទ្យាល័យពុទ្ធិសាស្ត្របានចាប់ដៃគូជាមួយក្រុមហ៊ុន Trybe ដើម្បីពង្រីកកន្លែងធ្វើការរួមគ្នានិងមន្ទីរពិសោធន៍នវានុវត្តន៍ ឱ្យក្លាយទៅជាមជ្ឈមណ្ឌលនវានុវត្តន៍និស្សិត។

### ប្រអប់ទី ៤.៣. ការគាំទ្រដល់សកម្មភាពសហគ្រិនភាពនៅក្នុងសាកលវិទ្យាល័យ

**ការអភិវឌ្ឍនៃប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាពនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ**

- ឆ្នាំ២០១១៖ មហាវិទ្យាល័យសិក្សាអភិវឌ្ឍន៍បង្កើតមុខវិជ្ជាមួយចំនួនស្តីពីសហគ្រិនភាពសង្គម និងនវានុវត្តន៍សម្រាប់កម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់។
- ឆ្នាំ២០១៣៖ មហាវិទ្យាល័យវិស្វកម្មបានបង្កើតមុខវិជ្ជាសហគ្រិនភាពជាផ្លូវការមួយចំនួន ដូចជា បច្ចេកវិទ្យាសហគ្រិនភាព ការគ្រប់គ្រងធុរកិច្ចនិងសហគ្រិនភាព ព្រមទាំងកម្មសិក្សា នៅក្នុងវិស័យឧស្សាហកម្មសម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រ។ មហាវិទ្យាល័យ និងដេប៉ាតឺម៉ង់ទាំងបីរបស់ខ្លួនបង្កើតបានមូលដ្ឋានគ្រឹះដ៏ល្អសម្រាប់ការផ្សារភ្ជាប់ឧស្សាហកម្មទៅក្នុងការស្រាវជ្រាវ ការអភិវឌ្ឍកម្មវិធីសិក្សា និងកម្មសិក្សា។
- ឆ្នាំ២០១៧៖ ក្រោមគម្រោងនវានុវត្តន៍សង្គមអាស៊ីអាគ្នេយ៍ អង្គភាពគាំទ្រនវានុវត្តន៍សង្គម (SISU) ត្រូវបានបង្កើតឡើងជា "មជ្ឈមណ្ឌលសម្រាប់ការស្រាវជ្រាវ ការអប់រំនិងបណ្តុះបណ្តាល ការភ្ញាស់ និងការសន្ទនាស្តីពីសហគ្រាសសង្គម សហករណ៍ នវានុវត្តន៍សង្គម ការទទួលខុសត្រូវរបស់សាជីវកម្មនៅក្នុងសង្គម (CSR) និង

[53] Sam and Dahles 2017.
[54] CDRI 2019.

អង្គការសេដ្ឋកិច្ចសង្គមទូលាយ នៅក្នុងប្រទេសកម្ពុជា និងក្នុងតំបន់។ បេសកកម្មរបស់ SISU គឺដើម្បីជួយដល់សហគ្រិនសង្គម និងអ្នកកែប្រែសង្គម (Social Changemakers) ដទៃទៀត រួមមានតួអង្គមកពីរដ្ឋាភិបាល ស្ថាប័នមិនមែនរដ្ឋាភិបាល និងវិស័យឯកជន សំដៅរួមចំណែកក្នុងការធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាមានចីរភាព និងបរិយាប័ន្ន។ SISU ត្រូវបានគ្រប់គ្រងនិងរៀបចំដោយមហាវិទ្យាល័យសិក្សាអភិវឌ្ឍន៍។ មហាវិទ្យាល័យនេះបានបង្កើតមុខវិជ្ជាសិក្សាថ្នាក់បរិញ្ញាបត្រស្តីពីសហគ្រិនភាព និងសហករណ៍។

- ឆ្នាំ២០១៩៖ មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី «តេជោ» ត្រូវបានដាក់ឱ្យដំណើរការជាទីភ្នាក់ងារជាតិដើម្បីដើរតួជាមជ្ឈមណ្ឌលភ្ញាស់ ពន្លឿន ស្រាវជ្រាវ និងអភិវឌ្ឍន៍ ព្រមទាំងកម្មវិធីចុះកម្មសិក្សា។ មជ្ឈមណ្ឌលនេះមានទីតាំងស្ថិតនៅក្នុងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក៏ប៉ុន្តែបម្រើសាកលវិទ្យាល័យទាំងអស់ តាមរយៈការភ្ជាប់ទំនាក់ទំនងរវាងសាកលវិទ្យាល័យទាំងនោះជាមួយនឹងសហគ្រាស និងជាកន្លែងសម្រាប់និស្សិតធ្វើកម្មសិក្សាស្រាវជ្រាវ និងជួបជាមួយគ្រូឧទ្ទេស (Mentors)។ ក្រៅពីបម្រើដល់និស្សិត សហគ្រាសធុនតូចនិងមធ្យមក៏ទទួលបានអត្ថប្រយោជន៍ពីសេវាកម្មរបស់មជ្ឈមណ្ឌលផងដែរ។ នៅក្នុងឆ្នាំដដែលមជ្ឈមណ្ឌលសហប្រតិបត្តិការសាកលវិទ្យាល័យនិងឧស្សាហកម្ម (UICC) ត្រូវបានបង្កើតឡើង ដោយទទួលបានការឧបត្ថម្ភថវិកាពីសហភាពអឺរ៉ុប។ UICC មានគោលបំណងបំពាក់បំប៉នដល់និស្សិត នូវជំនាញសហគ្រិនភាព ជំនាញនវានុវត្តន៍ សមត្ថភាពវប្បធម៌ចម្រុះ និងជំនាញសមត្ថនិយោជន៍(Employability Skills) ព្រមទាំងបង្កើតទំនាក់ទំនងសាកលវិទ្យាល័យនិងសហគ្រាសយ៉ាងទូលំទូលាយនៅក្នុងប្រទេសកម្ពុជា។

**ប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាពនៅសាកលវិទ្យាល័យជាតិគ្រប់គ្រង**

ចក្ខុវិស័យរបស់សាកលវិទ្យាល័យជាតិគ្រប់គ្រងគឺការប្រែក្លាយខ្លួនជាសាកលវិទ្យាល័យឈានមុខគេនៅក្នុងប្រទេសកម្ពុជាលើសហគ្រិនភាពភាព និងនវានុវត្តន៍។ ដើម្បីសម្រេចគោលដៅនេះ សាកលវិទ្យាល័យបានចាប់ផ្តើមកម្មវិធីសិក្សាថ្មីចំនួនពីរ ដូចជា កម្មវិធីថ្នាក់បរិញ្ញាបត្រជំនាញសហគ្រិនភាពនិងនវានុវត្តន៍សម្រាប់រយៈពេលបួនឆ្នាំ និងកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ ជំនាញការគ្រប់គ្រងនវានុវត្តន៍សកលសម្រាប់រយៈពេលមួយឆ្នាំ ព្រមទាំងបានបង្កើតភាពជាដៃគូជាមួយក្រុមហ៊ុនពហុជាតិ តាមរយៈសិក្ខាសាលា និងការបណ្តុះបណ្តាលអំពីនវានុវត្តន៍។

- មន្ទីរពិសោធន៍នវានុវត្តន៍ (iLab) ដើរតួនាទីជាមជ្ឈមណ្ឌលភ្ញាស់ និងជាកន្លែងសម្រាប់ការប្រកួតប្រជែងគំរូអាជីវកម្មថ្នាក់ជាតិ។ មន្ទីរពិសោធន៍នវានុវត្តន៍នេះផ្តល់ការិយាល័យធ្វើការនិងបច្ចេកវិទ្យាដែលមានលក្ខណៈទាន់សម័យបំផុត រួមទាំងការបោះពុម្ព 3D សម្រាប់គំរូដើម និងបច្ចេកវិទ្យារូបភាពប្រត្យក្សសម្រាប់ការបង្រៀននិងរៀន។ មន្ទីរពិសោធន៍នវានុវត្តន៍ជាផ្នែកមួយនៃបណ្តាញក្នុងតំបន់នៃ SISU ដែលជាឧទាហរណ៍មួយនៃភាពជាដៃគូរវាងរដ្ឋ និងឯកជន រវាងសាកលវិទ្យាល័យជាតិគ្រប់គ្រងនិងក្រុមហ៊ុន Smart Axiata ដែលជាក្រុមហ៊ុនទូរគមនាគមន៍ដ៏ធំមួយ។
- មន្ទីរពិសោធន៍នវានុវត្តន៍ (iLab) មានការរៀបចំបង្កើតធុរកិច្ចថ្មីៗជាច្រើន។ ធនាគារសៀវភៅ (Book Bank) ត្រូវបានបង្កើតឡើងដោយ MSK ដែលជានិស្សិតឆ្នាំទី ២ ផ្នែកធុរកិច្ចអន្តរជាតិ។ គោលបំណងរបស់គាត់គឺការជំរុញវប្បធម៌នៃការអាននៅទូទាំងប្រទេសតាមរយៈការផ្តល់កម្ចីសៀវភៅ និងសេវាកម្មចែកចាយ។ រ៉ូបូតដឹកមីន (Demine Robotics) ដែលឈ្នះពានរង្វាន់ជាច្រើន ត្រូវបានបង្កើតឡើងដោយ RCY ក្នុងគម្រោងឆ្នាំទី៤របស់គាត់ ដើម្បីជួយការងារដោះមីននៅកម្ពុជាឱ្យមានសុវត្ថិភាព និងប្រសិទ្ធភាព។ បច្ចុប្បន្ន រ៉ូបូតនេះកំពុងត្រូវបានប្រើប្រាស់នៅប្រទេសកាណាដា និងប្រទេសកម្ពុជា។

- ការប្រកួតប្រជែងគំរូធុរកិច្ចថ្នាក់ជាតិ គឺជាកម្មវិធីប្រកួតប្រជែងសហគ្រិនភាពសម្រាប់និស្សិតសាកលវិទ្យាល័យ និងនិស្សិតទើបបញ្ចប់ការសិក្សាថ្មីៗលើជំនាញ បច្ចេកវិទ្យា វេជ្ជសាស្ត្រនិងសុខាភិបាល ការអប់រំ កសិកម្ម និង ធុរកិច្ចទូទៅ។ ព្រឹត្តិការណ៍នេះគឺជាការប្រកួតមួយដែលដំណើរការយូរជាងគេបំផុតនៅក្នុងប្រទេសកម្ពុជា ហើយបានបង្កើនការយល់ដឹង និងក្តីរំភើបរីករាយក្នុងចំណោមនិស្សិតថ្នាក់បរិញ្ញាបត្រនៅក្នុងរាជធានីភ្នំពេញ។

គ្រាន់តែក្នុងឆ្នាំ២០១៨ កម្មវិធីបណ្តុះធុរកិច្ចថ្មីជាង ២០ ត្រូវបានរៀបចំផ្តួចផ្តើមឡើងសម្រាប់និស្សិតសាកលវិទ្យាល័យ និងនិស្សិតបញ្ចប់បរិញ្ញាបត្រ។ លើសពីនេះទៀត ដោយសារតែមានការផ្តល់មូលនិធិមកពីខាងក្រៅវិស័យសាធារណៈ និងវិស័យឯកជនកាន់តែប្រសើរឡើង ការភ្ជាប់ទំនាក់ទំនងរវាងវិស័យឧស្សាហកម្ម និងសាកលវិទ្យាល័យ បានទទួលការចាប់អារម្មណ៍ និងការប្តេជ្ញាចិត្តពីថ្នាក់ដឹកនាំស្ថាប័ន។ ដោយឡែក គេឃើញមានការបង្កើតភាពជាដៃគូផ្លូវការ និងសកម្មរវាងស្ថាប័នសិក្សា អង្គភាពអន្តរការី និងវិស័យឯកជន ក្នុងការអភិវឌ្ឍកម្មវិធីសិក្សា ការបង្កើតជាបណ្តាញទំនាក់ទំនង និងការចែករំលែកធនធាន ជាឧទាហរណ៍ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា-SmallWorld សាកលវិទ្យាល័យភូមិន្ទភ្នំពេញ-Impact Hub សាកលវិទ្យាល័យជាតិគ្រប់គ្រង-Smart Axiata ។ ភាពជាដៃគូទាំងនេះបង្កើតបានបណ្តាញទំនាក់ទំនងទាំងផ្លូវការនិងក្រៅផ្លូវការសម្រាប់ការអភិវឌ្ឍបណ្តាញសហគ្រិនភាព។ អង្គភាពអន្តរការី ដូចជា SmallWorld, Impact Hub មជ្ឈមណ្ឌលភ្ញាស់ និងបណ្តុះធុរកិច្ចថ្មី និងការិយាល័យភ្ជាប់ទំនាក់ទំនងសាកលវិទ្យាល័យនិងសហគ្រាស ផ្តល់នូវសេវាកម្មគាំទ្រផ្នែកបច្ចេកវិទ្យានិងសហគ្រិន ជួយភ្ជាប់គម្លាតទំនាក់ទំនង និងបង្កើតភាពជាដៃគូរវាងស្ថាប័នអប់រំ និងធុរកិច្ច។

ការផ្តល់មូលនិធិសាជីវកម្ម ជាពិសេសពីក្រុមហ៊ុន Smart Axiata និង EZECOM ព្រមទាំងដៃគូអភិវឌ្ឍន៍ផ្សេងៗទៀតដូចជា ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) និងសហភាពអឺរ៉ុបជាដើម បានផ្តល់លទ្ធភាពឱ្យសាកលវិទ្យាល័យអាចបំពាក់និងផ្តល់ជូននូវបរិក្ខារឧបទ្ទេស ដូចជា មន្ទីរពិសោធន៍នវានុវត្តន៍សម្រាប់និស្សិតប្រើប្រាស់ក្នុងគម្រោងបច្ចេកវិទ្យា។ រវាងឆ្នាំ២០១៣ និងឆ្នាំ២០១៩ គម្រោង Development Innovations (DI) ដែលទទួលបានមូលនិធិពី USAID និងមានគោលបំណងជួយអង្គការសង្គមស៊ីវិល ក្រុមហ៊ុនបច្ចេកវិទ្យា សហគ្រាសសង្គម និងនវានុវត្តជនវ័យក្មេងក្នុងការបង្កើតនិងប្រើប្រាស់ដំណោះស្រាយតាមរយៈ ICT និងប្រើប្រាស់ដំណើរការដែលមានលក្ខណៈនវានុវត្តន៍ដើម្បីដោះស្រាយបញ្ហាប្រឈមនៅក្នុងការអភិវឌ្ឍសម្រាប់ប្រទេសកម្ពុជា។ សេវាកម្ម និងសកម្មភាពដែលផ្តល់មូលនិធិដោយគម្រោង DI រាប់ចាប់ពីវគ្គសិក្សាជំនាញឌីជីថល រហូតដល់ការភ្ញាស់និងពន្លឿនធុរកិច្ចថ្មី និងរាប់ចាប់ពីយុទ្ធនាការនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម រហូតដល់កម្មវិធីអភិវឌ្ឍន៍អាជីពដល់យុវជន។ គំនិតផ្តួចផ្តើមទាំងអស់នេះមានគោលដៅបំពេញបន្ថែមនូវចន្លោះខ្វះខាតក្នុងការសិក្សានិងកសាងអាជីពរបស់និស្សិត ជាពិសេសសម្រាប់ការស្រាវជ្រាវនិងអភិវឌ្ឍន៍ នវានុវត្តន៍ និងការលើកកម្ពស់វប្បធម៌សហគ្រិនភាពនិងធុរកិច្ចថ្មី ដែលជាទូទៅសាកលវិទ្យាល័យនានានៅក្នុងប្រទេសខកខានមិនបានបង្រៀនជំនាញស្រាវជ្រាវ ក៏ដូចជាលើកកម្ពស់នវានុវត្តន៍នៅឡើយ។[55]

នៅឆ្នាំ២០១៨ ធនាគារពិភពលោកបានឱ្យខ្ចីថវិកាចំនួន ៩២,៥ លានដុល្លារ តាមរយៈគម្រោងកែលម្អការអប់រំឧត្តមសិក្សា (HEIP) ដើម្បីពង្រឹងគុណភាពនិងភាពជាប់ពាក់ព័ន្ធនៃថ្នាក់ឧត្តមសិក្សា និងការស្រាវជ្រាវ

---

[55] Konrad Adenauer-Stftung Cambodia, p 31.

នៅក្នុងមុខវិជ្ជាស្នែមនិងកសិកម្ម។ កម្មវិធីនេះមានសមាសភាពចំនួន ៤ រួមមាន ការកែលម្អសមត្ថភាពបង្រៀន និងការរៀន ការកែលម្អការស្រាវជ្រាវនៅក្នុងមុខវិជ្ជាស្នែមនិងកសិកម្ម ពង្រឹងអភិបាលកិច្ចតាមវិស័យនិងការគ្រប់គ្រងគម្រោង និងការឆ្លើយតបបន្ទាន់ជាយថាហេតុ។ គម្រោងនេះនឹងបញ្ចប់នៅក្នុងឆ្នាំ២០២៤។

## សមិទ្ធផលថ្មីៗនៅក្នុងវិស័យអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

រយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ គេសង្កេតឃើញមានសមិទ្ធផលមួយចំនួន ដូចជា ការអនុវត្តក្របខ័ណ្ឌគោលនយោបាយជាតិស្តីពីការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥ ក្របខ័ណ្ឌគុណវុឌ្ឍិកម្ពុជា ស្តង់ដាសមត្ថភាពថ្នាក់ជាតិនិងកម្មវិធីសិក្សាផ្អែកលើសមត្ថភាព ក្របខ័ណ្ឌទទួលស្គាល់គុណភាពនិស្សិតបញ្ចប់ការសិក្សាពីមជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈបន្តការសិក្សានៅគ្រឹះស្ថានឧត្តមសិក្សា ព្រមទាំងការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេសគំរូជាច្រើនកន្លែង ក៏ដូចជាការបង្កើតទិវាបណ្តុះបណ្តាលអប់រំ បច្ចេកទេស និងវិជ្ជាជីវៈថ្នាក់ជាតិ (ទិវាជីវេត)។

សកម្មភាពទាំងនេះគឺជាឱកាសសម្រាប់ការអភិវឌ្ឍជំនាញថ្មីៗ និងការធ្វើពិពិធកម្មទីផ្សារការងារនៅក្នុងប្រទេសកម្ពុជា។ សកម្មភាពផ្សេងទៀតអាចបន្តអនុវត្តរហូតដល់ឆ្នាំ២០២៤ ក្នុងបរិបទគម្រោងកែលម្អការអប់រំឧត្តមសិក្សា។

## ការរីកចម្រើនក្នុងវិស័យស្រាវជ្រាវនារយៈពេល ២០ ឆ្នាំចុងក្រោយ

ការស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជាមានច្រើនតែនៅតាមសាកលវិទ្យាល័យ និងគ្រឹះស្ថានស្រាវជ្រាវសាធារណៈ ដែលផលិតការបោះពុម្ពផ្សាយឯកសារផ្នែកវិទ្យាសាស្ត្រ។ ការផលិតឯកសារនេះកំពុងតែមានថាមវន្ត និងមាននិន្នាការកើនឡើងជាបន្តបន្ទាប់ទោះបីជាមានចំនួនតិចតួចនៅឡើយ ពោលគឺ ស្ទើរតែគ្មានការបោះពុម្ពផ្សាយមុនឆ្នាំ២០០០ រហូតមានការបោះពុម្ពប្រហែល ៥០០ ក្នុងឆ្នាំ២០១៨ ក្នុងនោះ ៨០% ជាអត្ថបទផ្នែកវិទ្យាសាស្ត្រ។ ប្រអប់ ៤.៤ សង្ខេបព័ត៌មានស្តីពី និន្នាការនៃការបោះពុម្ពផ្សាយនៅកម្ពុជាក្នុងរយៈពេល ២០ ឆ្នាំចុងក្រោយ។

### ប្រអប់ ៤.៤. និន្នាការនៃការបោះពុម្ពផ្សាយសំខាន់ៗនៅកម្ពុជា ពីឆ្នាំ២០០០-២០១៩

ក្នុងរយៈពេល ២០ ឆ្នាំចុងក្រោយនេះ មានការបោះពុម្ពផ្សាយផ្នែកវិទ្យាសាស្ត្រជិត ៥០០០ ជាអាទិ៍ អត្ថបទស្រាវជ្រាវ និងជំពូកនៅក្នុងសៀវភៅ ដែលមានអ្នកនិពន្ធ ឬសហអ្នកនិពន្ធ មកពីគ្រឹះស្ថានស្រាវជ្រាវកម្ពុជា។ ឯកសារប្រហែល ៨០% គឺជាអត្ថបទស្រាវជ្រាវ។*

- ប្រទេសកម្ពុជាស្ថិតនៅក្នុងចំណាត់ថ្នាក់ទី ២៣ នៅតំបន់អាស៊ី ដោយយោងតាមឯកសារផ្នែកវិទ្យាសាស្ត្រដែលបានបោះពុម្ពផ្សាយក្នុងឆ្នាំ២០១៩ និងស្ថិតនៅក្នុងចំណាត់ថ្នាក់ទី ១៩ បើផ្តោតតែលើការបោះពុម្ពផ្សាយផ្នែកវេជ្ជសាស្ត្រ។**
- សាកលវិទ្យាល័យភូមិន្ទភ្នំពេញជាគ្រឹះស្ថានកម្ពុជាតែមួយគត់ក្នុងចំណោមគ្រឹះស្ថានស្រាវជ្រាវឈានមុខទាំង ១០ ទាក់ទងនឹងការបោះពុម្ពផ្សាយដែលមានអ្នកនិពន្ធ ឬសហអ្នកនិពន្ធមកពីស្ថាប័នស្រាវជ្រាវកម្ពុជា (ឆ្នាំ ២០០០-២០១៩)។

- ប្រធានបទនៃការសិក្សាស្រាវជ្រាវសំខាន់ៗទាំង ១០ (ឆ្នាំ២០០០-២០១៩) រួមមាន វេជ្ជសាស្ត្រ វិទ្យាសាស្ត្រកសិកម្មនិងជីវសាស្ត្រ ភាពស៊ាំនិងអតិសុខុមជីវសាស្ត្រ វិទ្យាសាស្ត្រសង្គម វិទ្យាសាស្ត្របរិស្ថាន ជីវគីមីសាស្ត្រ ហ្សែននិងម៉ូលេគុលជីវសាស្ត្រ វិស្វកម្ម វិទ្យាសាស្ត្រផែនដីនិងភព គិលានុបដ្ឋាកម្ម និងពហុមុខវិជ្ជា។
- ក្នុងចំណោមអ្នកស្រាវជ្រាវឈានមុខទាំង ១០ ទាក់ទងនឹងការបោះពុម្ពផ្សាយ ដែលមកពីគ្រឹះស្ថានស្រាវជ្រាវនៅកម្ពុជា (ឆ្នាំ២០០០-២០១៩) មានពីរនាក់ជាជនជាតិខ្មែរ (D. Socheat and V. Saphonn)។***

*កំណត់សម្គាល់*

* Elsevier's Scopus, the largest abstract and citation database of peer-reviewed literature.

** The SCImago Journal and Country Rank is a publicly available portal that includes the journals and country scientific indicators developed from the information contained in the Scopus® database (Elsevier B.V.). These indicators can be used to assess and analyze scientific domains.

*** Elsevier's Scopus, the largest abstract and citation database of peer-reviewed literature.

ប្រទេសកម្ពុជាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ និងពឹងផ្អែកលើកិច្ចសហការស្រាវជ្រាវអន្តរជាតិ។ នៅចន្លោះឆ្នាំ២០០៨ ដល់ឆ្នាំ២០១៣ ៩៦% នៃអត្ថបទស្រាវជ្រាវរបស់អ្នកនិពន្ធកម្ពុជា មានការចូលរួមពីអ្នកនិពន្ធអន្តរជាតិយ៉ាងតិចម្នាក់ ដែលមានអត្រាធ្វើអាគតដ្ឋានកើនឡើង។ អ្នកនិពន្ធកម្ពុជាចាត់ទុកអ្នកវិទ្យាសាស្ត្រអាស៊ី (ប្រទេសថៃ និង ជប៉ុន) និងបស្ចិមប្រទេស (សហរដ្ឋអាមេរិក ចក្រភពអង់គ្លេស និងបារាំង) ក្នុងចំណោមអ្នកមានកិច្ចសហការជិតស្និទ្ធបំផុតរបស់ខ្លួន។[56]

ទាក់ទងនឹងបណ្តាញតភ្ជាប់ CamREN ជាបណ្តាញស្រាវជ្រាវ និងអប់រំជាតិរបស់កម្ពុជា ដែលមានឯកទេសខាងសេវាកម្មអ៊ីនធឺណិត ផ្តោតលើការគាំទ្រតម្រូវការរបស់សហគមន៍ស្រាវជ្រាវ និងអប់រំនៅកម្ពុជា។ មជ្ឈមណ្ឌលប្រតិបត្តិការបណ្តាញរបស់ CamREN មានទីតាំងស្ថិតនៅក្នុងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ តាមលក្ខន្តិកៈ សមាជិកក្រុមប្រឹក្សាភិបាលរបស់ CamREN រួមមានតំណាងមកពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងអប់រំយុវជននិងកីឡា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងរ៉ែនិងថាមពល។

## ៤.៥ លក្ខខណ្ឌនៃក្របខ័ណ្ឌអនុគ្រោះ

បន្ទាប់ពីការបោះឆ្នោតសកលឆ្នាំ២០១៨ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយទទួលបានជាតុចូលពីអគ្គនាយកដ្ឋានពន្ធដារ បានដាក់ចេញគំនិតផ្តួចផ្តើម ដើម្បីគាំទ្រដល់ធុរកិច្ចថ្មី និងមីក្រូសហគ្រាស សហគ្រាសធុនតូចនិងមធ្យម (MSMEs)។ ការផ្លាស់ប្តូរគោលនយោបាយដ៏សំខាន់មួយ ត្រូវបានអនុវត្តកាលពីខែតុលា ឆ្នាំ២០១៨ ដោយលើកលែងការយកពន្ធសម្រាប់សហគ្រាសធុនតូច និងមធ្យម រួមទាំងវិស័យបច្ចេកវិទ្យាទំនាក់ទំនងនិងព័ត៌មានដែលជាវិស័យមួយក្នុងចំណោមវិស័យអាទិភាពទាំង ៦។ សហគ្រាសធុនតូច និងមធ្យម ដែលបានចុះ បញ្ជីថ្មីទាំងអស់ អាចទទួលបានការលើកលែងពន្ធរយៈពេល ៣ ឆ្នាំ ដើម្បីទទួលបានការលើកលែងពន្ធ

[56] UNESCO 2015, p. 711.

រយៈពេល ៥ ឆ្នាំ សហគ្រាសធុនតូចនិងមធ្យមដែលចុះបញ្ជីថ្មី ត្រូវប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុកយ៉ាងតិច ៦០% និងបង្កើនចំនួនបុគ្គលិករបស់ខ្លួនចំនួន ២០% ឬមានទីតាំងស្ថិតនៅក្នុងបណ្តុំសហគ្រាសធុនតូច និងមធ្យម។

គួរឱ្យកត់សម្គាល់ផងដែរ ក្រសួងពាណិជ្ជកម្មបានអនុម័តច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងច្បាប់ស្តីពីការប្រកួតប្រជែងកាលពីឆ្នាំ២០១៩ ក្នុងគោលបំណងផ្តល់ការគាំទ្រដល់សកម្មភាពអភិវឌ្ឍន៍ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅក្នុងប្រទេសកម្ពុជា និងក្នុងតំបន់ ដោយធ្វើឱ្យផ្លូវច្បាប់មានភាពច្បាស់លាស់ជាងមុន និងពង្រឹងកិច្ចការពារអ្នកប្រើប្រាស់នៅក្នុងប្រទេស។

វិទ្យាស្ថានស្តង់ដារកម្ពុជាគឺជាស្ថាប័នស្តង់ដារជាតិដែលទទួលបន្ទុករៀបចំ និងផ្សព្វផ្សាយស្តង់ដារ និងគោលការណ៍ណែនាំរបស់កម្ពុជាសម្រាប់ផលិតផល ទំនិញ សម្ភារ សេវាកម្ម និងប្រតិបត្តិការ។ មុខងារនិងភារកិច្ចចម្បងៗរបស់វិទ្យាស្ថាន រួមមាន៖

១. រៀបចំស្តង់ដារជាតិសម្រាប់ផលិតផល ទំនិញ សម្ភារ និងសេវាកម្ម

២. អនុវត្តការវាយតម្លៃភាពអនុលោមស្របតាមបញ្ញត្តិ ដែលមានចែងក្នុងច្បាប់ស្តីពីស្តង់ដារកម្ពុជា

៣. បង្កើតនិងថែទាំមន្ទីរពិសោធន៍ បណ្ណាល័យ និងឧបករណ៍ផ្សេងទៀត ដើម្បីលើកកម្ពស់ស្តង់ដារូបនីយកម្ម និងគុណភាព

៤. បញ្ជាក់ភាពអនុលោមតាមស្តង់ដារសម្រាប់សុវត្ថិភាពផលិតផល ទំនិញ សារធាតុ សម្ភារ និងបរិក្ខារ សម្រាប់ការប្រើប្រាស់ក្នុងប្រទេស និងការនាំចូលនាំចេញ ព្រមទាំងបញ្ជាក់ភាពអនុលោមតាមស្តង់ដារ សម្រាប់ប្រព័ន្ធគ្រប់គ្រងផលិតកម្មនិងសេវាកម្ម

៥. ផ្តល់សេវាបណ្តុះបណ្តាលនិងពិគ្រោះយោបល់ដើម្បីផ្សព្វផ្សាយស្តង់ដារូបនីយកម្មនិងគុណភាព

៦. ទទួលស្គាល់ មន្ទីរពិសោធន៍ សម្ភារឧបទ្ទេស និងឧបករណ៍ផ្សេងៗទៀតរបស់អង្គភាពក្នុងនិងក្រៅប្រទេស

៧. ជួយ និងការពារអ្នកប្រើប្រាស់លើបញ្ហាសុវត្ថិភាពនិងគុណភាពទំនិញ ព្រមទាំងសេវាកម្ម

៨. សហការជាមួយអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធនឹងផ្នែកឧស្សាហកម្ម ពាណិជ្ជកម្ម អង្គការនានា ដើម្បីធានាការអនុវត្តស្តង់ដារ។

វិទ្យាស្ថានស្តង់ដារកម្ពុជាបានចូលរួមនៅក្នុងកម្មវិធីប្រទេសសម្ព័ន្ធគណៈកម្មការបច្ចេកទេសអគ្គិសនីអន្តរជាតិ (IECACP) និងជាសមាជិកនៃគណៈកម្មាធិការពិគ្រោះយោបល់អាស៊ានស្តីពីស្តង់ដារនិងគុណភាព (ACCSQ)។ ប្រទេសកម្ពុជាគឺជាសមាជិកបរិវិសកររបស់ ISO ចាប់តាំងពីខែមករា ឆ្នាំ១៩៩៥ និងជាសមាជិកឆ្លើយឆ្លង ចាប់តាំងពីដើមឆ្នាំ២០១៦រហូតមក។

# ជំពូកទី ៥

# ចំណុចខ្សោយនៃប្រព័ន្ធនវានុវត្តន៍ជាតិ

ប្រព័ន្ធនវានុវត្តន៍ជាតិកម្ពុជាមានចំណុចខ្សោយមួយចំនួន ដូចជា បញ្ហាប្រឈមនៅក្នុងអភិបាលកិច្ចនៃ វ.ប.ន. ប្រព័ន្ធអេកូឡូស៊ីឧស្សាហកម្មដែលគ្មានតុល្យភាព ព្រមទាំងកង្វះខាតធនធានមនុស្សនិងការបង្កើតចំណេះដឹង (សូមមើលរូបភាពទី ៥.១)។ ចំណុចខ្សោយទាំងនេះអាចកម្រិតផលជះនៃអន្តរាគមន៍គោលនយោបាយ ដូច្នេះ គេចាំបាច់ត្រូវចាត់អាទិភាពលើគំនិតផ្តួចផ្តើមដែលត្រូវបង្កើតឡើងដើម្បីដោះស្រាយបញ្ហាទាំងនោះ ក្នុងរយៈពេល ១០ ឆ្នាំខាងមុខ។

**រូបភាពទី ៥.១. ចំណុចខ្សោយរបស់ប្រព័ន្ធនវានុវត្តន៍ជាតិកម្ពុជា**




*កំណត់សម្គាល់៖* ពណ៌ក្រហមបង្ហាញពីសមាសភាពដែលមានចំណុចខ្សោយជាងសមាសភាពផ្សេងៗ។

## ៥.១ បញ្ហាប្រឈមនៅក្នុងអភិបាលកិច្ចផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

### កង្វះវប្បធម៌សម្របសម្រួលក្នុងចំណោមក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល

នវានុវត្តន៍កើតចេញពីបណ្តាញទំនាក់ទំនង កិច្ចសហការ និងការផ្លាស់ប្តូរគ្នានូវទស្សនៈ ចំណេះដឹងវិទ្យាសាស្ត្រ រវាងបុគ្គល សកម្មភាពឆ្លងអង្គភាព ក៏ដូចជាឆ្លងវិស័យ។ ក៏ប៉ុន្តែ ស្ថាប័នរាជរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជាខ្វះការសម្របសម្រួល។ ក្រសួងដែលចូលរួមក្នុងកិច្ចសម្ភាសន៍បានលើកឡើងពីការលំបាកក្នុងការប្រាស្រ័យទាក់ទងគ្នានៅក្នុងចំណោមក្រសួង-ស្ថាប័នរដ្ឋ។ ការបែងចែកភារកិច្ចជូនក្រសួង-ស្ថាប័នទាំង ១១ ឱ្យទទួលខុសត្រូវលើវិស័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា បង្កឱ្យមានបញ្ហាប្រឈមជាច្រើនដល់ប្រសិទ្ធភាពនៃការអភិវឌ្ឍគោលនយោបាយនិងអភិបាលកិច្ច។ បើទោះបីជាមានតឹកតាងបញ្ជាក់ពីកំណើនកិច្ចសហការរវាងស្ថាប័នគន្លឹះផ្នែកកសិកម្មក្តី ដូចជា វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា និងសាកលវិទ្យាល័យភូមិន្ទកសិកម្មជាដើម ក៏នៅតែមានការលំបាកក្នុងការពង្រីកកិច្ចសហការប្រភេទនេះទៅដល់ស្ថាប័នដទៃទៀតដែរ។[57]

អភិបាលកិច្ចនៃប្រព័ន្ធនវានុវត្តន៍ជាតិកម្ពុជានៅតែមានលក្ខណៈបែកខ្ញែកគ្នានៅឡើយក្នុងចំណោមក្រសួង-ស្ថាប័ននានា ចំណែកឯតួនាទីរបស់ក្រសួង ឧ.វ.ប.ន. ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក៏ដូចជាតួនាទីរបស់គណៈកម្មាធិការអាស៊ាននៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក៏មិនទាន់បានកំណត់ឱ្យច្បាស់លាស់ដោយភាគីពាក់ព័ន្ធនៅឡើយទេ។

### សហគ្រាសធុនតូច និងមធ្យមដែលមិនចុះបញ្ជីផ្លូវការនៅតែជាបញ្ហាប្រឈម

សហគ្រាសធុនតូច និងមធ្យមជាច្រើននៅកម្ពុជានៅតែមានការស្ទាក់ស្ទើរ ក្នុងការរៀបចំចុះបញ្ជីផ្លូវការ។ ជាលទ្ធផល គេអាចដឹងពីតម្រូវការ និងអាចរកទិន្នន័យបានតិចតួចណាស់ ទាក់ទិននឹងសហគ្រាសក្រៅផ្លូវការទាំងនោះ ដែលការណ៍នេះជាឧបសគ្គដល់អន្តរាគមន៍របស់វិស័យសាធារណៈ។ បើយោងតាមសម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា (FASMEC) សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជាមានចំនួនប្រមាណ ៥៣០ ០០០។[58] ក៏ប៉ុន្តែ ដោយសារតែការអនុលោមទៅតាមបទបញ្ញត្តិនៅមានកម្រិត និងការអនុវត្តច្បាប់មិនទាន់ស្មើភាព ជាហេតុនាំឱ្យសហគ្រាសធុនតូច និងមធ្យមប្រមាណជា ៣៩ ១៤១ ប៉ុណ្ណោះបានចុះបញ្ជីនៅក្រសួងឧស្សាហកម្ម និងសិប្បកម្មកាលពីចុងឆ្នាំ២០១៦។[59] ការអនុលោមទៅតាមបទបញ្ញត្តិនៅមានកម្រិតទាបបានបង្កការលំបាកខ្លាំងនៅក្នុងការគាំទ្រសហគ្រាសធុនតូច និងមធ្យម ព្រមទាំងរឹតត្បិតសកម្មភាពរបស់រដ្ឋក្នុងការជួយគាំទ្រនវានុវត្តន៍ ក៏ដូចជាការស្រាវជ្រាវនិងអភិវឌ្ឍន៍របស់ផ្នែកឯកជន។ ជាពិសេស គេនឹងជួបការលំបាកក្នុងការរៀបចំឧបករណ៍និងកម្មវិធីគាំទ្រ ឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់សហគ្រាសធុនតូច និងមធ្យមដែលមិនបានចុះបញ្ជីផ្លូវការ។

### ការប្រែប្រួលនាពេលថ្មីៗក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្មកំពុងផ្តល់អត្ថប្រយោជន៍ដល់អ្នកមានជីវភាពលើបន្ទាត់ក្រីក្រ

---

[57] Ibid.

[58] Phnom Penh Post 2017.

[59] Ministry of Industry and Handicraft 2016.

ខណៈពេលភាពក្រីក្រនៅប្រទេសកម្ពុជាបន្តថយចុះ កត្តាជំរុញការកាត់បន្ថយភាពក្រីក្រកំពុងតែប្រែប្រួល។ ទោះបីជាប៉ុន្មានឆ្នាំចុងក្រោយមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្តី ក៏ការកាត់បន្ថយភាពក្រីក្រនៅ ចន្លោះឆ្នាំ ២០១៣-២០១៧ ទាបជាងចន្លោះឆ្នាំ២០០៩-២០១៣ មួយផ្នែកធំគឺដោយសារតែកំណើនសេដ្ឋកិច្ចបានផ្តល់ផលប្រយោជន៍ដល់អ្នកមានជីវភាពលើបន្ទាត់ក្រីក្រច្រើនជាង។ ទន្ទឹមនឹងនេះដែរ ភាពក្រីក្រនៅក្នុងទីក្រុងបន្តនៅទ្រឹង បើធៀបទៅនឹងរយៈពេលមុន។ តួយ៉ាង ភាគរយនៃការប្រើប្រាស់ក្នុងមនុស្សម្នាក់បានកើនតែ ១៣% ប៉ុណ្ណោះនៅក្នុងចំណោមប្រជាជន ៤០% ដែលមានចំណូលទាប ក្នុងចន្លោះឆ្នាំ២០១៣-២០១៧ ប៉ុន្តែវាមានកំណើនដល់ទៅ ២២% ក្នុងចំណោមប្រជាជន ៦០% ដែលមានចំណូលខ្ពស់។ ប្រាក់ឈ្នួលក្រៅពីវិស័យកសិកម្មបានដើរតួនាទីសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រចន្លោះឆ្នាំ២០១៣-២០១៧ បើប្រៀបធៀបនឹងឆ្នាំ២០០៩-២០១៣ ដែលពេលនោះកសិកម្មលក្ខណៈគ្រួសារជាកត្តាចម្បងក្នុងការកាត់បន្ថយភាពក្រីក្រ។[60]

កំណើននៃការវិនិយោគក្នុងប្រព័ន្ធនវានុវត្តន៍ជាតិ ដែលភាគច្រើនប្រមូលផ្តុំតែនៅក្នុងតំបន់ទីក្រុង អាចធ្វើឱ្យមានវិសមភាពកាន់តែខ្លាំងឡើងរវាងប្រជាជននៅទីក្រុងនិងទីជនបទ ក៏ដូចជាបង្កើនឱ្យមានអតុល្យភាពភូមិសាស្ត្រផងដែរ។

## ៥.២ ប្រព័ន្ធអេកូឡូស៊ីឧស្សាហកម្មមួយដែលគ្មានតុល្យភាព

នៅប្រទេសកម្ពុជា មូលដ្ឋានឧស្សាហកម្មមានលក្ខណៈប្រហោងកណ្តាល (missing middle) ដែលភាគរយដ៏តិចតួចនៃសហគ្រាសធុនធំគឺតំណាងឱ្យភាគច្រើននៃផលរបរ និងការបង្កើតការងារ។ ចំនួនអាជីវកម្មមិនបានចុះបញ្ជីផ្លូវការក្នុងប្រទេស គឺមានចំនួនច្រើន។

សហគ្រាសធុនតូច និងមធ្យមភាគច្រើនមានលក្ខណៈប្រពៃណីដែលនឹងជួបការលំបាកក្នុងទំនើបកម្ម។ បើប្រៀបធៀបជាមួយប្រទេសជិតខាង កម្ពុជាស្ថិតក្នុងដំណាក់កាលដំបូងនៃការដាក់បញ្ចូលឌីជីថលនៅក្នុងធុរកិច្ច។[61] នៅក្នុងបរិបទនេះ គោលនយោបាយសាធារណៈគួរតែផ្តោតលើការលើកកម្ពស់សហគ្រិនជំនាន់ថ្មី ការធ្វើឌីជីថលកម្ម (Digitizing) សហគ្រាសធុនតូច និងមធ្យម និងបង្កបរិយាកាសអំណោយផល។ ក្នុងចំណោមសហគ្រាសធុនតូច និងមធ្យមចំនួន ៥៩០ ០០០ មានធុរកិច្ចថ្មីផ្នែកបច្ចេកវិទ្យាដែលសកម្មប្រហែល ២០០ ទៅ ៣០០ តែប៉ុណ្ណោះ។

លើសពីនេះ កម្ពុជាមានប្រជាជនច្រើនលើសលប់រហូតដល់ ៨០% រស់នៅទីជនបទ។ ជារចនាសម្ព័ន្ធនវានុវត្តន៍អភិវឌ្ឍទៅបាន លុះត្រាតែមានបណ្តាញនិងហេដ្ឋារចនាសម្ព័ន្ធស្រាវជ្រាវនិងអភិវឌ្ឍន៍ ព្រមទាំងបណ្តុំសហគ្រាស ដែលបច្ចុប្បន្នច្រើនតែមាននៅតាមតំបន់ទីក្រុង។ ដូចនេះ ភាពមិនស៊ីចង្វាក់គ្នារវាងទីក្រុងដែលមានការស្រាវជ្រាវនិងអភិវឌ្ឍន៍ និងទីជនបទដែលមានប្រជាជនរស់នៅច្រើន បង្កឱ្យមានការរាំងស្ទះដល់ការអភិវឌ្ឍវិស័យ វ.ប.ន.។

តំបន់នានាក្នុងប្រទេសដែលខ្វះលទ្ធភាពចូលទៅកាន់ទីផ្សារ ជាទូទៅដើរយឺតជាងតំបន់ដទៃទៀត។ ជាក់ស្តែង រាជធានីភ្នំពេញ និងបណ្តាខេត្តជុំវិញ គឺជាតំបន់ដែលមានសេដ្ឋកិច្ចរស់រវើកជាង។ ខេត្ត ដែលមាន

[60] World Bank 2019 , p13-14.
[61] Pidor 2018.

សក្ដានុពលខ្ពស់ផ្នែកពាណិជ្ជកម្ម និងមានលទ្ធភាពទទួលប្រយោជន៍ពីសេដ្ឋកិច្ចសេរីរបស់កម្ពុជា បានលូតលាស់យ៉ាងឆាប់រហ័សក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ដែលរួមមាន ខេត្តនៅទិសអាគ្នេយ៍ជាប់ព្រំដែនវៀតណាម ខេត្តនៅជាប់កំពង់ផែក្រុងព្រះសីហនុ និងខេត្តផ្សេងទៀតនៅតាមបណ្ដោយព្រំដែនថៃ។

ការបែកខ្ញែកគ្នារវាងធុរកិច្ចថ្មី និងសេដ្ឋកិច្ចកម្ពុជាអាចជាការគំរាមកំហែងមួយផ្សេងទៀត។ ភាគច្រើនលើសលប់នៃធុរកិច្ចថ្មីគឺផ្ដោតលើដំណោះស្រាយនៅក្នុងទីក្រុង ដោយមានផលិតផលតិចតួចណាស់ដែលផ្ដោតលើទីផ្សារធំៗ ឬទីផ្សារជនបទ។ ចំណុចនេះក៏ដូចគ្នា ចំពោះដំណោះស្រាយសម្រាប់ក្រុមអ្នកប្រើប្រាស់ដែលមានកម្រិតសង្គមសេដ្ឋកិច្ចទាប បើទោះជាមានការជ្រៀតចូលច្រើននៃទូរស័ព្ទឆ្លាតវៃ និងទិន្នន័យដែលមានតម្លៃថោកក៏ដោយ។ នេះគឺជាឱកាសបន្ថែម សម្រាប់ការពិចារណាចូលទីផ្សារនាពេលអនាគត។ ទោះបីជាថ្នាល កម្មវិធី និងសេវាកម្មជាច្រើនមានទម្រង់ពីរភាសា ឬភាសាខ្មែរទាំងស្រុងក្ដី ក៏ភាគច្រើននៅតែប្រើដំណោះស្រាយទូរស័ព្ទដែលជាប្រព័ន្ធភាសាអង់គ្លេសដដែល។

ពិពិធកម្មក្នុងប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាក៏ជាបញ្ហាប្រឈមមួយទៀតដែរនៅក្នុងប្រទេសកម្ពុជា។ ជាក់ស្ដែង ជាង ៨០% នៃស្ថាបនិកធុរកិច្ចថ្មីផ្នែកបច្ចេកវិទ្យាដែលបានស្ម័គ្រចិត្តចូលរួមជាអ្នកផ្ដល់ទិន្នន័យដល់ការស្រាវជ្រាវរបស់ Mekong Strategic Partners និង Raintree Development ស្ដីអំពី ប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាកម្ពុជា គឺសុទ្ធតែជាបុរស។ ខណៈដែលការស្រាវជ្រាវនេះពុំមានស្ថាបនិកជាស្ត្រីចូលរួមបានច្រើន វាបង្ហាញថាភាពលម្អៀងផ្នែកយេនឌ័រទំនងជាបញ្ហាខ្លាំងមួយក្នុងចំណោមក្រុមធុរកិច្ចថ្មី។

ជាចុងក្រោយ កត្តាជះឥទ្ធិពលខាងក្រៅ ដូចជាការវិនិយោគផ្ទាល់ពីបរទេស និងប្រទេសដៃគូអភិវឌ្ឍន៍គឺមានសារសំខាន់ណាស់ចំពោះសង្គមកម្ពុជា។

ខណៈដែលកត្តាថាមវន្តខាងលើនេះអាចមិនមែនជារឿងថ្មីក្ដី ក៏កម្ពុជាចាំបាច់ត្រូវដោះស្រាយបញ្ហាប្រឈមខាងពាណិជ្ជកម្មទាំងនេះ សំដៅឈានទៅកសាងសេដ្ឋកិច្ចឌីជីថលដោយជោគជ័យ។ ដើម្បីឱ្យមានចីរភាព និងគុណតម្លៃពិតសម្រាប់សេដ្ឋកិច្ចកម្ពុជា ប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាត្រូវកសាងអ្នកមានទេពកោសល្យក្នុងស្រុកសម្រាប់បញ្ចៀសបញ្ហាប្រឈមដូចអ្វីដែលបានកើតឡើងនៅអនុតំបន់សាហារ៉ាអាហ្វ្រិក ដែលមូលនិធិទុនផ្សងព្រេងសរុបផ្ដល់ទៅឱ្យស្ថាបនិកដែលមានដើមកំណើតនៅក្នុងតំបន់មានត្រឹមតែ ៩% ប៉ុណ្ណោះ ធៀបនឹងស្ថាបនិកបរទេសដែលបានបង្កើតធុរកិច្ចថ្មីនៅក្នុងទីផ្សារ។ ការជម្នះលើបញ្ហាប្រឈមទាំងនេះ តម្រូវឱ្យមានដំណោះស្រាយពីវិស័យរដ្ឋ និងឯកជន ក្រោមរូបភាពជាដៃគូ ដើម្បីឈានទៅសម្រេចបាននូវបរិយាកាសពាណិជ្ជកម្មសមប្រកបមួយ។

## ៥.៣ កង្វះវប្បធម៌វិទ្យាសាស្ត្រនិងសហគ្រិនភាព ជំនាញវិជ្ជាជីវៈ និងការស្រាវជ្រាវមានគុណភាព

### ភាពទន់ខ្សោយនៃវប្បធម៌វិទ្យាសាស្ត្រ ឌីជីថល និងសហគ្រិនភាព

ការយល់ដឹងអំពីនវានុវត្តន៍ និងវិទ្យាសាស្ត្រនៅក្នុងប្រទេសកម្ពុជានៅតែមានកម្រិត។ ជាងនេះទៅទៀត បទដ្ឋានសង្គមពាក់ព័ន្ធនឹងទំនាក់ទំនងយេនឌ័រ កំពុងបន្តជាឧបសគ្គរាំងដល់ការអភិវឌ្ឍសក្ដានុពលរបស់ស្ត្រី និងការផ្ដល់សិទ្ធិអំណាចក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច សាធារណៈ និងនយោបាយ។ ស្ត្រីចូលរួមក្នុងទីផ្សារពលកម្មផ្លូវការច្រើនជាងបុរស ដែលមាន ៥៦% នៃនិយោជិតសរុប ដែលត្រូវជា ៨៥% នៃកម្លាំងពលកម្មក្នុងវិស័យ

កាត់ដេរ។[62] ក៏ប៉ុន្តែ គម្លាតយេនឌ័រនៅមានខ្លាំង ជាពិសេសក្នុងកម្រិតប្រាក់ចំណូល និងគុណភាពការងារ។ ស្ត្រីភាគច្រើនក្នុងវិស័យកាត់ដេរធ្វើការពាក់ព័ន្ធនឹងការផ្គុំ ឬដំឡើងផលិតផល ខណៈដែលបុរសធ្វើការពាក់ព័ន្ធនឹងការងារត្រួតពិនិត្យគុណភាព និងការងារគ្រប់គ្រង ដែលមានប្រាក់ចំណូលខ្ពស់ជាង។ នៅក្នុងឆ្នាំ២០១៤ គេបានរកឃើញថា គម្លាតរកប្រាក់ចំណូលរវាងបុរសនិងស្ត្រីបានកើនដល់ ៣០% ក្នុងចំណោមអ្នកដែលមានការអប់រំទាប។[63] ផ្នត់គំនិតទូទៅរបស់អាណាព្យាបាលនៅតាមជនបទចំពោះការអប់រំកូនស្រី បានធ្វើឱ្យការចូលរួមរបស់ស្ត្រីក្នុងវិស័យស្ទែមមានកម្រិតទាប។

ប្រជាជនខ្មែរមិនសូវចង់ទទួលយកហានិភ័យ ដោយសារតែវិធីសាស្ត្រអប់រំកូនចៅតាមបែបប្រពៃណី និងការអប់រំសិស្សនៅតាមសាលារៀន មិនសូវលើកទឹកចិត្តឱ្យមានការចោទសួរ និងហ៊ានទទួលយកហានិភ័យ។ ការសិក្សាជាច្រើនបានបង្ហាញថា ផ្នត់គំនិតមិនហ៊ានទទួលយកហានិភ័យ គឺជាឧបសគ្គដល់នវានុវត្តន៍។ ការស្រាវជ្រាវមួយបានរកឃើញថា នៅកម្ពុជា នវានុវត្តន៍និងការទទួលយកហានិភ័យ មិនមានច្រើនទេ។[64] ការចៀសវាងមិនចង់ពាក់ព័ន្ធនឹងសហគ្រាសដែលមានហានិភ័យ ក្នុងការជួយពង្រីកវិសាលភាពវិនិយោគសង្គមជាដើម តាមរយៈថ្នាក់ឧត្តមសិក្សា ជាកត្តាជំរុញនាំឱ្យមានការជ្រើសរើសយកអាជីពវិជ្ជាជីវៈជាងធុរកិច្ច។[65]

ដើម្បីត្រៀមខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល សហគ្រាសភាគច្រើនបញ្ជាក់ថា ខ្លួនប្រហែលជាវិនិយោគលើការកែលម្អផលិតផល និងសេវាកម្មដែលមានស្រាប់ និងលើការអភិវឌ្ឍសមត្ថភាពបុគ្គលិក។ ប៉ុន្តែសហគ្រាសស្ទើរតែពាក់កណ្ដាលបានឱ្យដឹងថា ពួកគេពុំមានផែនការច្បាស់លាស់សម្រាប់ការបណ្ដុះបណ្ដាលទេ ហើយសហគ្រាសប្រហែល ៣០% ផ្សេងទៀតបញ្ជាក់ថា ពួកគេនឹងផ្ដល់ការបណ្ដុះបណ្ដាលតាមរយៈការងារជាក់ស្ដែង។ ស្ទើរតែគ្រប់សហគ្រាសទាំងអស់បានសម្ដែងក្ដីព្រួយបារម្ភថា បុគ្គលិករបស់ពួកគេនឹងលាឈប់ពីការងារបន្ទាប់ពីបានទទួលការបណ្ដុះបណ្ដាល[66]។ ដូច្នេះ គេរំពឹងថា សហគ្រាសទាំងនោះនឹងមិនវិនិយោគគ្រប់គ្រាន់ទេលើការបណ្ដុះបណ្ដាល និងការអភិវឌ្ឍជំនាញ ដែលធ្វើឱ្យកម្ពុជាប្រឈមក្នុងការពង្រីកសក្ដានុពលនវានុវត្តន៍របស់ខ្លួនបានពេញលេញ។

## ប្រព័ន្ធអប់រំនៅថ្នាក់ឧត្តមសិក្សាមិនបានផ្ដល់ជំនាញគ្រប់គ្រាន់ត្រូវនឹងតម្រូវការទីផ្សារដល់និស្សិតបញ្ចប់ការសិក្សា

ស្ថានភាពបច្ចុប្បន្ននៃវិស័យអប់រំថ្នាក់ឧត្តមសិក្សា បង្ហាញពីភាពមិនស៊ីចង្វាក់គ្នាដ៏គួរឱ្យព្រួយបារម្ភរវាងការអប់រំ និងការងារ ក៏ដូចជាកង្វះវប្បធម៌វិទ្យាសាស្ត្រ។ យោងតាមរបាយការណ៍ជាច្រើន ជំនាញសិក្សាដែលពេញនិយមជាងគេក្នុងចំណោមនិស្សិតសាកលវិទ្យាល័យនៅក្នុងប្រទេសកម្ពុជា គឺជំនាញវិទ្យាសាស្ត្រសង្គម និងជំនាញដែលពាក់ព័ន្ធនឹងធុរកិច្ច។ មាននិស្សិតតិចតួចណាស់ចាប់យកជំនាញវិទ្យាសាស្ត្រ វិស្វកម្ម និងកសិកម្ម ដែលជាជំនាញចាំបាច់សម្រាប់ជំរុញឱ្យមានកំណើនសេដ្ឋកិច្ចកម្ពុជា។ លើសពីនេះ គេនៅតែមានការព្រួយបារម្ភអំពីគុណភាពសិក្សានៅថ្នាក់ឧត្តមសិក្សាក្នុងកម្រិតទូទាំងប្រទេសផងដែរ។

កង្វះខាតជំនាញនៅក្នុងទីផ្សារការងារកំពុងកើនឡើងជាលំដាប់នៅប៉ុន្មានឆ្នាំចុងក្រោយនេះ។ ការស្រាវជ្រាវ ដែលបានរៀបចំឡើងដោយទីភ្នាក់ងារជាតិមុខរបរ និងការងារ កាលពីឆ្នាំ២០១៧ បានរកឃើញថា

---

[62] Interntional Labour Organization, 2019.
[63] World Bank, 2016a.
[64] Lyne, Ngin and Santoyo-Rio 2013.
[65] Smith-Hefiner 1999.
[66] Konrad-Adenauer-Stiftung Cambodia 2019.

និយោជក ៤៧,៥% ជួបប្រទះការលំបាកក្នុងការជ្រើសរើសបុគ្គលិក ដែលស្ទើរតែពាក់កណ្តាល បណ្តាលមកពីអ្នកដាក់ពាក្យ ភាគច្រើនពុំមានជំនាញដែលត្រូវការ ខ្វះបទពិសោធន៍ការងារ ឬខ្វះគុណវុឌ្ឍិ។

ការលំបាកក្នុងការជ្រើសរើសបុគ្គលិក ត្រូវបានលើកឡើងច្រើនជាងគេបំផុតនៅក្នុងវិស័យសេវាកម្មស្នាក់អាស្រ័យ ដូចជា សេវាកម្មស្នាក់អាស្រ័យរយៈពេលខ្លី និងកន្លែងបោះតង់ជាដើម ដែលនិយោជក ៧៧,៩% បានបញ្ជាក់ពីការលំបាកក្នុងជ្រើសរើសបុគ្គលិក បន្ទាប់មក ៦៤,១% ក្នុងផ្នែក ភស្តុភារកម្ម ឃ្លាំង និងការដឹកជញ្ជូន ៥៨,៣% ក្នុងផ្នែកសុខាភិបាល ៥៣% ក្នុងផ្នែកការអប់រំ ៥១,៧% ក្នុងផ្នែកចំណីអាហារនិងភេសជ្ជៈ និង ៥០,៧% ក្នុងផ្នែកហិរញ្ញវត្ថុនិងធានារ៉ាប់រង។ ការជ្រើសរើសបុគ្គលិកដែលមានការលំបាកតិចតួចបំផុតគឺ ផ្នែក ICT ៣៦,៥% ផ្នែកសំណង់ ៣៤,៤% ផ្នែកកាត់ដេរ ស្បែកជើង និងសម្លៀកបំពាក់ ២៩% ព្រមទាំងផ្នែកកៅស៊ូ និងប្លាស្ទិក ៧,៣%។[67]

ជំនាញដែលនិយោជកត្រូវការបំផុតរួមមាន ជំនាញភាសាបរទេស ជាពិសេសភាសាអង់គ្លេស ជំនាញបច្ចេកទេស ឬអនុវត្តន៍ ការប្រាស្រ័យជាមួយអតិថិជន ជំនាញទំនាក់ទំនងសម្តី ជំនាញដោះស្រាយបញ្ហានិងការងារជាក្រុម។ អ្នកស្វែងរកការងារធ្វើ ដែលពុំមានជំនាញមួយ ឬច្រើនតាមតម្រូវការរបស់និយោជក នឹងជួបការលំបាកក្នុងការទទួលបានការងារ។

ស្ទើរតែទាំងអស់នៃអ្នកចូលរួមឆ្លើយសំណួរក្នុងការសិក្សាមួយនៅឆ្នាំ២០១៩ ស្តីអំពី "ប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាពនិងនវានុវត្តន៍នៅប្រទេសកម្ពុជា៖ តួនាទីរបស់ស្ថាប័នសិក្សា" សុទ្ធតែបានទទួលស្គាល់ថា ធុរកិច្ចជាច្រើនមានការលំបាកយ៉ាងខ្លាំងក្នុងការស្វែងបុគ្គលិក និងអ្នកគ្រប់គ្រងដែលមានជំនាញនិងទេពកោសល្យពិតប្រាកដ ព្រមទាំងបានទទួលស្គាល់ពីការលំបាកក្នុងការដោះស្រាយបញ្ហានេះ។[68] ក្នុងអត្ថន័យសិក្សា "វិស័យឧស្សាហកម្មចង់ឱ្យយើងបណ្តុះបណ្តាលនិស្សិតបញ្ចប់ការសិក្សាប្រកបដោយគុណវុឌ្ឍិ ប៉ុន្តែវិស័យឧស្សាហកម្មបែរជាមិនចង់មានការចូលរួមពាក់ព័ន្ធអ្វីទាំងអស់ ដោយគ្រាន់តែរង់ចាំជ្រើសរើសយកនិស្សិតតែប៉ុណ្ណោះ"។[69] កង្វះការពិគ្រោះយោបល់គ្នារវាងស្ថាប័នអប់រំនិងបណ្តុះបណ្តាលជាមួយថ្នាក់ដឹកនាំវិស័យឧស្សាហកម្ម និងនិយោជក ជាហេតុនាំឱ្យខ្វះនិស្សិតបញ្ចប់ការសិក្សាដែលមានជំនាញក្នុងមុខរបរមួយចំនួន និងបែរជាមានការបណ្តុះបណ្តាលច្រើនលើសតម្រូវការសម្រាប់មុខរបរដទៃទៀត។ ការអភិវឌ្ឍឥរិយាបថរបស់និស្សិតក៏ជាកិច្ចការចាំបាច់មួយដែរសម្រាប់ប្រព័ន្ធអប់រំនៅកម្ពុជា ដូចជា ការបណ្តុះបណ្តាលអំពីការហ៊ានទទួលយកហានិភ័យ ដើម្បីលើកទឹកចិត្តពួកគេឱ្យហ៊ានដើរចេញពីទីសុខុមាលភាព។

គិតត្រឹមឆ្នាំ២០១៩ ភាគច្រើននៃនិយោជិតខ្មែរចំនួន ៥០ ០០០ នាក់ ដែលមានជំនាញឌីជីថលខ្ពស់ កំពុងបម្រើការងារនៅក្នុងក្រុមហ៊ុនបែបប្រពៃណីធំៗ ដូចជាធនាគារ តំណាងចែកចាយ ឧស្សាហកម្ម ជាដើម។ ចំណែកឯនិយោជិតដែលសល់ពីនោះ ភាគច្រើនផ្តល់សេវាកម្មបច្ចេកវិទ្យាព័ត៌មានដល់ក្រុមហ៊ុនរចនាគេហទំព័រ និងកម្មវិធី។[70]

[67] National Employment Agency 2017.

[68] See CDRI 2019. ការរកឃើញស្រដៀងគ្នា នឹងការរកឃើញរបស់ kem et al. 2019.

[69] Sam and Dahles 2017, p.17.

[70] See Cambodian_Tech_Startup_Report_Final_150319.pdf (squarespace.com).

សាកលវិទ្យាល័យនិងកម្មវិធីគាំទ្រនានា បានរាយការណ៍អំពីកំណើនចំណាប់អារម្មណ៍របស់ពលរដ្ឋវ័យក្មេង ជាពិសេសនិស្សិតទើបបញ្ចប់សិក្សាដែលមានគំនិតចង់បង្កើតធុរកិច្ចថ្មីផ្ទាល់ខ្លួនភ្លាមៗ ជាងទៅធ្វើការឱ្យក្រុមហ៊ុនដទៃ។

នៅក្នុងទីផ្សារការងារ ឬបន្ទាប់ពីដាក់ឱ្យដំណើរការធុរកិច្ចថ្មី ការអភិវឌ្ឍជំនាញថ្មីៗអាចជាកិច្ចការលំបាកមួយ ប្រសិនបើគេគ្មានឱកាសទទួលបានការណែនាំពីគ្រូឧទ្ទេស។

តួនាទីនៃបណ្ដាញទំនាក់ទំនង ឧទ្ទេស និងគំរូម៉ូឌែល ទេពកោសល្យនិយោជិត និងទុនវិនិយោគ គឺសុទ្ធតែជាគន្លឹះដ៏សំខាន់ក្នុងការអភិវឌ្ឍវិស័យ វ.ប.ន.។ នៅកម្ពុជា បើទោះបីជាគំរូម៉ូឌែលសហគ្រិនវ័យក្មេងក្នុងស្រុក និងមជ្ឈមណ្ឌលនវានុវត្តន៍នានាបានផ្ដល់ការគាំទ្រមួយចំនួន រួមមាន ឧទ្ទេសនិងការហ្វឹកហ្វឺនការងារសម្រាប់និស្សិតសាកលវិទ្យាល័យ និងអនាគតសហគ្រិនក្ដី ក៏ទំហំនិងរចនាសម្ព័ន្ធគាំទ្រការបង្វឹកនៅមានកម្រិត។

ថ្វីបើគេសង្កេតឃើញមានទម្រង់នៃភាពជាដៃគូយ៉ាងសកម្មក្នុងវិស័យអប់រំ ដូចជា សាកលវិទ្យាល័យជាច្រើនធ្វើការរួមគ្នាដើម្បីរៀបចំកម្មវិធីការប្រកួតប្រជែងផែនការធុរកិច្ចប្រចាំឆ្នាំ ក៏ដោយ ក៏សាកលវិទ្យាល័យជាច្រើនបានលើកឡើងពីការខ្វះភាពជាដៃគូជិតស្និទ្ធជាមួយតួអង្គពាក់ព័ន្ធផ្សេងៗទៀតនៅក្នុងប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មីផ្នែកបច្ចេកវិទ្យា។[71]

សាកលវិទ្យាល័យរដ្ឋ បានកត់សម្គាល់ថា បញ្ហាប្រឈមជាច្រើននៅតែមានក្នុងការអភិវឌ្ឍកម្មវិធីសិក្សាបុគ្គលិកមានបទពិសោធន៍ក្នុងការកសាងសហគមន៍ និងក្នុងការគ្រប់គ្រងបរិវេណនវានុវត្តន៍ ព្រមទាំងបញ្ហាផ្តល់ហិរញ្ញប្បទានដល់កម្មវិធីសិក្សានិងគម្រោងនានារបស់និស្សិតជាដើម។[72]

ជាទូទៅ ប្រទេសកម្ពុជាប្រឈមនឹងការខ្វះជំនាញស្វែម។ ជាក់ស្តែង កម្ពុជាមានអ្នកស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា តែ ១៧ នាក់ និងអ្នកបច្ចេកទេស ១៣ នាក់ ប៉ុណ្ណោះ ក្នុងចំណោមប្រជាជនមួយលាននាក់។[73] និស្សិតបញ្ចប់ការសិក្សាពីមហាវិទ្យាល័យឯកទេស ធុរកិច្ច ហិរញ្ញវត្ថុ ភាសាបរទេស និងវិទ្យាសាស្ត្រសង្គម មានចំនួនច្រើនជាង ៧០% នៃចំនួននិស្សិតបញ្ចប់នៅថ្នាក់ឧត្តមសិក្សា។ ជាងនេះទៅទៀត គុណភាពផ្នែកវិទ្យាសាស្ត្រនិងគណិតវិទ្យានៅកម្ពុជា ត្រូវទទួលរងឧបសគ្គ ដោយសារតែការខ្វះគ្រូបង្រៀនដែលមានគុណភាពផ្នែកវិទ្យាសាស្ត្រនិងគណិតវិទ្យា និងភាពខ្សត់ខ្សោយនៃបរិក្ខារឧបទ្ទេសសម្រាប់បង្រៀននិងរៀននៅថ្នាក់មធ្យមសិក្សាទុតិយភូមិ ព្រមទាំងចំណាប់អារម្មណ៍ និងឥរិយាបថរបស់សិស្សនៅមានកម្រិតទាបចំពោះមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យា។[74] ជាលទ្ធផល យោងតាមចំណាត់ថ្នាក់របស់វេទិកាសេដ្ឋកិច្ចពិភពលោក ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់ទី ៨៦ ក្នុងចំណោម ១០០ ប្រទេស ពាក់ព័ន្ធនឹងធនធានមនុស្សដែលមានជំនាញឌីជីថល វិទ្យាសាស្ត្រ និងគ្រប់គ្រង ដើម្បីត្រៀមសម្រាប់បដិវត្តន៍ឧស្សាហកម្មទី៤។

## ប្រព័ន្ធអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (ជីវេត) និងបញ្ហាប្រឈមនៅក្នុងការបង្កើនសមត្ថភាពបច្ចេកវិទ្យានៅក្នុងសហគ្រាសធុនតូច និងមធ្យម

[71] Kem et al. 2019, p.20.
[72] Ibid.
[73] Government of Cambodia 2013.
[74] Ministry of Education Youth and Sports 2016.

បញ្ហាប្រឈមបន្ទាន់មួយទៀតសម្រាប់ប្រទេសកម្ពុជា គឺការអភិវឌ្ឍធនធានមនុស្សនៅកម្រិតបច្ចេកទេស និងវិជ្ជាជីវៈ សំដៅឈានទៅបង្កើនសមត្ថភាពបច្ចេកវិទ្យារបស់សហគ្រាសធុនតូច និងមធ្យមដែលសកម្មក្នុងវិស័យកសិកម្ម វិស្វកម្ម និងវិទ្យាសាស្ត្រធម្មជាតិ។ សហគ្រាសបរទេសធំៗនៅកម្ពុជា ដែលជាប្រភពដ៏សំខាន់នៃការនាំចេញដែលមានតម្លៃបន្ថែម ច្រើនតែទោរទោរកេជំនាញឯកទេសផ្នែកគ្រឿងម៉ាស៊ីនអគ្គិសនី និងទូរគមនាគមន៍។ បច្ចុប្បន្ន ការផ្ទេរបច្ចេកវិទ្យាពីសហគ្រាសធំៗទាំងនេះទៅកាន់សហគ្រាសតូចៗ និងវិស័យផ្សេងៗទៀត គឺមិនទាន់បានពេញលេញនៅឡើយ ហើយការសម្របសម្រួលឱ្យមានការផ្ទេរបច្ចេកវិទ្យាប្រភេទនេះនឹងជួយបង្កើនសមត្ថលទ្ធភាពជំនាញ និងនវានុវត្តន៍នៅក្នុងប្រទេស។[75]

ទន្ទឹមនឹងការទទួលបានសមិទ្ធផលសំខាន់ៗ វិស័យធីវេតនៅកម្ពុជានៅតែជួបប្រទះបញ្ហាប្រឈមធំៗ មួយចំនួន ដូចដែលតួអង្គពាក់ព័ន្ធជាតិនានាបានលើកឡើងនៅក្នុងបទសម្ភាសន៍សម្រាប់របាយការណ៍នេះ៖

- ការបណ្តុះបណ្តាលបច្ចេកទេសមិនគ្រប់គ្រាន់ទាំងកម្រិតមធ្យម និងកម្រិតខ្ពស់
- ជំនាញ កម្មវិធីសិក្សា អាជីពនិយម កម្រិតនិងគុណភាពនៃការបណ្តុះបណ្តាលមិនអាចឆ្លើយតបទៅនឹងតម្រូវការទីផ្សារបានពេញលេញឡើយ និង
- ការចូលរួមរបស់វិស័យឯកជនក្នុងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅមានកម្រិត។

### ការខ្វះភាពទាក់ទាញ និងឧត្តមភាពនៅក្នុងការស្រាវជ្រាវ

ការបង្កើតចំណេះដឹងនៅកម្ពុជា នៅតែមានកម្រិតនៅឡើយ។ ខណៈរាជរដ្ឋាភិបាលបានផ្តោតការវិនិយោគតែក្នុងការគាំទ្រនវានុវត្តន៍នៅតាមសហគ្រាស ការវិនិយោគក្នុងសកម្មភាពស្រាវជ្រាវវិញគឺនៅមានកម្រិតទាប ការសម្របសម្រួលក្នុងចំណោមស្ថាប័នស្រាវជ្រាវថ្នាក់ជាតិនិងក្រសួង ទៅលើការរៀបចំរបៀបវារៈស្រាវជ្រាវគឺនៅខ្សោយ ហើយទំនាក់ទំនងរវាងស្ថាប័នស្រាវជ្រាវ និងវិស័យឯកជនគឺទើបចាប់ផ្តើមដុះពន្លកតែប៉ុណ្ណោះ។

## ៥.៤ ហេដ្ឋារចនាសម្ព័ន្ធ និងលក្ខខណ្ឌនៃក្របខ័ណ្ឌថ្មី ដែលត្រូវការការពង្រឹងបន្ថែម

### បរិក្ខារឧបទ្ទេសភ្ញាស់ និងលទ្ធភាពទទួលបានហិរញ្ញប្បទានសម្រាប់ក្រុមហ៊ុនទើបបង្កើតថ្មីនៅពុំទាន់មានសភាពល្អប្រសើរនៅឡើយទេ

ខណៈដែលកម្មវិធីសម្រាប់គាំទ្រធុរកិច្ចថ្មីនៅដំណាក់កាលដំបូងកំពុងតែមានវត្តមានជាបណ្តើរៗក្តី ក៏មជ្ឈមណ្ឌលភ្ញាស់ និងពន្លឿនសម្រាប់គាំទ្រធុរកិច្ចថ្មីដំណាក់កាលពាក់កណ្តាល នៅពុំទាន់មានច្រើននៅឡើយ។

លទ្ធភាពទទួលបានដើមទុនវិនិយោគនិងមូលនិធិ គឺត្រូវបានតួអង្គពាក់ព័ន្ធនានាលើកឡើងថាជាបញ្ហាប្រឈមដ៏ធំមួយសម្រាប់ស្ថាបនិកធុរកិច្ចថ្មី។ ជាទូទៅ ការយល់ដឹងអំពីតម្រូវការរបស់ធុរកិច្ចថ្មីដែលទើបចាប់ផ្តើមដំបូង និងកំពុងរីកលូតលាស់ក្នុងចំណោមវិនិយោគិន រួមទាំងសហវិនិយោគិន និងវិនិយោគិនគាំទ្រហិរញ្ញវត្ថុមានកម្រិតទាបនៅឡើយ។ កម្រិតទាបនៃភាពទំនើបនៃការធ្វើធុរកិច្ច និងកង្វះខាតបទពិសោធន៍ទូលំទូលាយរបស់

[75] See De la Pena and Taruno, 2012 and UNESCO Science Report 2015, p. 711.

ស្ថាបនិក គឺជាបញ្ហាប្រឈមសម្រាប់ការអភិវឌ្ឍវិស័យនវានុវត្តន៍នៅកម្ពុជា។ បណ្តាវិនិយោគិនបានសង្កេតឃើញថា ស្ថាបនិកធុរកិច្ចថ្មីដែលទើបចាប់ផ្តើមដំបូងមកបញ្ចុះបញ្ចូលពួកគាត់ឱ្យគាំទ្រ តាំងតែពីមុនពេលដែលស្ថាបនិកទាំងនោះជជែកពិភាក្សាឬយល់ដឹងទូលំទូលាយអំពីអតិថិជនរបស់ខ្លួនទៅទៀត។ សម្រាប់ស្ថាបនិកដែលបានចូលរួមកម្មវិធីណែនាំ ឬកម្មវិធីពន្លឿនការបណ្តុះធុរកិច្ចវិញ ពួកគេច្រើនតែផ្តោតខ្លាំងពេកទៅលើការបំពេញតម្រូវការប្រកួតប្រជែង និងមិនសូវជាផ្តោតលើការបង្កើតវឌ្ឍនភាពធុរកិច្ចឱ្យមាននិរន្តរភាពបន្ទាប់ពីកម្មវិធីនោះទេ។

ការផ្តល់ហិរញ្ញប្បទានជាផ្លូវការសម្រាប់ធុរកិច្ចថ្មី ពីសំណាក់ស្ថាប័នឥណទានក៏មានការខ្វះខាតដែរ។ វិស័យដែលផ្តោតលើការផ្តល់ទុនវិនិយោគ ដូចជាទុនវិនិយោគផ្សងព្រេង និងវិនិយោគិនគាំទ្រហិរញ្ញវត្ថុ ជាដើម គឺទើបតែនឹងចាប់ផ្តើមដុះពន្លក ដោយមានអ្នកគ្រប់គ្រងមូលនិធិដែលសកម្មតិចតួចប៉ុណ្ណោះ។ ទំហំទីផ្សារដ៏តូចនៅកម្ពុជាគឺជាឧបសគ្គមួយដែរ បើទោះបីជា នេះអាចជាឱកាសមួយសម្រាប់ជាទីផ្សារដើម្បីធ្វើការសាកល្បងនវានុវត្តន៍ មុននឹងពង្រីកចូលទៅក្នុងទីផ្សារតំបន់អាស៊ានទាំងមូល។[76]

ស្ថាបនិកធុរកិច្ចថ្មីវ័យក្មេងខ្វះការយល់ដឹងអំពីមូលដ្ឋានគ្រឹះនៃម៉ូដែលហិរញ្ញវត្ថុ ដូចជា ភាពខុសគ្នារវាងមូលធន និងបំណុល ក៏ដូចជាខ្វះការយល់ដឹងអំពីពាក្យពេចន៍ប្រើផ្សេងៗគ្នាពាក់ព័ន្ធនឹងហិរញ្ញវត្ថុ លក្ខខណ្ឌសមិទ្ធកម្មនៃការផ្តល់មូលនិធិ និងផ្សេងៗទៀតជាច្រើន។ ការណ៍នេះបានឆ្លុះបញ្ចាំងមួយផ្នែកអំពីភាពនៅមានកម្រិតនៃការអប់រំធុរកិច្ចនៅតាមប្រព័ន្ធអប់រំផ្លូវការ ឬនៅតាមកម្មវិធីគាំទ្រសហគ្រិនភាពផ្សេងៗ។

ប្រព័ន្ធច្បាប់ និងហិរញ្ញវត្ថុជាទូទៅមានលក្ខណៈស្មុគស្មាញ និងមិនច្បាស់លាស់ដែរសម្រាប់ធុរកិច្ចថ្មី និងសហគ្រាសធុនតូចនិងមធ្យម។ ការកែសម្រួលបទប្បញ្ញត្តិ និងគោលការណ៍ឱ្យសាមញ្ញ ជាពិសេសសម្រាប់ធុរកិច្ចថ្មី និងសហគ្រាសធុនតូច និងមធ្យមដែលមាននវានុវត្តន៍ នឹងជួយលើកទឹកចិត្តឱ្យមានការបណ្តុះធុរកិច្ចថ្មី និងនវានុវត្តន៍នៅក្នុងក្រុមហ៊ុន។

## កម្មសិទ្ធិបញ្ញា និងសេវាព័ត៌មាន

ច្បាប់កម្មសិទ្ធិបញ្ញាកម្ពុជាមានភាពជឿនលឿនជាងបណ្តាសមាជិកអាស៊ានដទៃទៀត ប៉ុន្តែការអនុវត្តច្បាប់គឺមិនមានភាពទូលំទូលាយ និងជាបញ្ហាប្រឈម។ អាជ្ញាធរប្រកាសនីយបត្រតក្កកម្ម របស់កម្ពុជា ខ្វះខាតមូលនិធិគ្រប់គ្រាន់ ក៏ដូចជាជំនាញដើម្បីពិនិត្យឯកសារស្នើសុំប្រកាសនីយបត្រតក្កកម្ម និងអាជ្ញាធរបាននិងកំពុងសហការជាមួយការិយាល័យកម្មសិទ្ធិបញ្ញានៃប្រទេសសិង្ហបុរី និងជប៉ុន ដើម្បីផ្តល់ការការពារប្រកាសនីយបត្រតក្កកម្មដល់អ្នកស្នើសុំដែលបានចុះបញ្ជីប្រកាសនីយបត្រតក្កកម្មរួចហើយនៅក្នុងប្រទេសសាមី។[77] ប៉ុន្តែ ក៏នៅតែខ្វះខាតមន្ត្រីជំនាញដែលអាចធ្វើការងារ និងឆ្លើយតបបានរហ័ស។ ការយល់ដឹងរបស់សាធារណជនអំពីកម្មសិទ្ធិបញ្ញាគឺនៅតែមានកម្រិត ហើយក៏មានការខ្វះខាតនូវបរិក្ខារដើម្បីគាំទ្រក្នុងដំណើរការចុះបញ្ជីកម្មសិទ្ធិបញ្ញាដែរ។[78] បើតាមរបាយការណ៍បញ្ជាក់នានា យន្តការនៃការដាក់ពាក្យស្នើសុំ ការចុះឈ្មោះ និងការអនុវត្តច្បាប់នៅកម្ពុជា "គឺស្ថិតនៅក្នុងដំណាក់កាលដំបូងនៅឡើយ" បើទោះបីជាមានការរីកចម្រើនក្នុងប៉ុន្មានឆ្នាំចុងក្រោយ

[76] គេមើលឃើញពីការកើនឡើងនៃចំនួនទស្សនកិច្ចពាណិជ្ជកម្មផ្តោតលើបច្ចេកវិទ្យាពីសំណាក់សហគមន៍បច្ចេកវិទ្យានៅក្នុងតំបន់ ដូចមាននៅរៀបរាប់នៅក្នុងរបាយការណ៍ "Cambodia's Vibrant Tech Startup Ecosystem"។របាយការណ៍នេះបានគូសបញ្ជាក់ពីការទទួលស្គាល់កម្ពុជាថាជាទីផ្សារសម្រាប់ការសាកល្បងគំនិតថ្មីៗ។

[77] OECD, ERIA and the Association of Southeast Asian Nations 2018, p. 245.

[78] Government of Cambodia 2019.

នេះ។[79] ពាក់ព័ន្ធនឹងការប្រឈមទាំងនេះ ផែនការអភិវឌ្ឍន៍វិស័យឧស្សាហកម្មបានបញ្ចូលគោលដៅជាក់លាក់ដើម្បីកែលម្អប្រសិទ្ធភាពនៃការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម ក្នុងនោះរួមទាំងការទទួលស្គាល់ភ្នាក់ងារនៃប្រទេសជាដៃគូ និងដើម្បីបង្កើនស្វ័យប្រវត្តិកម្មប្រព័ន្ធចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម (សូមអានផ្នែក ៦.៣ ខ នៅក្នុងគោលនយោបាយ)។

ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្មឆ្នាំ ២០០៦ នៅមានកម្រិតនៅក្នុងការអនុវត្តជាក់ស្តែងនៅឡើយ លើកលែងតែក្រុមហ៊ុនបរទេសធំៗដែលកំពុងប្រតិបត្តិការនៅកម្ពុជា។ ពិតណាស់ ចាប់ពីឆ្នាំ២០១១ មក ចំនួនពាក្យស្នើសុំប្រកាសនីយបត្រតក្កកម្មមានជាមធ្យមចំនួន ៧៧ សំណើ។ ក្នុងចន្លោះឆ្នាំ២០១១ ដល់ឆ្នាំ២០១៨ ក្នុងចំណោមពាក្យស្នើសុំចំនួន ៦២០ មានចំនួនតែ ៥ ប៉ុណ្ណោះដែលត្រូវបានស្នើសុំដោយអ្នករស់នៅក្នុងប្រទេស។[80]

ព័ត៌មានអំពីមូលនិធិ ក៏ដូចជាជំនួយផ្នែកច្បាប់ និងពន្ធដារគឺមានសារសំខាន់ណាស់សម្រាប់សហគ្រាសធុនតូច និងមធ្យម ប៉ុន្តែសហគ្រាសទាំងនោះពិបាកនឹងទទួលបានព័ត៌មានទាំងនោះ។ ដំណើរការផ្នែកច្បាប់ និងពន្ធសម្រាប់ធុរកិច្ចថ្មីនិងបច្ចេកវិទ្យា គឺជាកិច្ចការដ៏លំបាកមួយសម្រាប់ស្ថាបនិកធុរកិច្ចថ្មី។ ពួកគេបង្ហាញពីការលំបាកក្នុងការស្វែងរកប្រភពព័ត៌មានដែលមានបច្ចុប្បន្នភាព និងច្បាស់លាស់ ដែលអាចជួយបង្ហាញផ្លូវពួកគេទៅរកគោលនយោបាយ ដើម្បីបញ្ចៀសការខ្វះខាតធនធានជាមួយភាពស្មុគស្មាញ និងស្រពេចស្រពិល។

ខណៈដែលអ្នកធុរកិច្ចថ្មីចាត់ទុកការផ្តល់កន្លែងធ្វើការងាររួមគ្នាថាជាសេវាកម្មដែលមិនសូវសំខាន់ ពួកគេយល់ថា សេវាប្រឹក្សាអំពីវិនិយោគ ច្បាប់ និងពន្ធដារគឺមានសារសំខាន់ខ្លាំងណាស់ ហើយទន្ទឹមគ្នានេះពួកគេក៏ចង់ទទួលបានឱកាសជួបជាមួយអ្នកជំនាញខាងវិនិយោគ ដើម្បីស្នើសុំអ្នកទាំងនោះធ្វើជាអ្នកណែនាំ ឬជាដៃគូយុទ្ធសាស្ត្រ។

## បទដ្ឋាន និងវិញ្ញាបនបត្រកម្ម

ការបរិយាយអំពីវិទ្យាស្ថានស្តង់ដារកម្ពុជា និងតួនាទីរបស់ស្ថាប័ននេះមានលើកឡើងនៅក្នុងផ្នែក ៤.៥។

តួអង្គពាក់ព័ន្ធនានានៅថ្នាក់ជាតិបានឱ្យដឹងថា ធុរកិច្ចថ្មី និងសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា ពុំមានលទ្ធភាពទទួលបានព័ត៌មានស្តីអំពីបទដ្ឋាន និងវិញ្ញាបនបត្រកម្មទេ ហើយប្រព័ន្ធបទដ្ឋាននិងវិញ្ញាបនបត្រកម្មនោះទៀតសោតក៏នៅមិនទាន់មានដំណើរការពេញលេញនោះដែរ។ ការណ៍នេះបានបន្ថយឱកាសរបស់សហគ្រាសក្នុងការបោះជំហានចូលទៅក្នុងខ្សែច្រវ៉ាក់តម្លៃតំបន់ និងការអភិវឌ្ឍផលិតផលសម្គាល់ភូមិសាស្ត្រ។

---

[79] DFDL 2015.
[80] See www.wipo.int/ipstats/en/statistics/country_profile/profile.jsp?code=KH.

ជំពូកទី

# ៦

# សេចក្ដីសន្និដ្ឋាន និង អនុសាសន៍

គោលនយោបាយជាតិស្ដីពី វ.ប.ន. មានគោលដៅជំរុញវិស័យ វ.ប.ន. ឱ្យក្លាយជាកម្លាំងចលករដ៏សំខាន់ក្នុងការអភិវឌ្ឍសង្គមសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាប័ន្ន ដើម្បីឈានទៅសម្រេចចក្ខុវិស័យរបស់រាជរដ្ឋាភិបាល សំដៅធ្វើឱ្យកម្ពុជាក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០ និងឈានទៅសម្រេចគោលដៅជាតិសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ គោលដៅនៃគោលនយោបាយ វ.ប.ន. គឺការឈានទៅពង្រឹងមូលដ្ឋានគ្រឹះ វ.ប.ន. លើកកម្ពស់ប្រព័ន្ធអេកូឡូស៊ី ក៏ដូចជាការកសាងលក្ខខណ្ឌដែលអំណោយផលដល់ការរីកលូតលាស់នៃវិស័យ វ.ប.ន សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងឈានទៅលើកកម្ពស់គុណភាពនៃការរស់នៅរបស់ប្រជាជននៅគ្រប់កម្រិត និងគ្រប់វិស័យ។ គោលដៅខាងលើនេះអាចនឹងសម្រេចទៅបាន លុះត្រាតែមានការសម្របខ្លួន ក៏ដូចជាការចាប់យកបច្ចេកវិទ្យាថ្មីៗ និងការបន្តលើកកម្ពស់វិស័យនវានុវត្តន៍បន្ថែមទៀត។

ការលើកកម្ពស់ វ.ប.ន. ក៏ត្រូវបានដាក់បញ្ចូលផងដែរនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ ក៏ដូចជានៅក្នុងចក្ខុវិស័យឆ្នាំ២០៥០ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ និងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ឆ្នាំ២០១៥-២០២៥។

ប្រព័ន្ធនវានុវត្តន៍កម្ពុជាកំពុងស្ថិតនៅក្នុងដំណាក់កាលអភិវឌ្ឍន៍នៅឡើយ។ ដោយផ្អែកលើចំណុចខ្លាំង និងចំណុចខ្សោយបច្ចុប្បន្ន រាជរដ្ឋាភិបាលចាំបាច់ត្រូវអនុវត្តវិធានការជាអនុសាសន៍មួយចំនួនដូចរៀបរាប់ខាងក្រោម ដើម្បីអភិវឌ្ឍប្រព័ន្ធនវានុវត្តន៍ជាតិឱ្យឈានឡើងមួយកម្រិតថែមទៀត។

**ពង្រឹងអភិបាលកិច្ចរបស់ប្រព័ន្ធ វ.ប.ន.៖** អភិបាលកិច្ច វ.ប.ន. គឺជាគន្លឹះដ៏មានសារសំខាន់ ហើយត្រូវបានរៀបចំរចនាសម្ព័ន្ធឡើងវិញតាមរយៈការបង្កើតក្រសួង ឧ.វ.ប.ន. នាខែមីនា ឆ្នាំ២០២០។ វាមានសារសំខាន់ណាស់ក្នុងការពង្រឹងរចនាសម្ព័ន្ធថ្មីនេះ ដោយកាត់បន្ថយការបែងចែកនិងការធ្វើការដាច់ដោយឡែកគ្នាពីរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធនានា។ ប៉ុន្តែតម្រូវឱ្យមានការកំណត់តួនាទីរបស់ក្រសួងឧ.វ.ប.ន. និងក្រសួងស្ថាប័នពាក់ព័ន្ធដទៃទៀត ព្រមទាំងពង្រឹងការយល់ដឹង និងសមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តគោលនយោបាយស្ដីពី វ.ប.ន. ក៏ដូចជាការត្រួតពិនិត្យតាមដាន និងវាយតម្លៃសកម្មភាពលើកកម្ពស់វិស័យ វ.ប.ន.។

**កសាងធនធានមូលធនក្នុងវិស័យ វ.ប.ន.៖** តម្រូវការនវានុវត្តន៍នៅមានកម្រិតទាបនៅឡើយ ហើយវប្បធម៌នៃវិទ្យាសាស្ត្រ និងសហគ្រិនភាពថ្មី ក៏នៅមានកម្រិតដែរក្នុងសង្គមកម្ពុជានាពេលបច្ចុប្បន្ន។ វាមានសារសំខាន់ណាស់ក្នុងការលើកកម្ពស់ចំណេះដឹងផ្នែកវិទ្យាសាស្ត្រ ឌីជីថល និងសហគ្រិនភាព ក៏ដូចជាការត្រៀមខ្លួន

ជាស្រេចក្នុងការចាប់យកបច្ចេកវិទ្យាថ្មីក្នុងចំណោមយុវជន ដោយចាប់ផ្តើមពីការអប់រំថ្នាក់មូលដ្ឋានឡើងទៅ។ ការបង្រៀនផ្នែក វ.ប.ន. ដល់កុមារនឹងជួយបង្កើតឱ្យមានអ្នកវិទ្យាសាស្ត្រ និងអ្នកនវានុវត្តន៍ជំនាន់ថ្មី។ ជំនាញផ្នែកស្ទែម ក៏ត្រូវការការលើកកម្ពស់នៅក្នុងថ្នាក់ឧត្តមសិក្សាផងដែរ។ លើសពីនេះទៀត ការបង្រៀន និងកិច្ចសហការជាមួយវិស័យឯកជននៅតាមស្ថាប័ន អប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ(ជីវេត) នៅមានកម្រិតនៅឡើយ និងគួរត្រូវបានគិតគូរពង្រឹងបន្ថែមទៀត។ យុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្សគឺជាមូលដ្ឋានគ្រឹះក្នុងការលើកកម្ពស់វិស័យ វ.ប.ន.។

**ពង្រឹងសមត្ថភាពស្រាវជ្រាវ និងគុណភាព៖** កសាងសមត្ថភាពគ្រឹះស្ថានឧត្តមសិក្សា និងប្រព័ន្ធស្រាវជ្រាវ គឺជាកិច្ចការចាំបាច់មួយ ដើម្បីទទួលបាននូវការស្រាវជ្រាវនិងអភិវឌ្ឍន៍ ប្រកបដោយគុណភាពខ្ពស់ស្របទៅតាមផលប្រយោជន៍ជាតិ និងនៅក្នុងវិស័យអាទិភាព។ ដើម្បីសម្រេចគោលដៅនេះ តម្រូវឱ្យមានការបង្កើតរបៀបវារៈស្រាវជ្រាវថ្នាក់ជាតិ ជាមួយសហគមន៍អ្នកសិក្សាស្រាវជ្រាវ និងសហការយ៉ាងជិតស្និទ្ធជាមួយវិស័យឯកជន តាមរយៈការផ្តល់ជាមូលនិធិដើម្បីគាំទ្រស្នាដៃលេចធ្លោពាក់ព័ន្ធនឹងវិទ្យាសាស្ត្រ ការធ្វើអន្តរជាតូបនីយកម្មកិច្ចការស្រាវជ្រាវ ព្រមទាំងការលើកទឹកចិត្តឱ្យមានកិច្ចសហការជាមួយវិស័យឯកជន។

**បង្កើនកិច្ចសហការនិងបណ្តាញរវាងតួអង្គពាក់ព័ន្ធ៖** នវានុវត្តន៍បានមកពីការផ្លាស់ប្តូរគំនិតក្នុងចំណោម បុគ្គល អង្គការ វិស័យ និងផ្នែកវិទ្យាសាស្ត្រជាដើម។ អង្គភាពអន្តរការី (Intermediary Organization) និង អង្គភាពឈ្មួញកណ្តាលចំណេះដឹង(Knowledge Broker Institution) គឺជាតួអង្គដ៏សំខាន់ក្នុងការដើរតួជាអ្នកសម្របសម្រួលឱ្យមានការផ្លាស់ប្តូរគំនិតយោបល់គ្នា។ ដូច្នេះហើយ វាមានភាពចាំបាច់ណាស់ក្នុងការជំរុញនិងធានានិរន្តភាពបរិក្ខារឧបទ្វេសភ្ញាស់និងពន្លឿន (Incubation and Acceleration Facilities) និងវេទិកាបច្ចេកវិទ្យា ដែលបើកចំហដល់វិស័យឯកជន និងបណ្តុំស្ថាប័នដែលមានលក្ខណៈនវានុវត្តន៍ (Innovative Clusters) សំដៅជំរុញកិច្ចសហប្រតិបត្តិការ ដើម្បីគាំទ្រដល់នវានុវត្តន៍ នៅតាមបណ្តាសហគ្រាសធុនតូចនិងមធ្យម ព្រមទាំងលើកកម្ពស់សមត្ថភាពស្រូបយកបច្ចេកវិទ្យា និងចំណេះដឹងថ្មីរបស់សហគ្រាសទាំងនោះ។

**ជំរុញឱ្យមានបរិយាកាសអំណោយផលដល់នវានុវត្តន៍៖** ការគាំទ្រដល់សមត្ថភាពនវានុវត្តន៍ និងបង្កើនសមត្ថភាពស្រូបយករបស់ក្រុមហ៊ុន ទាមទារឱ្យមានហិរញ្ញប្បទាន និងការលើកកម្ពស់រចនាសម្ព័ន្ធអន្តរការីដែលជួយបណ្តុះធុរកិច្ចថ្មី (Start-Up) ក៏ដូចជាគាំទ្រការផ្ទេរបច្ចេកវិទ្យា និងលើកកម្ពស់បច្ចេកវិទ្យាក្នុងស្រុក។ លើសពីនេះទៅទៀត គេក៏ចាំបាច់ត្រូវជួយជំរុញស្ថាប័នណាដែលមានសមត្ថកិច្ចក្នុងការផ្តល់សេវាកម្មបច្ចេកវិទ្យា និងគុណភាព (ដូចជា បទដ្ឋាននិងវិញ្ញាបនបត្រកម្ម) ទៅដល់បណ្តាក្រុមហ៊ុន។ម្យ៉ាងទៀត វាក៏ទាមទារនូវការបង្កើនលទ្ធភាពទទួលបានហិរញ្ញប្បទាន សម្រាប់សកម្មភាពនវានុវត្តន៍ តាមរយៈការលើកកម្ពស់ការវិនិយោគពីវិស័យឯកជន និងការទាក់ទាញប្រភពថវិកាពីម្ចាស់ជំនួយ។ ការលើកទឹកចិត្តឱ្យមានការវិនិយោគផ្ទាល់ពីបរទេស ដែលគាំទ្រដល់ការកសាង សមត្ថភាពបច្ចេកវិទ្យាក្នុងស្រុក ការសម្របសម្រួលការនាំចូលឧបករណ៍បច្ចេកទេស និងការលើកកម្ពស់កម្មសិទ្ធិបញ្ញា គឺជាមធ្យោបាយបន្ថែមក្នុងការជំរុញឱ្យមានប្រព័ន្ធអេកូឡូស៊ីដែលបង្កបរិយាកាសដល់ការអនុវត្តនវានុវត្តន៍៕

# ឯកសារយោង


Cambodia Development Resource Institute (CDRI) (2019). "Innovation and Entrepreneurship Ecosystem in Cambodia: The Roles of Academic Institutions".

Cambodia, Government of Cambodia (2013). National Science and Technology Master Plan 2014–2020. Available at http://snt.gov.kh/wp-content/uploads/2016/03/Master-Plan-2014-2020.pdf.

_____ (2019). Cambodia's Voluntary National Review 2019 on the Implementation of the 2030 Agenda for Sustainable Development.

Cambodia, Ministry of Education, Youth and Sports (2016). Policy Guidelines for New Generation Schools.

Cambodia, Ministry of Industry and Handicraft (2016). Cambodia Industrial Development Policy 2015–2025. Available at www.mih.gov.kh/File/UploadedFiles/12_9_2016_4_29_43.pdf.

Cambodia, National Employment Agency (2018). Skills Shortages and Skills Gaps in the Cambodian Labour Market: Evidence from Employer Survey 2017. Available at www.khjobs.net/images/survay/ESNS%202017--Final--05282018.pdf.

Cicera, Xavier, and William F. Maloney (2017). "The Innovation Paradox: Developing-Country Capabilities and the Unrealized Promise of Technological Catch-Up". Washington D.C.: World Bank.

Cohen, Wesley M., and Daniel A. Levinthal (1990). "Absorptive Capacity: A New Perspective on Learning and Innovation", in *Administrative Science Quarterly*, 35, pp. 128–152.

DFDL (2015). Cambodian Intellectual Property Laws and Regulations Update 2015. 3 March. Available at www.dfdl.com/resources/legal-and-tax-updates/cambodia-intellectual-property-laws-regulations/.

De la Pena, F. T., and W. P. Taruno (2012). Study on the State of S&T Development in ASEAN. Taguig City, the Philippines: Committee on Science and Technology of Association for Southeast Asian Nations.

Freeman (1987). Technology and Economic Performance: Lessons from Japan. London: Pinter.

General Secretariat of the National Science and Technology Council (2019). Summary of National Priority Technology Report.

International Labour Organization (2019). "The Footwear Sector - New Opportunities for Cambodia?", in *Cambodia Garment and Footwear Sector Bulletin*, 9. Available at www.ilo.org/wcmsp5/groups/public/---asia/---ro-bangkok/documents/publication/wcms_714915.pdf.

Kem, Bora, Jolyda Sou, Zoë Ng, Penhleak Chan (2019). "Cambodia's Vibrant Tech Startup Ecosystem in 2018." Research Report 2. Phnom Penh: Mekong Strategic Partners and Raintree Development.

Konrad-Adenauer-Stiftung Cambodia (2019). Preparing Cambodia's Workforce for a Digital Economy. Digital Insights. Phnom Penh.
Lundvall (1992). National Innovation Systems: Towards a Theory of Innovation and Interactive Learning. London: Pinter.

Lyne, Isaac, Chanrith Ngin, Emannuel Santo Rio (2013). Understanding Social Enterprise, Social Economy and Local Social Entrepreneurship in the Context of Rural Cambodia. Conference: 4th EMES International Research Conference on Social Enterprise. Liege, Belgium, July.

Nelson (1993). National Innovation Systems. A Comparative Analysis. New York/Oxford: Oxford University Press.
OECD (2018). "Chapter 3. Cambodia", in Good Regulatory Practices to Support Small and Medium Enterprises in Southeast Asia, pp. 56–75.

OECD, ERIA and the Association of Southeast Asian Nations (2018). "Chapter 13. Cambodia", in SME Policy Index:
ASEAN 2018 – Boosting competitiveness and inclusive growth, pp. 231–255.

Pidor, Lydet (2018). Cambodian SMEs in the 4th Industrial Revolution: Government Policies and Opportunities.

Sam, Chanphirun, and Heidi Dahles (2017). "Stakeholder Involvement in the Higher Education Sector in Cambodia," in *Studies in Higher Education*, 42 (9) pp. 1764–1784.

Schwaag Serger, S., Emily Wise and Erik Arnold (2015). National Research and Innovation Councils as an Instrument of Innovation Governance – Characteristics and challenges. Vinova Analysis, November.

Smith-Hefner, N. J. (1999). Khmer American: Identity and moral education in a diasporic community. Berkeley: University of California Press.

Stam, F.C. (2017). "Measuring Entrepreneurial Ecosystems," Working Papers 17-11, Utrecht School of Economics.

United Nations Development Programme (UNDP) (2019). Human Development Report Cambodia: Sustaining natural resources for all. Phnom Penh.

United Nations Economic Commission for Asia and the Pacific (ESCAP) and Inclusive Business Action Network (iBAN) (2020). Landscape Study of Inclusive Business in Cambodia. Available at www.unescap.org/sites/default/d8files/knowledge-products/Landscape%20Study%20Inclusive%20Business%20Cambodia%20ESCAP%20iBAN%202021%20REPORT%20Final.pdf.

United Nations Educational, Scientific and Cultural Organization (UNESCO) (2015). "Chapter 27. Southeast Asia and Oceania", in UNESCO Science Report, pp. 692–731.

World Bank (2016a). Cambodia Economic Update: Enhancing export competitiveness – the key to Cambodias Future Economic Success. Phnom Penh, Cambodia Country Office.

World Bank (2016b). Globalization and the Gender Earnings Gap: Evidence from Sri Lanka and Cambodia.

World Bank (2018). Entrepreneurial Cambodia – Cambodia Policy Note. Washington D.C.

World Bank (2019). Cambodia Economic Update: Recent economic developments and outlook. Phnom Penh, Cambodia Country Office.

World Vision (2015). Country Profile: Cambodia. Available at www.worldvision.com.au/docs/default-source/global-one/country-profile-cambodia.pdf.

# ឧបសម្ព័ន្ធ

## តារាងស្ថាប័នពាក់ព័ន្ធដែលបានពិគ្រោះយោបល់

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**
- អគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- វិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- អគ្គនាយកដ្ឋានឧស្សាហកម្ម
- អគ្គនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម
- វិទ្យាស្ថានស្តង់ដារកម្ពុជា

**សមាជិកគណៈប្រឹក្សាយោបល់វិទ្យាសាស្ត្ររបស់ក្រុមប្រឹក្សាជាតិ-វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

**អតីតក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
- អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ

**ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ**

**ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**
- អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
- វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ

**ក្រសួងអប់រំ យុវជន និងកីឡា**
- អគ្គនាយកដ្ឋានឧត្តមសិក្សា
- អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ

**ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**
- អគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

**ក្រសួងពាណិជ្ជកម្ម**
- អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ
- អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
- អគ្គនាយកដ្ឋានបណ្តុះបណ្តាលនិងអប់រំវិជ្ជាជីវៈ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
- អគ្គនាយកដ្ឋានកសិកម្ម

**ក្រសួងសុខាភិបាល**
- អគ្គនាយកដ្ឋានសុខាភិបាល

**ក្រសួងផែនការ**
- អគ្គនាយកដ្ឋានផែនការ
- វិទ្យាស្ថានជាតិស្ថិតិ

**ក្រសួងសាធារណការ និង ដឹកជញ្ជូន**
- អគ្គនាយកដ្ឋានភស្តុភារកម្ម
- អគ្គនាយកដ្ឋានផែនការ

**ក្រសួងមហាផ្ទៃ**
- អគ្គស្នងការដ្ឋាននគរបាលជាតិ

**ក្រសួងការពារជាតិ**
- កងយុទ្ធពលខេមរភូមិន្ទ

**ក្រសួងមុខងារសាធារណៈ**

**ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

**មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ"**

**ធនាគារ SME កម្ពុជា**

**សម្ព័ន្ធសមាគមសហគ្រាសធុនតូចនិងមធ្យមកម្ពុជា**

**សភាពាណិជ្ជកម្មកម្ពុជា**

**វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា**

**សាកលវិទ្យាល័យភូមិន្ទភ្នំពេញ**

**សាកលវិទ្យាល័យភូមិន្ទកសិកម្ម**

**វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន**

**វិទ្យាស្ថានជាតិពហុបច្ចេកវិទ្យាកម្ពុជា**

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

**វិទ្យាស្ថានបច្ចេកវិទ្យាគិរីរម្យ**

**វិទ្យាស្ថានចក្ខុវិស័យអាស៊ី**

**ក្រុមហ៊ុន Impact Hub**

**ក្រុមហ៊ុន Small World**

**ក្រុមហ៊ុន Amru Rice**

**ក្រុមហ៊ុន GGear Group**

**ក្រុមហ៊ុន ISI Group**

**ក្រុមហ៊ុន ម៉ុង ឫទ្ធី គ្រុប**

**ក្រុមហ៊ុន ជីបម៉ុង**

**ក្រុមហ៊ុន Royal Group**

**ក្រុមហ៊ុន វីង**

**ក្រុមហ៊ុន Bongluy**

**ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)**

**ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)**

**ធនាគារពិភពលោក (WB)**

